**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សទ្តាត់

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ប៊ិន រ៉ូហ្សានណាបញ្ញាវត្តី**

**ខខ្យ សីហ៊ន**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្តដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សន្ទាត់

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ប៊ិន រ៉ូហ្សានណាបញ្ញាវត្តី**

**វង្ស សីហ៊ិន**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ម៉ិន រ៉ូហ្សានណាបញ្ញាវត្តី** និងខ្ញុំបាទឈ្មោះ **វង្ស សីហ៊ន** ជានិស្សិតបរិញ្ញាបត្រ ឆ្នាំទី៤ ជំនាន់ទី១៤ ផ្នែករដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០២០-២០២១។ ជាបឋម នាងខ្ញុំ ខ្ញុំបាទសូមធ្វើការថ្លែងអំណរគុណ និងសម្តែងនូវការដឹងគុណកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅ បំផុតចំពោះ៖

- លោក ឪពុក **ម៉ិន ញាណរិទ្ធី** និងអ្នកម្តាយ **សិទ្ធិ សុភ័ក្រ្ត**
- លោក ឪពុក **វង្ស សុខខឿន** និងអ្នកម្តាយ **អំ ចាន់ថូ**

ដែលលោកទាំងពីរបានផ្តល់កំណើត បីបាច់ចិញ្ចឹមថែរក្សារូបកូន ដោយមិនឱ្យ កូនខ្វះខាតអ្វីឡើយ។ លើសពីនេះទៅទៀតលោកទាំងពីរបានផ្គត់ផ្គង់នូវប្រាក់កាក់ឱ្យកូនបានរៀនសូត្រ តាំងពីថ្នាក់មត្តេយ្យ រហូតដល់ថ្នាក់ឧត្តមសិក្សាដើម្បីឱ្យកូនបានក្រេបយកនូវចំណេះវិជ្ជាដើម្បីជាប្រយោជន៍សម្រាប់ទៅថ្ងៃអនាគត។ ក្រៅពីនេះលោកទាំងពីរបានទូន្មានអប់រំកូនឱ្យខិតខំរៀនសូត្រដើម្បីក្លាយជា កូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អ នៅក្នុងសង្គម និងចៀសវាង នូវអំពើមិនល្អទាំងឡាយទាំងពួងនៅក្នុងសង្គម។ យើងខ្ញុំទាំងពីរនាក់ មិនអាចបំភ្លេចបាននូវគុណូបការៈ ដ៏ថ្លៃថ្លា និងធំធេងមិនអាចកាត់ថ្លៃបានឡើយ។ យើងខ្ញុំទាំងពីរនាក់ មានតែប្រមាមដៃដប់លើកបន់ស្រន់ ដល់វត្ថុស័ក្តិសិទ្ធិឱ្យជួយតាមថែរក្សាលោកទាំងទ្វេ ហើយយើងខ្ញុំនឹងតបស្នងសងគុណលោកទាំងពីរដោយការដឹងគុណរៀងរហូតអស់មួយជីវិត។

យើងខ្ញុំទាំងពីរនាក់ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ខ្មែរ និងបរទេសទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំបង្ហាត់បង្រៀន ផ្តល់នូវចំណេះដឹងដល់យើងខ្ញុំចាប់តាំងពីឆ្នាំទី១ រហូតដល់ឆ្នាំទី៤។ ជាពិសេសយើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **បណ្ឌិត អ៊ុន សភក្កដា** ដែលជាសាស្ត្រាចារ្យទទួលបន្ទុកណែនាំសារណា ដែលលោកបានលះបង់នូវពេលវេលាដ៏មានតម្លៃ និងខិតខំអស់ពីកម្លាំងកាយចិត្ត ព្រមទាំងយកចិត្តទុកដាក់ក្នុងការពន្យល់ណែនាំចង្អុលបង្ហាញឱ្យយើងខ្ញុំអាចសម្រេចកិច្ចការនេះប្រកបដោយជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ ដល់ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឱ្យមានសុខភាពល្អ និងទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# អារម្ភកថា

បន្ទាប់ពីឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈរយៈពេល៤ឆ្នាំ ចាប់ពីឆ្នាំ២០១៧ ដល់ ២០២១ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី១៤ ក្រុម $P_4C_1$ យើងខ្ញុំទាំងពីរ បានទទួលនូវចំណេះដឹងក៏ដូចជាបទពិសោធន៍ជាច្រើនទាំងមុខជំនាញ ព្រមទាំងចំណេះដឹងផ្នែកសង្គមផងដែរ ពីសំណាក់លោកគ្រូ និងអ្នកគ្រូសាស្ត្រាចារ្យទាំងអស់ ដែលបានបង្ហាត់បង្រៀនដល់យើងខ្ញុំទាំងអស់គ្នាអស់ពីកម្លាំងកាយ កម្លាំងចិត្តរហូតមកដល់ពេលនេះ ដែលជួយឱ្យយើងខ្ញុំបានទទួលបានលទ្ធផលល្អមកដល់សព្វថ្ងៃនេះ។ ដូច្នេះហើយដើម្បីធ្វើការវាយតម្លៃលើ ចំណេះដឹងរបស់យើងខ្ញុំទាំងពីរនាក់បានលើកយកនូវប្រធានបទមួយស្ដីពី "**ការផ្ដល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់**" មកធ្វើការស្រាវជ្រាវសរសេរសារណាក្នុងការបញ្ចប់នូវការសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំទាំងពីរនាក់។

មូលហេតុដែលយើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តលើកយកប្រធានបទមួយនេះ មកសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយសារតែយើងខ្ញុំយល់ឃើញថា ការផ្ដល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ ជូនដល់ប្រជាពលរដ្ឋ នៅមានកម្រិត និងមានចំណុចខ្វះខាតមួយចំនួនត្រូវកំណែទម្រង់ ហើយចាំបាច់ត្រូវតែបញ្ជ្រាប់ការយល់ដឹង និងផ្សព្វផ្សាយដល់សាធារណៈជន ឱ្យបានជ្រាបកាន់តែច្បាស់ពីសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់។

ម៉្យាងវិញទៀតយើងបានសង្កេតឃើញថាឯកសារដែលយើងបានពីការសរសេរនេះនឹងអាចក្លាយជាបច្ច័យមួយសម្រាប់កិច្ចការស្រាវជ្រាវដែលលោកសាស្ត្រាចារ្យបានដាក់ឱ្យ ឬយកទៅធ្វើជាឯកសារដើម្បីអានសម្រាប់ពង្រីកនូវចំណេះដឹងបន្ថែមទៀត។ ទន្ទឹមនឹងនេះដែរ រាល់ការលើកយកមកបង្ហាញ និងការបញ្ចេញទស្សនៈនៅក្នុងឯកសារនេះ មុខជានឹងមានការខ្វះចន្លោះនៅត្រង់កន្លែងមួយជាក់ជាពុំខានដូច្នេះ ហើយយើងខ្ញុំទាំងពីរនាក់រីករាយនឹងទទួលនូវរាល់ការរិះគន់ទាំងឡាយក្នុងន័យស្ថាបនាពីសំណាក់លោក លោកស្រី បណ្ឌិត សាស្ត្រាចារ្យ បញ្ញាវន្ត និងប្រជាជនទូទាំងប្រទេសដើម្បី ជាបទពិសោធន៍ និងជួយឱ្យយើងខ្ញុំអភិវឌ្ឍន៍ និងកែប្រែនូវរាល់កំហុសដែលខ្វះខាតទាំងប៉ុន្មានឱ្យបានល្អប្រសើរឡើងវិញ និងមានភាពពេញលេញ។

# មាតិកា


**ទំព័រ**

**សេចក្ដីផ្ដើម** ........................................................................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅចំពោះការផ្ដល់សេវាសាធារណៈ នៃរដ្ឋបាលឃុំ សង្កាត់**

**១.១. ទិដ្ឋភាពទូទៅនៃការផ្ដល់សាធារណៈនៃរដ្ឋបាលឃុំ សង្កាត់** ........................ ៥

**១.១.១. ការកកើតសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់** ........................................ ៥

១.១.១.១. និយមន័យ ........................................................................ ៥

១.១.១.២. សារតា ........................................................................ ៧

១.១.១.៣. បច្ចុប្បន្នភាព ........................................................................ ៨

១.១.១.៤. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ ........................ ៩

**១.១.២. សញ្ញាណនៃសេវាសាធារណៈ** ........................................................ ១០

១.១.២.១. សេវាសាធារណៈភ្ជាប់ជាមួយអង្គការ ........................................ ១០

១.១.២.២. ការធ្វើសកម្មភាពដើម្បីជាប្រយោជន៍សាធារណៈ ........................................ ១១

១.១.២.៣. ចរឹកលក្ខណៈនៃសេវាសាធារណៈ ........................................ ១២

១.១.២.៤. អត្ថិភាពនៃសេវាសាធារណៈ ........................................ ១២

**១.២. ការរៀបចំ និងការប្រព្រឹត្តទៅនៃសេវាសាធារណៈនៃរដ្ឋបាលឃុំសង្កាត់** ........... ១៨

**១.២.១. ការបង្កើត និងការរៀបចំសេវាសាធារណៈ** ........................................ ១៨

១.២.១.១. ការបង្កើតសេវាសាធារណៈ ........................................ ១៩

១.២.១.២. ការរៀបចំសេវាសាធារណៈ ........................................ ២០

**១.២.២. គោលការណ៍គ្រឹះ នៃសេវាសាធារណៈ** ........................................ ២០

១.២.២.១. គោលការណ៍និរន្តរភាពនៃសេវាសាធារណៈ ........................................ ២០

១.២.២.២. គោលការណ៍កែតម្រូវ នៃសេវាសាធារណៈ ........................................ ២១

១.២.២.៣. គោលការណ៍សមភាព នៃសេវាសាធារណៈ ........................................ ២១

## ជំពូកទី២

## ការផ្ដល់សេវាសាធារណៈនៃរដ្ឋបាល ឃុំ សង្កាត់

**២.១. ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់** ........ ២២

**២.១.១. ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់** ........ ២២

២.១.១.១. ការតាមដាន ការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍........ ២៦

២.១.១.២. ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ សង្កាត់ ........ ២៩

**២.១.២. តួនាទី និងភារកិច្ចរបស់អង្គភាពទទួលបន្ទុក** ........ ៣០

២.១.២.១. ក្នុងឋានៈតំណាងឱ្យរាស្ត្រប្រជា........ ៣០

២.១.២.២. ក្នុងឋានៈតំណាងឱ្យរដ្ឋ ........ ៣១

**២.១.៣. ការត្រួតពិនិត្យ លើរដ្ឋបាលឃុំ សង្កាត់** ........ ៣១

២.១.៣.១. ការត្រួតពិនិត្យលើអង្គការឃុំ សង្កាត់........ ៣១

២.១.៣.២. ការត្រួតពិនិត្យលើសេចក្ដីសម្រេច ........ ៣១

**២.២. នីតិវិធីចំពោះការងារអត្រានុកូលដ្ឋាននៃរដ្ឋបាលឃុំ សង្កាត់** ........ ៣២

**២.២.១. នីតិវិធីរដ្ឋបាលមន្ត្រីមានសមត្ថកិច្ចនៃរដ្ឋបាលឃុំ សង្កាត់** ........ ៣២

២.២.១.១. មេឃុំ ចៅសង្កាត់........ ៣២

២.២.១.២. ជំទប់ ឬមេឃុំចៅសង្កាត់រង ........ ៣២

២.២.១.៣. ការងារអត្រានុកូលដ្ឋាន ........ ៣៣

២.២.១.៤. អត្រានុកូលដ្ឋានកំណើត ........ ៣៤

២.២.១.៥. អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ........ ៣៨

២.២.១.៦. ការងារអត្រានុកូលដ្ឋានមរណភាព ........ ៤៤

**២.២.២. បញ្ហាប្រឈម** ........ ៣២

២.២.២.១. បញ្ហាប្រឈមក្នុងការអនុវត្តតួនាទី........ ៥០

២.២.២.២. បញ្ហាប្រឈមចំពោះហិរញ្ញវត្ថុសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់........ ៤៤

**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៥២
**អនុសាសន៍** ........................................................................................................ ៥៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសចំណាស់មួយដែលបានឆ្លងកាត់របបដឹកនាំជាច្រើនរបប បើគិតចាប់តាំងពីឆ្នាំ១៨៦៣ មកម្ល៉េះ ដែលរបបដឹកនាំទាំងនោះមានដូចជា របបអាណានិគមនិយមបារាំង(១៨៦៣-១៩៥៣) របបសង្គមរាស្ត្រនិយម(១៩៥៣-១៩៧០) របបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥) របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) របបសាធារណរដ្ឋប្រជាមានិតកម្ពុជា(១៩៧៩-១៩៨៩) របបរដ្ឋកម្ពុជា(១៩៨៩-១៩៩៣) និងរបបព្រះរាជាណាចក្រកម្ពុជាទី២(១៩៩៣-បច្ចុប្បន្ន)។ បន្ទាប់ពីឆ្លងកាត់ជាច្រើនរបបដឹកនាំ និងសង្គ្រាមរ៉ាំរ៉ៃជាច្រើនឆ្នាំដែលបណ្តាលឱ្យប្រទេសកម្ពុជាខូចខាតហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច បាត់បង់ធនធានមនុស្ស ប្រទេសកម្ពុជាក៏ចាប់ផ្តើមកែប្រែខ្លួន និងព្យាយាមសិក្សាពីប្រទេសដទៃទៀតមកក្លាយជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ មានសុខសន្តិភាព ស្ថេរភាព សន្តិសុខ សណ្តាប់ធ្នាប់ ការគោរពសិទ្ធិសេរីភាព ព្រមទាំងមានការរីកឡើងនៅកំណើនសេដ្ឋកិច្ច និងប្រជាជនផងដែរ។

សព្វថ្ងៃនេះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាបាននឹងកំពុងយកចិត្តទុកដាក់ទៅលើគ្រប់វិស័យ ដូចជាកសិកម្ម ការនេសាទ ជំនួយការអភិវឌ្ឍ គ្រោះមហន្តរាយ និងការឆ្លើយតបក្នុងគ្រាអាសន្ន សេដ្ឋកិច្ច ពាណិជ្ជកម្ម ថាមពល បរិស្ថាន និងធនធានធម្មជាតិ ឧស្សាហកម្មនិស្សារណកម្ម ហេដ្ឋារចនាសម្ព័ន្ធ ពលកម្ម ដីធ្លី ច្បាប់ និងប្រព័ន្ធតុលាការ ប្រជាជន និងជំរឿន វិទ្យាសាស្ត្រ បច្ចេកវិទ្យា ការអភិវឌ្ឍសង្គម គោលដៅអភិវឌ្ឍន៍ប្រកបចីរភាព ការអភិវឌ្ឍ និងការគ្រប់គ្រងទីក្រុង។ ការអភិវឌ្ឍគ្រប់វិស័យពីមួយដំណាក់កាលទៅមួយដំណាក់កាលនៃការកសាងប្រទេសជាតិ គឺមានការចម្រើនយ៉ាងរលូន ក្នុងនោះផងដែរវិស័យសាធារណៈ ក៏ជាវិស័យដែលរាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់ពាក់ព័ន្ធទៅនឹងការផ្តល់សេវាសាធារណៈ ក្នុងគោលបំណងជាជំនួយឱ្យសេវាសាធារណៈមានភាពទាក់ទាញយ៉ាងជិតស្និតជាមួយប្រជាពលរដ្ឋ។ ក្នុងពេលបច្ចុប្បន្ននេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការសិក្សាទៅលើតម្រូវការខ្វះខាតរបស់ សាធារណៈដើម្បីបំពេញនូវតម្រូវការចាំបាច់ និងភាពងាយស្រួលដល់អ្នកផ្តល់សេវាបម្រើឱ្យប្រជាពលរដ្ឋកាន់តែមានជំនឿទុកចិត្ត និងរីករាយក្នុងការទទួលបាននូវសេវាសាធារណៈពីអង្គភាពទទួលបន្ទុក ដែលស្ថិតក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល។

ទន្ទឹមនឹងនេះដើម្បីឱ្យមានការយល់ច្បាស់ទាក់ទងទៅហ្នឹងការផ្តល់សេវាសាធារណៈ នៃរដ្ឋបាលសាធារណៈ រាជរដ្ឋាបាលបានបង្កើតច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១ ដែលក្នុងនោះក៏បានចែងយ៉ាងលម្អិតអំពីការផ្តល់សេវាសាធារណៈ នៃរដ្ឋបាលឃុំ សង្កាត់ ផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ៖

នៅក្នុងការជ្រើសរើសយកប្រធានបទ "**ការផ្តល់សេវាសាធារណៈ នៃរដ្ឋបាលឃុំ សង្កាត់**" គឺដើម្បីយកមកសិក្សាស្វែងយល់ថា តើសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ មានសារៈសំខាន់ និងអត្ថប្រយោជន៍បែបណាខ្លះចំពោះប្រជាពលរដ្ឋ និងសង្គមជាតិ? តើប្រភេទ នៃសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់មានអ្វីខ្លះ? តើការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ មានការរៀបចំ និងការប្រព្រឹត្តិទៅយ៉ាងដូចម្តេច? តើមានចំណុចខ្វះខាតអ្វីខ្លះដែលត្រូវកែប្រែទៅលើសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ក្រោយពីបានធ្វើការស្រាវជ្រាវស្វែងយល់ទៅលើសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ រួចមកចំពោះគោលបំណងនៃការស្រាវជ្រាវប្រធានបទនេះ គឺយើងខ្ញុំចង់សិក្សាឱ្យកាន់តែច្បាស់ពីប្រភេទនៃសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ និងជាពិសេសដើម្បីស្វែងយល់អំពីដំណើរការទូទៅចំពោះនីតិវិធីនៃការផ្តល់ជូន និងបម្រើសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋនូវគុណប្រយោជន៍របស់សេវាសាធារណៈចំណុចខ្វះខាត និងការបំពេញបន្ថែមឱ្យកាន់តែមានភាពល្អប្រសើរទៅលើការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ៖

ការសិក្សាស្រាវជ្រាវ "**ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់**" គឺជាការសិក្សាស្វែងយល់ពីការផ្តល់សេវាសាធារណៈ នៃរដ្ឋបាលឃុំ សង្កាត់ ទៅដល់ប្រជាពលរដ្ឋគ្រប់រូប (អ្នកទទួលសេវា)។ ទំហំនៃការស្រាវជ្រាវនោះ គឺអនុលោមទៅតាមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១ អនុក្រឹត្យស្តីពី ការកែសម្រួល អនុក្រឹត្យស្តីពី អត្រានុកូលដ្ឋាន ឆ្នាំ២០០៣ គោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈរាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៦ ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត និងបណ្តាប្រព័ន្ធផ្សព្វផ្សាយនានាតាមប្រព័ន្ធអ៊ីនធឺណេតជាច្រើនផ្សេងទៀត។ វិសាលភាព នៃការស្រាវជ្រាវសារណាមួយច្បាប់នេះ យើងខ្ញុំបានផ្តោតសំខាន់ទៅលើការសិក្សាស្វែងយល់អំពីប្រភេទ និងនីតិវិធីក្នុងការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ និងសារៈសំខាន់របស់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ សម្រាប់បម្រើប្រយោជន៍សាធារណៈ ប្រជាជន និងសង្គមជាតិឱ្យទទួលបានសណ្តាប់ធ្នាប់ល្អ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ៖

ក្នុងការសិក្សាស្វែងយល់ប្រធានបទនេះពិតជាមានសារៈសំខាន់ និងមានគុណតម្លៃយ៉ាងក្រៃលែងព្រោះប្រធានបទនេះបានបង្ហាញឱ្យយើងបានស្វែងយល់បន្ថែមទាក់ទងទៅហ្នឹងការគ្រប់គ្រង និងនីតិវិធីក្នុងការផ្តល់សេវាសាធារណៈជូនដល់ប្រជាជនគ្រប់រូប គ្រប់វណ្ណៈនៅក្នុងប្រទេសកម្ពុជា។

យ៉ាងណាមិញប្រទេសកម្ពុជា ជាប្រទេសដែលកំពុងអភិវឌ្ឍ និងមានការរីកចម្រើន ប៉ុន្តែយើងចាំបាច់ត្រូវតែមានការគ្រប់គ្រងទៅលើសេវាសាធារណៈឱ្យមានភាពច្បាស់លាស់ និងតម្លាភាព គឺដើម្បីជាផ្លូវបង្ហាញឱ្យប្រជាពលរដ្ឋយល់ដឹងពីតម្លៃ នៃសេវាសាធារណៈ ជាពិសេសអគ្រានុកូលដ្ឋាន។ មួយវិញទៀតការបណ្តុះបណ្តាលពង្រឹង និងត្រួតពិនិត្យ ទៅលើដំណើរការប្រព្រឹត្តទៅនៃកិច្ចការសេវាសាធារណៈរដ្ឋបាលឃុំ សង្កាត់ ក៏ជាផ្នែកដ៏សំខាន់ក្នុងការសិក្សាទៅលើទិន្នន័យសរុប នៃចំនួនប្រជាជនទាំងអស់នៅប្រទេសកម្ពុជា ដូចជាការយល់ដឹងពីសន្ទុះរបស់ប្រជាជនទាំងកំណើន និងការថយចុះបន្ថែមមកវិញទៀតយើងបានស្វែងយល់ និងទទួលបានព័ត៌មានជាក់លាក់អំពីជីវភាពនៃការរស់រៀនរបស់ប្រជាជននៅទូទាំងប្រទេសកម្ពុជា។ ហេតុនេះហើយទើបការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ ជាផ្នែកមួយជំរុញឱ្យរដ្ឋាភិបាលមានភាពងាយស្រួលក្នុងការរៀបចំ និងការដាក់ចេញនូវគោលនយោបាយថ្មីៗ ដែលជាដំណោះស្រាយចំគោលដៅទៅនឹងបញ្ហាដែលប្រជាពលរដ្ឋបានជួបជាក់ស្តែង និងមានការផ្តល់សេវាទាន់ពេលវេលាហើយជួយបង្កើនដល់ជីវភាពសហគមន៍មានភាពធូរធារ និងមានការអភិវឌ្ឍគ្រប់វិស័យ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្វែងយល់ទៅលើប្រធានបទនេះ គឺយើងផ្តោតសំខាន់ទៅលើប្រភេទសេវា នីតិវិធី និងការអភិវឌ្ឍចំពោះការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ ឱ្យកាន់តែមានភាពងាយស្រួល និងចំគោលដៅទៅលើបញ្ហា ឬតម្រូវការពីអ្នកទទួលសេវាឱ្យកាន់តែមានការពេញចិត្តក្នុងការប្រើប្រាស់សេវា។ ក្នុងការស្រាវជ្រាវនេះបានប្រើវិធីសាស្ត្រដោយពឹងផ្អែកទាំងស្រុងទៅលើច្បាប់ គោលនយោបាយ សេចក្តីណែនាំ សៀវភៅណែនាំផ្សេងៗទៀតជាគោលក្នុងការស្រាវជ្រាវ សរសេរ និងបង្កើតបានជាស្នាដៃថ្មីមួយដែលផ្តោតយ៉ាងសំខាន់ទៅលើ"**ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់**"។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ៖

ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានការជោគជ័យ និងមានលទ្ធផលល្អហើយមាននូវគុណភាពខ្ពស់ស្របតាមស្តង់ដា នៃការស្រាវជ្រាវ មានរចនាបថងាយស្រួលសម្រាប់អ្នកអាន។ បន្ថែមមកទៀតការស្រាវជ្រាវក៏បានរៀបចំនូវរចនាសម្ព័ន្ធ នៃការស្រាវជ្រាវឱ្យមានភាពជាក់លាក់ ច្បាស់លាស់ ដើម្បីឱ្យការស្រាវជ្រាវនេះមានលក្ខណៈពេញលេញ។ កិច្ចការស្រាវជ្រាវនេះមានពីរផ្នែកសំខាន់ៗ៖

- **ជំពូកទី១ "សញ្ញាណទូទៅចំពោះការផ្តល់សេវាសាធារណៈ នៃរដ្ឋបាលឃុំ សង្កាត់"**៖ នៅក្នុងជំពូកនេះយើងខ្ញុំនឹងបែងចែកជាពីរចំណុចបន្ថែមទៀតដោយចំណុចទី១ និយាយអំពីទិដ្ឋភាពទូទៅនៃការផ្តល់សេវាសាធារណៈ និងចំណុចទី២ បង្ហាញអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃសេវាសាធារណៈរបស់រដ្ឋបាលឃុំ សង្កាត់។

❖ **ជំពូកទី២ "ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់"៖** នៅក្នុងជំពូកនេះយើងខ្ញុំនឹងបែងចែកជាពីរចំណុចបន្ថែមទៀត ដោយចំណុចទី១ និយាយអំពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងចំណុចទី២ និយាយអំពីនីតិវិធីចំពោះការងារអត្រានុកូលដ្ឋាន នៃរដ្ឋបាលឃុំ សង្កាត់។

# ជំពូកទី១
# សញ្ញាណទូទៅចំពោះការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់

# ជំពូកទី១
# សញ្ញាណទូទៅចំពោះការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់

## ១.១. ទិដ្ឋភាពទូទៅនៃការផ្តល់សាធារណៈនៃរដ្ឋបាលឃុំ សង្កាត់

នៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលនៃយើងបាននឹងកំពុងតែអនុវត្តនូវគោលនយោបាយដ៏សំខាន់មួយនោះគឺ គោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ សម្រាប់ជូនដល់បងប្អូនប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង ជាពិសេសគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលសាធារណៈត្រូវតែបានពង្រឹងដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរ

### ១.១.១. ការកកើតសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់

ការកកើតសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ គឺត្រូវបានបង្កើតឡើងដោយច្បាប់ និងបទបញ្ញា។ ចំពោះការកកើតឡើងនេះ ការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាកាលពីនីតិកាលទី៣នៃរដ្ឋសភា បានផ្តោតសំខាន់ និងយកចិត្តទុកដាក់លើវិស័យអាទិភាពចំនួន៤ ដើម្បីផ្តល់ជាសេវាសាធារណៈដល់ប្រជាពលរដ្ឋ ដែលស្ថិតក្នុងយុទ្ធសាស្ត្រចតុកោណ ហើយសេវាអាទិភាពទាំង៤ នោះមានដូចជា សេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរបស់រដ្ឋ សេវាពាក់ព័ន្ធនឹងការវិនិយោគ សេវាពាក់ព័ន្ធនឹងមូលដ្ឋាន និងសេវាពាក់ព័ន្ធហ្នឹងហិរញ្ញវត្ថុសាធារណៈ ក៏ប៉ុន្តែវិស័យដែលពាក់ព័ន្ធនឹងសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ នោះគឺសេវាអធិបតេយ្យភាពរបស់រដ្ឋ ដែលមានដូចជា សេវាអត្រានុកូលដ្ឋាន លិខិតអនុញ្ញាត និងបណ្ណកម្មសិទ្ធិដីធ្លី។ ចំពោះសេវាអត្រានុកូលដ្ឋាននេះហើយដែលស្ថិតក្នុងចង្កោមសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ គឺសំដៅលើស្ថានភាពបី គឺកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។

#### ១.១.១.១. និយមន័យ

ជាធម្មតាសេវាសាធារណៈត្រូវបានគេឱ្យនិយមន័យខុសៗគ្នាជាច្រើនដែលនិយមន័យទាំងនោះ រួមមាន និយមន័យតាមន័យទូទៅ និយមន័យតាមន័យអង្គការ និយមន័យតាមន័យខ្លឹមសារ និយមន័យតាមន័យគតិយុត្ត និយមន័យតាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ និងនិយមន័យនៃការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់។

**ក. និយមន័យតាមន័យទូទៅ**

សេវាសាធារណៈនៃអត្ថន័យទូទៅ គឺសកម្មភាពដែលមានគោលដៅបំពេញសេចក្តីត្រូវការនៃផលប្រយោជន៍ទូទៅនិងដែលគ្រប់គ្រងដោយរបបគតិយុត្ត ដែលជានីតិសាធារណៈ។[1]

សេវាសាធារណៈ គឺជាសេវាកម្មដែលបានផ្តល់ដោយរដ្ឋាភិបាលទៅកាន់ប្រជាជនដែលរស់នៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួនដោយផ្ទាល់ (តាមរយៈវិស័យសាធារណៈ) ឬដោយការផ្តល់ជាហិរញ្ញវត្ថុដល់ផ្នែកឯកជនក្នុងការផ្គត់ផ្គង់សេវានោះ។ រួមមកគឺបង្កើតសេវាសាធារណៈដើម្បីបំពេញតម្រូវការប្រជាជនគ្រប់រូបស្មើៗភាពគ្នា និងមិនគិតពីការចំណេញ(Non-profit)។[2]

---

[1] សាស្ត្រាចារ្យ ខាំ សុមករា៖ រដ្ឋបាលសាធារណៈ ឆ្នាំ២០១៣ ទំព័រទី៧៦

[2] ដកស្រង់ចេញពីគេហទំព័រ https://www.sciencedaily.com/terms/public_services.htm
ចូលមើលថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១

**ខ. និយមន័យតាមន័យអង្គការ**

សេវាសាធារណៈ គឺជាស្ថាប័ន អង្គភាព ឬនីតិបុគ្គលសាធារណៈ ដាក់នូវ មន្ត្រីរាជការ បុគ្គលិក និង មធ្យោបាយនានា មកបម្រើការងារបម្រើប្រយោជន៍សាធារណៈរដ្ឋ និងសកម្មភាពវិមជ្ឈការ ដែលអាចបង្កើតនូវ សេវាសាធារណៈបានដោយខ្លួនឯង។ នេះគេហៅថាការឱ្យនិយមន័យតាមលក្ខណៈ "អង្គការ របស់ក្រសួង" នៃ អង្គការរដ្ឋ និងអង្គការវិមជ្ឈការ " ដែលភាគច្រើនសំដៅទៅលើក្រសួង" ឬ"មន្ទីរ"។[3]

**គ. និយមន័យតាមន័យខ្លឹមសារ**

សេវាសាធារណៈ ក្នុងន័យខ្លឹមសារ គឺជាសកម្មភាពបម្រើប្រយោជន៍ទូទៅដែលរាជការជាអ្នកទទួល បន្ទុក(រដ្ឋាការ) ឬសកម្មភាពមួយចំនួនរដ្ឋប្រគល់ឱ្យឯកជនកាន់កាប់ គ្រាន់តែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ រដ្ឋ(សម្បទានសេវាសាធារណៈ)។[4]

**ឃ. និយមន័យតាមន័យគតិយុត្ត**

តាមន័យគតិយុត្ត សេវាសាធារណៈ គឺជាសកម្មភាព របស់រាជការដែលនៅក្នុងរបបគតិយុត្តមួយខុសពី នីតិរួម ពោលនីតិរដ្ឋបាលតែម្តង[5] ឬជារូបភាពមួយនៃអំពើរបស់រាជការ ដែលនៅក្នុងនោះនីតិបុគ្គលសាធារណៈ ទទួលភារកិច្ចបំពេញតម្រូវការនៃប្រយោជន៍ទូទៅ។

**ង. និយមន័យតាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ**

តាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ បានកំណត់អំពីនិយមន័យនៃ សេវាសាធារណៈ ថា៖ រាល់សកម្មភាពទាំងឡាយណា ដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ចក្នុង គោលដៅបម្រើផលប្រយោជន៍សាធារណៈ គឺជាសេវាសាធារណៈ។

"**ស្ថាប័នមានសមត្ថកិច្ច**" នៅក្នុងន័យនេះ គឺសំដៅដល់ស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ ថ្នាក់ទាំងអស់របស់រដ្ឋ ដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន។

"**ស្ថាប័នទទួលសមត្ថកិច្ច**" នៅក្នុងន័យនេះ គឺសំដៅដល់ផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបាន សិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។ ការគ្រប់គ្រង ការត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋទៅលើផ្នែកឯកជន និងសង្គមស៊ីវិលដែលរដ្ឋបានប្រគល់សិទ្ធិអំណាចឱ្យត្រូវ ធ្វើឡើងផ្អែកលើលក្ខខណ្ឌដូចមានចែងក្នុងសេចក្តីសម្រេចកិច្ចព្រមព្រៀង ឬកិច្ចសន្យាដែលបានប្រគល់ភារកិច្ច ក្នុងរង្វង់ដែនសមត្ថកិច្ចមួយយ៉ាងច្បាស់លាស់ និងពិនិត្យទៅលើសកម្មភាពការងារលទ្ធផលដែលសម្រេចបាននូវ គោលដៅទៅអនាគត និងផលប៉ះពាល់ផ្សេងៗជាយថាហេតុ ដែលអាចកើតមានចំពោះសង្គមជាតិ។[6]

[3] សាស្ត្រាចារ្យសាយ បូរី៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ភ្នំពេញ ឆ្នាំ២០០២ ទំព័រទី៤០៣

[4] សាស្ត្រាចារ្យសាយ បូរី៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ភ្នំពេញ ឆ្នាំ២០០២ ទំព័រទី៤០៣

[5] សាស្ត្រាចារ្យ ហៀង សាង៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៤ ឆ្នាំ២០១៧ ទំព័រ២២

[6] គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ថ្ងៃទី៥ ឧសភា ២០០៦

**ច. និយមន័យនៃការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់**

ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ គឺជាយន្តការដែលសេវាកម្មសាធារណៈត្រូវចាំបាច់ផ្តល់ជូនសាធារណៈជនដោយរដ្ឋបាលឃុំ សង្កាត់។

ឧទាហរណ៍៖ ការចុះបញ្ជីអត្រានុកូលដ្ឋាន ដូចជាសំបុត្រកំណើត អត្តសញ្ញាណបណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ជាដើម និងធ្វើលិខិតបញ្ជាក់នៅលីវ មេម៉ាយ លិខិតយល់ព្រមដើម្បីរៀបចំកម្មវិធីសង្គម និងបុណ្យទាននានា។

**១.១.១.២. សាវតា**

ជាប្រវត្តិសាស្ត្រ ការរីករាលដាល នៃការផ្តល់សេវាសាធារណៈ នៅក្នុងប្រទេសអភិវឌ្ឍន៍ ជាធម្មតាចាប់ផ្តើមនៅចុងសតវត្សរ៍ទី១៩ ជាមួយនឹងការអភិវឌ្ឍសេវាកម្មឧស្ម័ន និងទឹកក្រុង។ ក្រោយមកសេវាកម្មផ្សេងទៀតដូចជាអគ្គិសនី និងថែទាំសុខភាព បានចាប់ផ្តើមត្រូវបានផ្តល់ដោយរដ្ឋាភិបាល។ នៅក្នុងប្រទេសអភិវឌ្ឍន៍ភាគច្រើនសេវាកម្មបែបនេះនៅតែត្រូវបានផ្តល់ដោយរដ្ឋាភិបាលក្នុងតំបន់ ឬថ្នាក់ជាតិ គឺមានលើកលែងតែចំពោះសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ដែលការផ្តល់ឱ្យបុគ្គលឯកជន មានសារៈសំខាន់ជាង។ ទោះយ៉ាងណាក៏ដោយសេវាកម្មសាធារណៈដែលផ្តល់ដោយបុគ្គលឯកជនបែបនេះច្រើនតែត្រូវបានកំណត់យ៉ាងតឹងរឹង។ ដូចជាឧទាហរណ៍នៅសហរដ្ឋអាមេរិក ដោយគណៈកម្មការឧបករណ៍សាធារណៈ។ ចំណែកឯនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍សេវាកម្មសាធារណៈមាននិន្នាការមិនសូវត្រូវបានអភិវឌ្ឍន៍ច្រើនទេ។ ឧទាហរណ៍៖ សេវាកម្មទឹកអាចមានតែសម្រាប់វណ្ណៈកណ្តាលអ្នកមានប៉ុណ្ណោះ។ សម្រាប់ហេតុផលនយោបាយសេវាកម្ម ត្រូវបានឧបត្ថម្ភធនធានជារឿយៗដែលកាត់បន្ថយហិរញ្ញវត្ថុ ដែលមានសម្រាប់ពង្រីក ដល់សហគមន៍ក្រីក្រ។

ចាប់តាំងពីទសវត្សឆ្នាំ១៩៩០ ប្រទេសកម្ពុជា បានកត់សំគាល់នូវកំណើន គួរឱ្យចាប់អារម្មណ៍ប៉ុន្តែការអភិវឌ្ឍនេះ មិនស្មើគ្នាទេ ជាមួយនឹងវិសមភាពក្នុងតំបន់ ការទទួលបាន និងគុណភាព នៃសេវាសាធារណៈ។ ប្រជាជនក្រីក្រជាង៩០% រស់នៅក្នុងតំបន់ជនបទមានតែ៣៧% នៃប្រជាជននៅតាមជនបទប៉ុណ្ណោះដែលមានអនាម័យហើយ៤៨% នៃប្រជាជននៅតាមជនបទមានទឹកស្អាតប្រើប្រាស់។[7]

ជាក់ស្តែង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានកំណត់ពីសេវាសាធារណៈថ្នាក់ជាតិនៅក្នុងជំពូកទី៣ និយាយអំពីសិទ្ធិ និងករណីកិច្ចរបស់ ប្រជាពលរដ្ឋខ្មែរ ជំពូកទី៥ និយាយអំពីសេដ្ឋកិច្ច និងជំពូកទី៦ និយាយអំពីអប់រំ វប្បធម៌ និងសង្គមកិច្ច។ សេវាសាធារណៈមូលដ្ឋាន ជាទូទៅសំដៅទៅលើសេវាទាំងឡាយណាដែលមានចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាក់ស្តែងសម្រាប់កម្ពុជាសេវាប្រភេទនេះ មានកំណត់នៅក្នុង ច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលឃុំ សង្កាត់ ដូចជា សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន ការអភិវឌ្ឍមូលដ្ឋាន អនាម័យ សុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ការធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈជាពិសេសការងារអត្រានុកូលដ្ឋាន។

[7] ដកស្រង់ចេញពីគេហទំព័រ https://www.worldbank.org/en/news/feature/2017/02/09/enhancing-the-quality-of-public-service-delivery-in-cambodia ចូលមើលថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១

### ១.១.១.៣. បច្ចុប្បន្នភាព

រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកការកែលម្អការផ្តល់សេវា គឺជាអាទិភាពចម្បងមួយរបស់ខ្លួន។ ការកែលម្អការផ្តល់សេវាកម្ម គឺស្ថិតនៅចំណុចប្រសព្វ នៃកំណែទម្រង់ចំនួនបី ដែលកំពុងត្រូវបានអនុវត្តនៅក្នុងប្រទេស។ ទីមួយ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) ដែលសំដៅទៅលើ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺមានគោលបំណងដើម្បីនាំមកនូវការសម្រេចចិត្តកាន់តែជិតស្និទ្ធជាមួយពលរដ្ឋដែលប្រើប្រាស់សេវាកម្មសាធារណៈ។ ទីពីរ កំណែទម្រង់រដ្ឋបាលសាធារណៈ (PAR) នឹងផ្តល់នូវរចនាសម្ព័ន្ធគ្រប់គ្រង និងជាការលើកទឹកចិត្តត្រឹមត្រូវសម្រាប់អ្នកផ្តល់សេវាកម្ម។[8] ជាចុងក្រោយកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM)។ សូចនាករនៃគុណភាពសេវាចំនួនប្រាំដែលរាជរដ្ឋាភិបាលបានកំណត់ គឺរួមមានដូចជាគុណភាពព័ត៌មានភាពងាយស្រួលក្នុងការទទួលយកសេវាភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា សេវាផ្តល់តាមគោលការណ៍កំណត់មានអភិបាលកិច្ចល្អ និងយន្តការព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា។ នៅក្នុងឯកសារគោលនយោបាយ ស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុម័តដោយសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រីនាថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ វាក្យសព្ទសេវាសាធារណៈ ត្រូវបានកំណត់និយមន័យថា រាល់សកម្មភាពទាំងឡាយ ដែលធ្វើឡើងដោយ ស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នទទួលសមត្ថកិច្ច ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។ ស្ថាប័នមានសមត្ថកិច្ច សំដៅដល់ស្ថាប័នរដ្ឋ ភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋដែលបំពេញការងារទៅតាមសមត្ថកិច្ចរបស់ខ្លួន។ ស្ថាប័នទទួលសមត្ថកិច្ច សំដៅដល់ ផ្នែកឯកជន និងសង្គមស៊ីវិល ដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយស្ថិតនៅក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់រដ្ឋ ឬភាក់ងាររដ្ឋ។

ក្នុងគោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈរបស់កម្ពុជា សេវាសាធារណៈត្រូវបានបែងចែកជាប្រាំពីរចង្កោមធំៗនោះ គឺចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និងមធ្យម បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ ចង្កោមសេវាសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូលការធ្វើវិចារណកម្មចំណាយ និងការបើកផ្តល់។

នីតិវិធីនៃការទទួលសេវាសាធារណៈនឹងត្រូវបានសម្រួល និងធ្វើឱ្យមានភាពសាមញ្ញតាមរយៈការលប់បំបាត់ការងារដែលជាន់គ្នា ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តន៍គោលនយោបាយវិសហមជ្ឈការ វិមជ្ឈការបច្ចេកទេស វិមជ្ឈការថ្នាក់ឃុំ សង្កាត់ យន្តការ «ច្រកចេញចូលតែមួយ» ព្រមទាំងបង្កើតការិយាល័យប្រជាពលរដ្ឋថ្វីត្បិតតែការងាររបស់រាជរដ្ឋាភិបាលអាណត្តិទី៣ ទទួលបានលទ្ធផលគួរជាទីមោទនភាពក៏ដោយ ប៉ុន្តែសម្រាប់នីតិកាលទី៤ នៃរដ្ឋសភានេះរាជរដ្ឋាភិបាលកម្ពុជា នៅមានបេសកកម្មដោយ បន្តអនុវត្តគោលនយោបាយ ដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណ ក្នុងគោលដៅពង្រឹងគុណភាព ប្រសិទ្ធភាពនៃសេវាសាធារណៈនៅតាម

---

[8] ដកស្រង់ចេញពីគេហទំព័រ https://www.worldbank.org/en/news/feature/2017/02/09/enhancing-the-quality-of-public-service-delivery-in-cambodia ចូលមើលថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២១

មូលដ្ឋានក្រោមឈ្មោះជាផ្លូវការថា«យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២»។ រាជរដ្ឋាភិបាលកម្ពុជាពិនិត្យឃើញថាមានបញ្ហាប្រឈមជាច្រើនទៀត ជាមួយ និងសេវាសាធារណៈ៖

- ស្ថាប័នតុលាការនៅមិនទាន់ទទួលបាននូវជំនឿទុកចិត្តពេញលេញពីសំណាក់មហាជននៅឡើយ
- ការផ្តល់សេវាសុខាភិបាលសាធារណៈ ប្រកបដោយគុណភាព នៅមានកម្រិតនៅឡើយ
- កិច្ចការពារសុវត្ថិភាពសង្គម ជាពិសេស សម្រាប់ពលករ និងជនក្រីក្រនៅមិនទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយ
- គុណភាពអប់រំនៅមានកម្រិតទាប ទាំងកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា
- អគ្គីសនី នៅមានថ្លៃខ្ពស់ ធៀបនឹងប្រទេសជិតខាង ប្រព័ន្ធធារាសាស្ត្រ មិនទាន់ត្រូវបានអភិវឌ្ឍគ្រប់គ្រាន់តាមសេចក្តីត្រូវការ។

ជារួម សមត្ថភាពស្ថាប័ន នៅមានកម្រិតទាបនៅឡើយ ដោយសារប្រាក់បៀវត្ស និងការលើកទឹកចិត្តរបស់មន្ត្រីរាជការនៅទាប កិច្ចសហប្រតិបត្តិការអន្តរស្ថាប័ននៅមានកម្រិត លិខិតបទដ្ឋានមួយចំនួន នៅមានចន្លោះប្រហោង និងកង្វះខាតធនធាន ដើម្បីអនុវត្តគោលនយោបាយដែលបានដាក់ចេញ។

បច្ចុប្បន្នគោលដៅយុទ្ធសាស្ត្រ និងវិស័យអាទិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយរាជរដ្ឋាភិបាលបានកំណត់យកគោលដៅយុទ្ធសាស្ត្រទាំង៤ និងវិស័យអាទិភាពទាំង៤ ជាការប្តេជ្ញាចិត្តក្នុងការអនុវត្តបន្តនៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ក្នុងនោះក៏បានចែងយ៉ាងច្បាស់ក្នុងគោលដៅយុទ្ធសាស្ត្រទី៤ បង្ហាញពីសេវាសាធារណៈ គឺការបន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានានូវប្រសិទ្ធភាពនិងសក្តិសិទ្ធភាព នៃសេវាសាធារណៈសំដៅ បម្រើប្រជាជនឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និងបរិស្ថានអំណោយផល។[9]

**១.១.១.៤. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ**

ចំពោះការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈរាជរដ្ឋាភិបាលបានកំណត់ទៅលើចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រ ដើម្បីជួយក្នុងការបម្រើទៅដល់ប្រជាពលរដ្ឋ។

- ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍដែលអាចជឿទុកចិត្តបាន សំដៅបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង
- គោលបំណងនៃសេវាសាធារណៈ គឺធ្វើយ៉ាងណាឱ្យសេវាសាធារណៈប្រកបដោយគុណភាពមានភាពសាមញ្ញ ប្រសិទ្ធភាព ភាពអាចជឿទុកចិត្តបាន ភាពឆាប់រហ័ស ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការ មានភាពងាយស្រួល និងមានការចូលរួមពីអ្នកប្រើប្រាស់សេវា
- គោលដៅនៃសេវាសាធារណៈ គឺធានាភាពងាយស្រួលក្នុងការទទួលយកសេវាទៅប្រើប្រាស់ផ្តល់សេវាដែលផ្តោតទៅលើសេចក្តីត្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់សេវា (សេវាតម្រូវការ និងសេវាសំណូមពរ) ផ្តល់សេវាឱ្យចំទីកន្លែងដែលមានសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវាលើកកម្ពស់តម្លាភាព និងការទទួលខុសត្រូវក្នុងការផ្តល់សេវា ហើយកែលម្អគុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវា។

[9] រាជរដ្ឋាភិបាលកម្ពុជា៖ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤

យុទ្ធសាស្ត្រនៃសេវាសាធារណៈគឺ៖

- ជំរុញឱ្យមានការផ្លាស់ប្តូរទស្សនទាន ក្នុងក្របខ័ណ្ឌនៃការផ្តល់សេវាសាធារណៈរបស់មន្ត្រីរាជការពីអ្នកគ្រប់គ្រងទៅជាអ្នកផ្តល់សេវាព្រមទាំងផ្តល់តម្លៃដល់អ្នកប្រើប្រាស់សេវា។
- ជំរុញការកែទម្រង់របៀបរបបការងារពីរចនាសម្ព័ន្ធការងារទៅជារចនាសម្ព័ន្ធប្រតិបត្តិការដោយលើកកម្ពស់គុណភាពសេវាផ្នែកជួរមុខព្រមទាំងបង្កើនសមត្ថភាពផ្នែកទ្រទ្រង់។[10]

### ១.១.២. សញ្ញាណនៃសេវាសាធារណៈ

សញ្ញាណ នៃសេវាសាធារណៈមិនអាចកំណត់បានទេ។ ប៉ុន្តែយើងអាចកំណត់ជាសេវាសាធារណៈភ្ជាប់ជាមួយអង្គការ និងការធ្វើសកម្មភាពដើម្បីជាប្រយោជន៍សាធារណៈ។

#### ១.១.២.១. សេវាសាធារណៈភ្ជាប់ជាមួយអង្គការ

**ក. បុគ្គលសាធារណៈ**

បុគ្គលសាធារណៈ គឺជាអ្នកធានាដោយផ្ទាល់ជាមួយនឹងមធ្យោបាយនានា នៃសកម្មភាពនៅក្នុងការបម្រើ។ ដែលសកម្មភាពទាំងនោះគឺ៖

- **ការផ្តល់ដោយបុគ្គលសាធារណៈផ្ទាល់៖** ជាការផ្តល់សេវាសាធារណៈដោយប្រើប្រាស់បុគ្គលិក ធនធាន មធ្យោបាយ និងថវិការបស់រដ្ឋ។ ការផ្តល់បែបនេះហៅថា "រដ្ឋាករ" ភាគច្រើនគេតែងតែអនុវត្តន៍ចំពោះសេវាអធិបតេយ្យភាពរបស់រដ្ឋ។
- **ប្រតិភូកម្មឱ្យបុគ្គលសាធារណៈ៖** រដ្ឋបានផ្តល់សមត្ថកិច្ចទៅឱ្យគ្រឹះស្ថានជំនាញជាអ្នកផ្តល់សេវាជំនួស ដែលគេអាចហៅបានថាជាការធ្វើវិមជ្ឈការបច្ចេកទេស។ បុគ្គលសាធារណៈនៅទីនេះ សំដៅទៅលើគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ។[11]

**ខ. បុគ្គលឯកជន**

បុគ្គលឯកជន គឺជាការផ្ទេរសកម្មភាពរបស់រាជការនៅក្នុងការបម្រើនេះទៅឱ្យឯកជនគ្រប់គ្រងជំនួសវិញ។ ប្រការនេះគេហៅថា ជាការធ្វើឯកជនភាវូបនីយកម្មលើសេវាសាធារណៈ។[12] ការធ្វើប្រតិភូកម្មឱ្យបុគ្គលឯកជនសេវាសាធារណៈទាំងឡាយណាក្រៅពីសេវាអធិបតេយ្យភាពរបស់រដ្ឋ គឺអាចធ្វើប្រតិភូកម្មឱ្យឯកជនបាន។ ប៉ុន្តែចំពោះសេវាអធិបតេយ្យអាចមិនដូចគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ហើយវាមានលក្ខណៈតិចទៅៗសម្រាប់ប្រទេសអភិវឌ្ឍន៍ ការធ្វើប្រតិភូកម្មឱ្យបុគ្គលឯកជនចាំបាច់ត្រូវមានវិធាន និងទម្រង់នៃប្រតិភូកម្មច្បាស់លាស់តាមរូបភាពជាក់ស្តែងជាសម្បទាននៃសេវាសាធារណៈឱ្យប្រវាស់សេវាសាធារណៈ ឬអាចរហូតដល់ការធ្វើឯកជនភាវូបនីយកម្ម (ដូចជាករណីនៃការធ្វើឯកជនភាវូបនីយកម្មលើវិស័យអប់រំ)។[13]

---

[10] ក្រសួងមុខងារសាធារណៈ ៖ការកែលម្អគុណភាពសេវាសាធារណៈ

[11] ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧.៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល និងព្រះរាជក្រមលេខ ជស/រកម/០៦៩៦.០៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

[12] សាស្ត្រាចារ្យហៀងសាង៖ នីតិរដ្ឋបាលទូទៅ ឆ្នាំ២០១៧ ទំព័រ២២៣

[13] ច្បាប់ស្តីសម្បទាន(នស.រកម.១០០៧.០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧)

ចំពោះកម្ពុជាបាន និងកំពុងអនុវត្តយន្តការចំនួន៩ចំណុច ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ យន្តការទាំង៩ នេះរួមមាន៖

១. ការកែលម្អកិច្ចដំណើរការការងារនៃការផ្តល់សេវា

២. យន្តការច្រកចេញចូលតែមួយ

៣. វិសហមជ្ឈការសេវាសាធារណៈ

៤. វិមជ្ឈការសេវាសាធារណៈ

៥. គ្រឹះស្ថានសាធារណៈរដ្ឋបាល

៦. សហគ្រាសសាធារណៈ

៧. កិច្ចសន្យា

៨. ភ្នាក់ងារប្រតិបត្តិការពិសេស

៩. ឯកជនភាវូបនីយកម្ម។[14]

**១.១.២.២.ការធ្វើសកម្មភាពដើម្បីជាប្រយោជន៍សាធារណៈ**

**ក. សេវាសាធារណៈដែលមិនស្វែងរកផលចំណេញ**

សេវាសាធារណៈដែលមិនស្វែងរកផលចំណេញ គឺគោលដៅនៃការបម្រើសេវាសាធារណៈច្រើនជាងការរកផលចំណេញតែមិនទាត់ចោលនូវការរកផលចំណេញនោះទេ។[15] ចំពោះអ្វីដែលជាសកម្មភាពបម្រើផលប្រយោជន៍ទូទៅនេះវានៅតែត្រូវបានទទួលស្គាល់ថា គឺជាសេវាសាធារណៈ។ ធនធាន មធ្យោបាយ បុគ្គលិក និង ហិរញ្ញវត្ថុ គឺជារបស់រដ្ឋ។ ចំពោះរចនាសម្ព័ន្ធគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅធ្វើឡើងតាមបែបផែនរបស់រដ្ឋ។

**ខ. សេវាសាធារណៈដែលស្វែងរកផលចំណេញ**

សេវាសាធារណៈដែលស្វែងរកផលចំណេញ គឺគោលដៅនៃការបម្រើសេវាស្វែងរកប្រាក់ចំណេញច្រើនជាងការបម្រើផលប្រយោជន៍ទូទៅ។ គេអាចនិយាយបានម្យ៉ាងទៀតថា ការស្វែងរកផលចំណេញមិននៅដាច់ពីការបម្រើផលប្រយោជន៍ទូទៅទេ។ ធនធាន មធ្យោបាយ បុគ្គលិក និងហិរញ្ញវត្ថុ គឺជារបស់ឯកជន។ ចំពោះរចនាសម្ព័ន្ធគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅ ធ្វើឡើងតាមបែបផែនរបស់ក្រុមហ៊ុនឯកជន គឺនៅតែមានការត្រួតពិនិត្យពីរដ្ឋ។ សកម្មភាព ដែលចងភ្ជាប់ទៅនឹងបុគ្គលសាធារណៈនេះសុទ្ធតែជាសេវាសាធារណៈទាំងអស់។

លក្ខខណ្ឌនៃសេវាសាធារណៈមានពីរចាំបាច់៖

- ភ្ជាប់ទៅនឹងបុគ្គលសាធារណៈ
- គោលបំណងនៃផលប្រយោជន៍ទូទៅ។

**១.១.២.៣ ចរិតលក្ខណៈនៃសេវាសាធារណៈ**

តាមនិយមន័យខាងលើបង្ហាញឱ្យឃើញថាមានចរិតលក្ខណៈ ឬចំណុចវិនិច្ឆ័យ ចំនួន៣ ដែលអាចសម្គាល់ ឬកំណត់បានថាសេវាមួយជាសេវាសាធារណៈ។

[14] ជួប ឋិតចេរឫទ្ធិ៖ ឯកសារជំនួយស្មារតីស្តីពី សេវាសាធារណៈ ទំព័រទី៦

[15] សាស្ត្រាចារ្យហៀងសាង៖ នីតិរដ្ឋបាលទូទៅ ឆ្នាំ២០១៧ ទំព័រ២២៣

**ក. សកម្មភាពបម្រើប្រយោជន៍ទូទៅ**

សំដៅទៅលើសកម្មភាពទាំងឡាយណាដែលធ្វើឡើង ដើម្បីជាប្រយោជន៍ទូទៅសម្រាប់អនុញ្ញាតឱ្យសាធារណជនអាចប្រើប្រាស់បានដោយសេរី ដោយស្មើភាព និងដូចៗគ្នា ដោយមិនសម្រាប់តែបម្រើឱ្យផលប្រយោជន៍របស់បុគ្គលណាម្នាក់ ក្រុមណាមួយ ឬផ្នែកណាមួយនៃសង្គមនោះទេ។ ដើម្បីពិនិត្យថា សកម្មភាពមួយបម្រើផលប្រយោជន៍ទូទៅ ឬមិនបម្រើផលប្រយោជន៍ គឺត្រូវមើលលើតម្រូវការនៃសេវានោះទៅតាមពេលវេលា និងទីកន្លែង ព្រមទាំងភាពសមាមាត្ររវាងផលប្រយោជន៍ និងផលប៉ះពាល់របស់វា។

**ខ. បំពេញដោយ ឬក្រោមការត្រួតពិនិត្យរបស់បុគ្គលសាធារណៈ**

សំដៅទៅលើសកម្មភាពដែលបំពេញដោយស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នទទួលសមត្ថកិច្ចក្រោមការត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។ អ្នកបំពេញសេវាសាធារណៈ គឺជាអ្នកណាក៏បានដែរទោះជារដ្ឋ ឬឯកជនក្ដី តែមានការអនុញ្ញាតដោយច្បាប់ ដែលគេហៅថា ស្ថាប័ន មានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ច។ ឯកជនទទួលសមត្ថកិច្ចផ្ដល់សេវាសាធារណៈអ្វីមួយ ចាំបាច់ត្រូវមានការត្រួតពិនិត្យដោយរដ្ឋ ហើយមានកាតព្វកិច្ចជាប់ចំណងនឹងបុគ្គលសាធារណៈ តាមរយៈកិច្ចសន្យាច្បាស់លាស់ស្ដីពីការផ្ដល់សេវា ទាំងពេលវេលាផ្ដល់សេវា និងតម្លៃប្រើប្រាស់សេវា។

**គ. ស្ថិតនៅក្រោមរបបគតិយុត្តពិសេស**

មានន័យថា សកម្មភាពសេវាសាធារណៈ ត្រូវប្រព្រឹត្តទៅ ក្រោមវិធានគតិយុត្តពិសេសដាច់ដោយឡែកពីវិធានរួម ឬនីតិឯកជន។ វិធាននេះ សំដៅលើនីតិរដ្ឋបាល ឬនីតិសាធារណៈសម្រាប់គ្រប់គ្រងរដ្ឋ ស្ថាប័ន និងសកម្មភាពសាធារណៈ។ ប៉ុន្តែមិនមានន័យថា គ្រប់សកម្មភាព សេវាសាធារណៈស្ថិតនៅក្រោមតែវិធានគតិយុត្តពិសេសមួយប៉ុណ្ណោះនោះទេ ព្រោះសេវាសាធារណៈមួយចំនួនមិនត្រឹមតែអនុលោមតាមវិធានគតិយុត្តពិសេសប៉ុណ្ណោះទេ ប៉ុន្តែបានប្រើប្រាស់វិធាននៃនីតិរួមសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ខ្លួន ជាពិសេសចំពោះសេវាសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច។ ដូចនេះសេវាទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌទាំងបីខាងលើ ទើបហៅថា សេវាសាធារណៈ។ មានន័យថាសេវាសាធារណៈ គឺជាសកម្មភាពទាំងឡាយណាដែលធ្វើឡើងក្នុងគោលដៅ បម្រើផលប្រយោជន៍ទូទៅទោះសកម្មភាពនោះបំពេញដោយរដ្ឋ ភ្នាក់ងាររដ្ឋ អាជ្ញាធរ ឬបុគ្គលសាធារណៈ ឬបំពេញដោយឯកជន ឬអង្គការសង្គមស៊ីវិលក្ដី ប៉ុន្តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ និងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងារ និងត្រូវអនុវត្តតាមវិធានគតិយុត្តពិសេស ឬនីតិសាធារណៈ។

**១.១.២.៤. អត្ថិភាពនៃសេវាសាធារណៈ**

**ក. ប្រភេទនៃសេវាសាធារណៈ**

នៅសតវត្សទី១៩ រដ្ឋជាអ្នកមានសិទ្ធិផ្ដាច់មុខលើសេវាសាធារណៈរដ្ឋបាល SPA រីឯសេវាសាធារណៈដែលមានលក្ខណៈឧស្សាហកម្មនិងពាណិជ្ជកម្ម SPIC ត្រូវកាន់កាប់ដោយបុគ្គលឯកជនដែលទទួលសម្បទានពីរដ្ឋ។ ប៉ុន្តែស្ថានភាពនេះត្រូវផ្លាស់ប្ដូរនៅសតវត្សទី២០។[16] ចំពោះសេវាសាធារណៈរដ្ឋបាល និងសេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្មខាងលើនេះ គឺជាការបែងចែកដែលចម្លងតាមប្រព័ន្ធច្បាប់បារាំងសុទ្ធសាធ។

[16] នីតិរដ្ឋបាលទូទៅ ដោយសាស្ត្រាចារ្យ ឌឿក ពិដោរ បោះពុម្ពផ្សាយអង្គរ ឆ្នាំ២០០៩ ទំព័រ៩២-៩៣

នេះប្រហែលជាមូលហេតុដែលកម្ពុជាធ្លាប់ស្ថិតនៅក្រោមអាណានិគមនិយមបារាំង បានជាធ្វើឱ្យប្រទេសដ៏កំសត់មួយនេះមានប្រព័ន្ធច្បាប់បែបរ៉ូម៉ាំង-អាល្លឺម៉ង់ និងមានប្រព័ន្ធគ្រប់គ្រងរដ្ឋបាលបែបបារាំង។ ដូចនេះជាដំបូងយើងត្រូវសិក្សាអំពីសេវាសាធារណៈរដ្ឋបាលមុខនឹងស្វែងយល់អំពីសេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្ម។

**ក១. សេវាសាធារណៈរដ្ឋបាល (SPA)**

- **និយមន័យ**

សេវាសាធារណៈរដ្ឋបាល គឺជាសកម្មភាពទាំងឡាយណាដែលគ្រប់គ្រងដោយនីតិបុគ្គលសាធារណៈដើម្បីបម្រើប្រយោជន៍ទូទៅ។

- **លក្ខណៈសេវាសាធារណៈរដ្ឋបាល**

សេវាសាធារណៈរដ្ឋបាលត្រូវបានគ្រប់គ្រងដោយរដ្ឋផ្តាច់មុខ។ ចំពោះសេវាសាធារណៈរដ្ឋបាលនេះគឺជាសកម្មភាពដែលបម្រើដោយផ្ទាល់ និងមិនចំពោះហើយដែលសម្រាប់សង្គមជាតិទាំងមូល។

គេឃើញថាសេវាសាធារណៈរដ្ឋបាលមាននៅគ្រប់ទីកន្លែងនៃរដ្ឋដូចជា៖

- នៅថ្នាក់ជាតិ
- នៅថ្នាក់ក្រោមជាតិជាដើម។

នៅសតវត្សរ៍ទី១៩ សេវាសាធារណៈរដ្ឋបាល គ្រប់គ្រងដោយរដ្ឋ ហើយសេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្ម គ្រប់គ្រងដោយបុគ្គលនៃនីតិឯកជនដែលផ្តល់សម្បទានពីរដ្ឋ។ នៅសតវត្សរ៍ទី២០ បុគ្គលនៃនីតិឯកជននេះមានសិទ្ធិធានា សេវាសាធារណៈរដ្ឋបាលផងដែរ។ ចំណែកឯបុគ្គលសាធារណៈវិញ ធ្វើអាជីវកម្មដោយខ្លួនឯងតែម្តងជារដ្ឋាករលើសេវាសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម។

គ្រឹះស្ថានសាធារណៈខ្លះ គ្រប់គ្រងសាធារណៈទាំងពីរប្រភេទតែម្តង។ ចាំបាច់ពិនិត្យមើលទៅសកម្មភាពនៃសេវាសាធារណៈខ្លួនឯងផ្ទាល់តែម្តង ធ្វើយ៉ាងណារកឱ្យឃើញនៅក្នុងសកម្មភាពនេះនូវមធ្យោបាយកំណត់នូវលក្ខណៈវិនិច្ឆ័យនៃការបែងចែកឱ្យឃើញ នៅក្នុងសកម្មភាពនេះនូវមធ្យោបាយកំណត់នូវលក្ខណៈវិនិច្ឆ័យដើម្បីការបែងចែកឱ្យដាច់ពីគ្នា។ តាមយុទ្ធសាស្ត្រឆ្នាំ១៩៥៦ របស់បារាំងគេបានកំណត់លក្ខណៈវិនិច្ឆ័យ**បី៖**

- **លក្ខណៈវិនិច្ឆ័យទាញចេញពីកម្មវត្ថុនៃសេវា**

សេវាសាធារណៈរដ្ឋបាល គឺបម្រើប្រយោជន៍ទូទៅមិនស្វែងរកប្រាក់ចំណេញទេ។ ប៉ុន្តែគោលការណ៍សេវាសាធារណៈរដ្ឋបាលនេះបានទទួលនូវសិទ្ធិផ្តាច់មុខជាប្រយោជន៍នៃអំណាចសាធារណៈត្រូវបានចាត់ទុកថាប្រភេទនៃសេវាសាធារណៈរដ្ឋបាលដដែល បើទោះបីសកម្មភាពរបស់វាមានលក្ខណៈជាឧស្សាហកម្ម និងពាណិជ្ជកម្មក៏ដោយ។ ត្រូវសម្គាល់ថា សិទ្ធិផ្តាច់មុខនេះមិនបណ្តាលឱ្យរដ្ឋទាត់ចោលនូវលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្មរបស់ខ្លួនឡើយ។ នៅក្នុងករណីនេះ គេហៅថាសេវាសាធារណៈដែលមានមុខផ្កាប់(មុខពីរ)។

សកម្មភាពទីមួយ គឺពិតជាតម្រុយនៃសេវាសាធារណៈរដ្ឋបាល រីឯសកម្មភាពទីពីរ គឺសេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្ម។

- **លក្ខណៈវិនិច្ឆ័យទាញចេញពីធនធាននៃសេវា**

លក្ខណៈវិនិច្ឆ័យទាញចេញពីធនធាននៃសេវាគឺ មូលនិធិសាធារណៈ និងអាករយកពីអ្នកប្រើប្រាស់ (អតិថិតា)

- **លក្ខណៈវិនិច្ឆ័យទាញចេញពីការរៀបចំ និងការប្រព្រឹត្តទៅនៃសេវា**

យើញឃើញថា សេវាសាធារណៈរដ្ឋបាល នេះគឺជាសកម្មភាពមួយដែលបម្រើប្រយោជន៍ទូទៅហើយដែលគេរៀបចំ និងការប្រព្រឹត្តទៅតាមរបៀបៈ ប្រព័ន្ធនៃការជ្រើសរើសនិងការត្រួតពិនិត្យបុគ្គលិក (លក្ខន្តិកៈនៃនីតិសាធារណៈ) ការចេញសេចក្តីសម្រេចមានលក្ខណៈជាបទបញ្ជា និងមានសិទ្ធិប្រើប្រាស់កម្លាំងប្រដាប់អាវុធ។

- ➢ **របបគតិយុត្ត និងការគ្រប់គ្រង**
- **របបគតិយុត្ត**

របបគតិយុត្ត គឺសេវាសាធារណៈរដ្ឋបាល ជាគោលការណ៍សេវាសាធារណៈរដ្ឋបាលស្ថិតនៅក្រោមរបបគតិយុត្តនៃនីតសាធារណៈ ជាពិសេសនីតិរដ្ឋបាលជាមួយនឹងផលវិបាកទាំងឡាយ ដែលទាក់ទងទៅនឹងសេវានេះខាងវិវាទ។ ដូច្នេះការដោះស្រាយវិវាទ ដែលកើតឡើងជាសមត្ថកិច្ចនៅក្នុងការដោះស្រាយដូចជាតុលា និងការរដ្ឋបាល។

- **ការគ្រប់គ្រង**

ការគ្រប់គ្រងនៃសេវាសាធារណៈរដ្ឋបាល គឺគ្រប់គ្រងដោយមន្ត្រីរាជការរបស់រដ្ឋសុទ្ធសាធដែលទទួលប្រាក់បៀវត្សរពីរដ្ឋ។ ឧទាហរណ៍៖ យោធិន នគរបាល និងគ្រូបង្រៀនជាដើម។[17]

**ក២. សេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្ម(SPIC)**

- ➢ **និយមន័យ**

សេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្ម គឺជាសកម្មភាពទាំងឡាយដែលបានគ្រប់គ្រងដោយនីតិបុគ្គលឯកជនដើម្បីផលប្រយោជន៍ទូទៅ។

- ➢ **លក្ខណៈសេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្ម**

ដើម្បីឱ្យដឹងថា សេវាសាធារណៈណាមួយជាសេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្មលុះត្រាតែសេវានោះចាំបាច់ត្រូវប្រកបសកម្មភាពសេដ្ឋកិច្ចដែលស្ថិតនៅក្នុងការប្រកួតប្រជែងជាមួយសហគ្រាសឯកជន។

សេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្ម ក៏ដូចជាសេវាសាធារណៈរដ្ឋបាលដែលគេបានកំណត់លក្ខណៈវិនិច្ឆ័យបីយ៉ាងគឺ៖

- **លក្ខណៈវិនិច្ឆ័យទាញចេញពីកម្មវត្ថុនៃសេវា**

សេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្មមានលក្ខណៈឯកជនបម្រើប្រយោជន៍ទូទៅទាញយកផលចំណេញហើយចូលរួមសកម្មភាពក្នុងការផលិតកម្មសម្ភារប្រើប្រាស់ និងការបំពេញតម្រូវការធ្វើឡើងនៅក្នុងគោលបំណងចូលរួមសកម្មភាពបម្រើផលប្រយោជន៍ទូទៅ។ ជាគោលការណ៍ច្បាប់បានកំណត់ថាមិនត្រូវឱ្យមានការបង្កើត ឬការធ្វើអាជីវកម្មតែក្នុងគោលបំណងហិរញ្ញវត្ថុសុទ្ធសាធនោះទេ។

- **លក្ខណៈវិនិច្ឆ័យទាញចេញពីធនធាននៃសេវា**

ហិរញ្ញកិច្ចរបស់សេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្មគឺបានមកពីការបង់ថ្លៃឈ្នួលរបស់អ្នកប្រើប្រាស់សេវាជាមួយនឹងការងារដែលបានផ្តល់ឱ្យ។

[17] សាស្ត្រាចារ្យ ហៀង សាង៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៤ ឆ្នាំ២០១៧ ទំព័រ២២៥

- **លក្ខណៈវិនិច្ឆ័យទាញចេញពីការរៀបចំ និងការប្រព្រឹត្តទៅនៃសេវា**

យើញឃើញថាសេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្មនេះ គឺជាសកម្មភាពមួយដែលបម្រើប្រយោជន៍ទូទៅហើយគេរៀបចំ និងការប្រព្រឹត្តទៅតាមរបៀបៈ ប្រព័ន្ធនៃការជ្រើសរើស និងការត្រួតពិនិត្យបុគ្គលិក (លក្ខន្តិកៈនៃនីតិឯកជន) ការចេញសេចក្តីសម្រេចមានលក្ខណៈជាបទបញ្ញាទូទៅ និងមិនមានសិទ្ធិប្រើប្រាស់កម្លាំងប្រដាប់អាវុធ។

- **របបគតិយុត្ត និងការគ្រប់គ្រង**

- **របបគតិយុត្ត**

របបគតិយុត្តនៃសេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្ម ជាគោលការណ៍ស្ថិតនៅក្រោមរបបគតិយុត្តនៃនីតិឯកជន ជាមួយនឹងផលវិបាលទាំងឡាយដែលទាក់ទងទៅនឹងសេវានេះខាងវិវាទ។ ដូចនេះការដោះស្រាយវិវាទដែលកើតឡើងសមត្ថកិច្ច គឺតុលាការយុត្តិធម៌។ មានការលើកលែងករណីមួយចំនួន ដែលពាក់ព័ន្ធទៅនឹងថ្នាក់នាំសហគ្រាសសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលមានលក្ខន្តិកៈពិសេសប៉ុណ្ណោះ។

- **ការគ្រប់គ្រង**

ការគ្រប់គ្រងនៃសេវាសាធារណៈឧស្សាហកម្ម និងពាណិជ្ជកម្ម គឺគ្រប់គ្រងដោយបុគ្គលិករបស់ឯកជនដែលមិនទទួលបៀវត្សរពីរដ្ឋទេ។

ឧទាហរណ៍៖ បុគ្គលិករដ្ឋាករទឹក និងអគ្គិសនីជាដើម។[18]

**ខ. សេវាសាធារណៈអាទិភាព**

សេវាសាធារណៈដូចបានកំណត់នៅខាងលើ និងដែលមានចែងនៅក្នុងគោលនយោបាយនេះត្រូវបានចងក្រង និងប្រមូលផ្តុំជា៧ប្រភេទធំៗទៅតាមវិស័យ និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នពាក់ព័ន្ធដូចខាងក្រោម៖[19]

- **ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ៖**

ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ គឺជាសេវា ទទួលខុសត្រូវផ្តាច់មុខរបស់រដ្ឋ ដែលផ្តល់ដោយអង្គភាពរដ្ឋ ឬនីតិបុគ្គលនៃនីតិសាធារណៈដែលរដ្ឋបានប្រគល់សិទ្ធិអំណាចឱ្យដើម្បីអនុវត្ត។ ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋមានដូចជា លិខិតអនុញ្ញាត អាជ្ញាបណ្ណ បញ្ជីអត្រានុកូលដ្ឋាន សំបុត្របញ្ជាក់កំណើត បណ្ណសំគាល់យានយន្ត អាកាសយានដ្ឋាន និងវិញ្ញាបណ្ណប័ត្រទទួលស្គាល់កម្មសិទ្ធិ អត្តសញ្ញាណបណ្ណប្រជាពលរដ្ឋខ្មែរ ជាពិសេស ការធ្វើនីត្យានុកូលកម្មជាដើម។ សៀវភៅគ្រួសារពាក់ព័ន្ធទៅនឹងចង្កោមសេវាសាធារណៈនេះ ការរៀបចំ និងការប្រតិបត្តិការនៃការផ្តល់សេវាត្រូវទទួលខុសត្រូវដោយរដ្ឋ ឬភ្នាក់ងាររបស់រដ្ឋ។

- **ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម៖**

ចង្កោមសេវាពាក់ព័ន្ធផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការស្នាក់នៅ ការធ្វើដំណើរ ការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋ និងសុវត្ថិភាពសង្គម គឺជាសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចនគរបាលជាតិកងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទ គ្រប់លំដាប់ថ្នាក់ទូទាំងប្រទេស។ ចង្កោមសេវានេះជាសេវាដ៏

[18] សាស្ត្រាចារ្យ ហៀង សាង៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៤ ឆ្នាំ២០១៧ ទំព័រ២២៩

[19] គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ថ្ងៃទី៥ ឧសភា ២០០៦

ចាំបាច់មួយ និងមិនអាចខ្វះបាន ដើម្បីធានាបរិយាកាសល្អដល់ការអភិវឌ្ឍសង្គមជាតិ ការកាត់បន្ថយភាពក្រីក្រ ភាពសុខសាន្តរបស់ប្រជាពលរដ្ឋ និងជាទំនុកចិត្ត ដល់វិនិយោគិន ធុរជន ក្នុងការប្រកបរបរអាជីវកម្ម និងជំនួញជួញដូរ។ ពាក់ព័ន្ធទៅនឹងចង្កោមសេវាសាធារណៈនេះចំពោះការរៀបចំ និងការប្រតិបត្តិការនៃការផ្តល់សេវាត្រូវធ្វើឡើងដោយរដ្ឋ ឬភ្នាក់ងាររបស់រដ្ឋ។

➢ **ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាលៈ**

ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាលដូចជា វិវាទរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ឬរវាងប្រជាពលរដ្ឋ និងអ្នករាជការ ឬរវាងប្រជាពលរដ្ឋ និងផ្នែកឯកជន ឬរវាងអ្នករាជការ និងផ្នែកឯកជនជាដើម សេវាដោះស្រាយវិវាទនេះធ្វើឡើងតាម រូបភាព២ យ៉ាង៖

- តាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាអ្នកសម្របសម្រួល និងដោះស្រាយចំពោះករណីវិវាទមិនធ្ងន់ធ្ងរ ដើម្បីសម្រួលដល់គូភាគីទាំងសងខាង ដោយមិនចាំបាច់ពឹងផ្អែកតទៅលើតុលាការ និងកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ
- ក្នុងករណីគូភាគីវិវាទមិនទទួលយកនូវដំណោះស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេនោះ ការដោះស្រាយវិវាទត្រូវធ្វើឡើងតាមរយៈតុលាការ។ ភាពជឿទុកចិត្តរបស់អ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធទាំងអស់អាស្រ័យទៅលើការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវនៅក្នុងបរិបទ នៃនីតិរដ្ឋដូចនេះរាល់សកម្មភាពកែលំអប្រព័ន្ធការងារទាំងអស់ត្រូវរៀបចំឡើងជាជំហានៗ និងដោយការប្រុងប្រយ័ត្នក្នុងទិសដៅបង្កើនគុណភាព និងប្រសិទ្ធភាព នៃសេវាកម្មយុត្តិធម៌។

➢ **ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកំពស់កិច្ចការពាណិជ្ជកម្មសហគ្រាសធុនតូច និងមធ្យម បរិស្ថានវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ**

ការលើកកំពស់កិច្ចការពាណិជ្ជកម្ម៖ រាជរដ្ឋាភិបាល ដែលជាអ្នករៀបចំយុទ្ធសាស្ត្រ និងជាអ្នកគ្រប់គ្រងការអភិវឌ្ឍ ដើម្បីធ្វើឱ្យបរិស្ថាន ធុរកិច្ចកាន់តែប្រសើរសម្រាប់វិស័យឯកជនបានចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។ អាទិភាពជាពិសេសនឹងត្រូវផ្តោតទៅលើការរៀបចំ ឱ្យកាន់តែប្រសើរឡើងនូវបរិស្ថានរួមសម្រាប់ការអភិវឌ្ឍវិស័យឯកជន តាមរយៈវិធានការជាក់ស្តែងនានាដូចជា៖

- ពង្រឹងអភិបាលកិច្ចល្អ ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន
- កាត់បន្ថយរាល់បែបបទស្មុគស្មាញ និងវែងអន្លាយនៅតាមក្រសួងស្ថាប័នដែលបានពាក់ព័ន្ធដល់ការនាំចេញ និងនាំចូល
- បំបាត់ចោលនូវភារកិច្ចជាន់គ្នារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញដំណើរការត្រួតពិនិត្យតែមួយកន្លែងឱ្យមានប្រសិទ្ធភាព
- ពង្រឹងការអនុវត្តយន្តការការិយាល័យច្រកចេញចូលតែមួយ នៅតាមបណ្តាច្រកអន្តរជាតិ

**សហគ្រាសធុនតូច និងមធ្យម៖** រាជរដ្ឋាភិបាលបន្តជំរុញការអភិវឌ្ឍសហគ្រាស ធុនតូច និងមធ្យមតាមរយៈគោលនយោបាយ៖

- លើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យមជាពិសេសតាមរយៈការផ្តល់ឥណទានរយៈពេលមធ្យម និងរយៈពេលវែង

- ទប់ស្កាត់ការរត់គេចពន្ធគ្រប់ប្រភេទ
- កាត់បន្ថយបែបបទការចុះបញ្ជី និងការរៀបចំដំណើរការក្រុមហ៊ុន
- សម្រួលដល់ការនាំចេញនាំចូលតាមរយៈការកាត់បន្ថយបែបបទស្មុគស្មាញ ក្នុងការស្នើសុំអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ
- កាត់បន្ថយពេលវេលាជាងមុន និងកាត់បន្ថយថ្លៃសេវាកម្មចំពោះការអនុញ្ញាតឱ្យដំណើរការផលិតកម្មនៃសហគ្រាសធុនតូច និងមធ្យមតាមរយៈការអនុវត្តយន្តការការិយាល័យច្រកចេញចូលតែមួយ
- ផ្តល់ការគាំពារដល់សហគ្រាសមួយចំនួនក្នុង រយៈពេលមួយសមស្រប
- ជំរុញឱ្យមានសម្ព័ន្ធភាពរវាងសហគ្រាសធុនតូច និងមធ្យម ជាមួយនឹងឧស្សាហកម្មធុនធំជាដើម
- ជំរុញលើកទឹកចិត្ត ដល់ការផលិតទំនិញបម្រើទីផ្សារក្នុងស្រុកជំនួសការនាំចូលដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រនៃការបង្កើតមូលដ្ឋាន ផលិតកម្មទំនិញក្នុងប្រទេសឱ្យបានច្រើនស្របទៅនឹងយុគសម័យនៃតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម
- រៀបចំយុទ្ធសាស្ត្របង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់សហគ្រាសធុនតូច និងមធ្យម
- រៀបចំផែនការសកម្មភាព និងបទប្បញ្ញត្តិនានាដើម្បីគ្រប់គ្រង តាមដានត្រួតពិនិត្យ និងគាំទ្រដល់ដំណើរការរបស់សហគ្រាសធុនតូច និងមធ្យម។

**បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនៈ** ក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងការងារនេះ រាជរដ្ឋាភិបាលនឹងចាត់វិធានការចាំបាច់ដើម្បីពង្រឹង និងកែលំអ បរិស្ថានវិនិយោគ និងធុរកិច្ចរួមមានគោលនយោបាយលើកទឹកចិត្ត លិខិតបទដ្ឋានសម្រាប់ណែនាំ និងជំរុញការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ។ រចនាសម្ព័ន្ធនៃផ្នែកពាក់ព័ន្ធទៅនឹងចង្កោមសេវានេះដែលមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការជាចាំបាច់ ក្នុងការសម្រួលដល់ការធ្វើអាជីវកម្ម ការវិនិយោគទុន និងការអភិវឌ្ឍផ្នែកឯកជនត្រូវធ្វើការកែសម្រួលឱ្យបានសមស្រប និងឱ្យបានឆាប់រហ័សទៅតាមស្ថានភាពជាក់ស្តែង និងធនធានដែលមាន។

➢ **ចង្កោមសេវាសង្គមកិច្ច វប្បធម៌ និងកិច្ចការនារីៈ**

ចង្កោមសេវានេះរួមមាន សេវាអប់រំលើកកំពស់គុណភាពសេវាអប់រំសម្រាប់ទាំងអស់គ្នា សម្ភារសិក្សាគ្រប់គ្រាន់ និងសិទ្ធិទទួលបានសេវាអប់រំជាមូលដ្ឋាន សេវាអនាម័យ និងសុខភាព បង្កលក្ខណៈងាយស្រួលគុណភាព ប្រសិទ្ធភាព ដើម្បីផ្គត់ផ្គង់នូវសេវាសុខាភិបាលមូលដ្ឋានប្រកបដោយសមធម៌ និងនិរន្តរភាព ជូនដល់ប្រជាពលរដ្ឋគ្រប់រូប ជាពិសេសជនក្រីក្រ និងក្រុមជនងាយរងគ្រោះសេវាសម្រាប់ការកំសាន្ត សេវាសង្គមកិច្ច សេវាគាំពារកុមារកំព្រា កុមារងាយរងគ្រោះ ជនពិការ សេវាលើកស្ទួយ និងការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសេវាដទៃទៀតដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

➢ **ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តៈ**

ការផ្តល់សេវានៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គឺជាអាទិភាពចំបងមួយរបស់រាជរដ្ឋាភិបាលដើម្បីជម្រុញ និងបង្កើនល្បឿនកំណើននៃសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តត្រូវផ្តោតជាសំខាន់លើការបន្តការកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនរួមមាន ផ្លូវថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ

និងអាកាសយានដ្ឋានដែលអាចតភ្ជាប់ពីទីក្រុងទៅជនបទ និងគ្រប់ទីកន្លែងនៅទូទាំងប្រទេស កសាងមន្ទីរពេទ្យ សាលារៀន អណ្តូងទឹក ប្រព័ន្ធទឹកស្អាត ប្រព័ន្ធធារាសាស្ត្រ អគ្គីសនី ថាមពល បច្ចេកវិទ្យាព័ត៌មាន ប្រៃសណីយ៍ និងទូរគមនាគមន៍។ ពាក់ព័ន្ធនឹងចង្កោមសេវានេះរាជរដ្ឋាភិបាលមានគោលនយោបាយលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ជាពិសេសផ្នែកឯកជន។

- **ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូលះ**

ធ្វើវិចារណកម្មចំណាយ និងការបើកផ្តល់ចង្កោមសេវានេះ ពាក់ព័ន្ធនឹងការកែលំអការគ្រប់គ្រងចំណូលចំណាយ និងការបើកផ្តល់ឱ្យមាន តម្លាភាព និងប្រសិទ្ធភាពខ្ពស់ជាងមុន សំដៅកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវា។ ដើម្បីសម្រួលដល់ការអនុវត្ត ក្រសួង ស្ថាប័ន ដែលមានភារកិច្ចពាក់ព័ន្ធនឹងចង្កោមសេវាណាមួយ ក្នុងចំណោមចង្កោមសេវាទាំង៧ ខាងលើ ត្រូវរៀបចំចងក្រងបញ្ជីសេវានេះឱ្យបានសមស្រប។ ករណីមានការវិវត្តសេដ្ឋកិច្ចទីផ្សារ ក៏ដូចជា បច្ចេកវិទ្យាទំនើប និងតម្រូវការជាក់ស្តែងដទៃទៀត ដែលកើតមានឡើងពីការវិវត្តរបស់សង្គមជាតិសេវា-សាធារណៈនឹងត្រូវកំណត់តាមស្ថានការណ៍វិវត្តនោះ។ ការផ្តល់សេវាសាធារណៈគ្រប់ប្រភេទទោះបីជាតាមរយៈយន្តការទីកន្លែង និងកាលៈទេសៈណាក៏ដោយ ត្រូវគិតទៅដល់លទ្ធភាព និងការគាំទ្រដល់ជនក្រីក្រ ជនពិការ ចាស់ជរា និងកុមារទាំងនៅក្នុងទីក្រុង និងនៅតាមទីជនបទ ក្នុងការទទួលយកសេវាទៅប្រើប្រាស់។

## ១.២. ការរៀបចំ និងការប្រព្រឹត្តទៅនៃសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់

សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីគ្រប់គ្រង ដឹកនាំធានានូវអធិបតេយ្យភាព និងដើម្បីប្រយោជន៍សាធារណៈទូទៅដែលស្ថិតក្រោមដែនដីឃុំ សង្កាត់របស់ខ្លួន។ សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ គឺផ្តោតសំខាន់ទៅលើការការងារអគ្រានុកូលដ្ឋាននានាដែលមានចែងក្នុងច្បាប់ស្តីពីអគ្រានុកូលដ្ឋាន។

### ១.២.១. ការបង្កើត និងការរៀបចំសេវាសាធារណៈ

ការបង្កើតអង្គការទាំងនេះ ដើម្បីទទួលបន្ទុកនៅក្នុងការអនុវត្តសេវាសាធារណៈនេះជាគោលការណ៍ គឺអត្ថបទគតិយុត្ត (រដ្ឋធម្មនុញ្ញ ច្បាប់ ឬបទបញ្ជា)។ នៅក្នុងរដ្ឋប្រជាធិបតេយ្យរាស្ត្រប្រជាមានសិទ្ធិទទួលបាននូវដំណើរការប្រព្រឹត្តទៅនៃសេវាសាធារណៈ និងសិទ្ធិទាមទារឱ្យមានសេវាសាធារណៈហើយសិទ្ធិនេះត្រូវបានចែងដោយរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទបញ្ជា។ ដូច្នេះ អាជ្ញាធររដ្ឋដែលមានសមត្ថកិច្ចនៅក្នុងការឱ្យតម្លៃប្រសិនបើការទាមទារនេះពិតជាតម្រូវការចាំបាច់មែន។ សេវាសាធារណៈ ត្រូវបង្កើតឡើងដើម្បីបំណងរាស្ត្រប្រជាតែប៉ុណ្ណោះ។ អាជ្ញាធររដ្ឋ ត្រូវមានសមត្ថកិច្ចនៅក្នុងការបង្កើត និងការរក្សាសេវាសាធារណៈ។ ផ្ទុយទៅវិញសេវាសាធារណៈមួយនេះក៏អាចត្រូវលុបចោលទៅវិញបាន ប្រសិនបើខ្លួនយល់ឃើញថា មានការភ័ន្តច្រឡំក្នុងការឱ្យតម្លៃ នៃអង្គហេតុ។ ការបង្កើតសេវាសាធារណៈគឺដោយច្បាប់ និងបទបញ្ជា។

នៅក្នុងតួនាទីបម្រើកិច្ចការរដ្ឋបាលដែនដីឃុំ សង្កាត់ មានភារកិច្ចរៀបចំ ចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ។[20] នៅក្នុងការត្រួតពិនិត្យឡើងវិញនូវមុខងារ និងការទទួលខុសត្រូវនីមួយៗ ដូចមានចែងក្នុងច្បាប់នេះ ត្រូវផ្តល់អាទិភាពដល់ការពិនិត្យឡើងវិញនូវមុខងារ

[20] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

ជាមូលដ្ឋាន និងចាំបាច់ដែលមានផលប៉ះពាល់ផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ និងការកែលម្អគុណភាព នៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។[21]

**១.២.១.១. ការបង្កើតសេវាសាធារណៈ**

នៅព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលនៃយើងបាននឹងកំពុងតែអនុវត្តនូវគោលនយោបាយដ៏សំខាន់មួយនោះ គឺគោលនយោបាយ ស្តីពី ការផ្តល់សេវាសាធារណៈ សម្រាប់ជូនដល់បងប្អូនប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើងជាពិសេសគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលសាធារណៈត្រូវតែបានពង្រឹងដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរប្រកបដោយនិរន្តរភាព និងពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់កម្ពុជាយើងដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយចីរភាព។ នៅក្នុងរដ្ឋប្រជាធិបតេយ្យរាស្ត្រប្រជាមានសិទ្ធិទទួលបាននូវដំណើរការប្រព្រឹត្តទៅនៃសេវាសាធារណៈ និងសិទ្ធិទាមទារឱ្យមានសេវាសាធារណៈហើយសិទ្ធិនេះត្រូវបានចែងដោយ រដ្ឋធម្មនុញ្ញ ច្បាប់ ឬបទបញ្ជា។

ការបង្កើតសេវាសាធារណៈនេះ គឺត្រូវបានបង្កើតឡើងដោយច្បាប់ និងបទបញ្ជា។ ការបង្កើតស្ថាប័ន ឬអង្គការទទួលបន្ទុកផ្តល់សេវាសាធារណៈជូនសាធារណៈ មានគោលបំណងរាស្ត្រប្រជាតែប៉ុណ្ណោះ គឺដើម្បីបម្រើប្រយោជន៍សាធារណៈទូទៅ។ ចំពោះគោលនយោបាយ ស្តីពីការផ្តល់សេវាសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជាដែលអនុម័តដោយសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រីនាថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦ វាក្យសព្ទសេវាសាធារណៈត្រូវបានកំណត់និយមន័យថា រាល់សកម្មភាពទាំងឡាយ ដែលធ្វើឡើងដោយ ស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នទទួលសមត្ថកិច្ច ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។ ស្ថាប័នមានសមត្ថកិច្ចសំដៅដល់ស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋដែលបំពេញការងារតាមសមត្ថកិច្ចរបស់ខ្លួន។ ស្ថាប័នទទួលសមត្ថកិច្ច សំដៅដល់ផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋហើយស្ថិតនៅក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់រដ្ឋ ឬភាក់ងាររដ្ឋ។

នៅក្នុងការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈនាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់នីតិកាលទី៣ នៃរដ្ឋសភាបានផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យអាទិភាពចំនួន៤ ដើម្បីផ្តល់ជាសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋនៅក្នុងយុទ្ធសាស្ត្រចតុកោណដែលមានជាអាទិ៍៖

- សេវាដែលពាក់ព័ន្ធនឹងអធិបតេយ្យភាពរបស់រដ្ឋ៖ **សេវាអត្រានុកូលដ្ឋាន** ផ្សេងៗ និងបណ្ណកម្មសិទ្ធិលើដីធ្លី
- សេវាដែលពាក់ព័ន្ធនឹងការវិនិយោគ
- សេវាកម្មមូលដ្ឋាន៖ អប់រំ និងសុខាភិបាល
- សេវាដែលពាក់ព័ន្ធនឹងចំណូលចំណាយរបស់រដ្ឋ។[22]

---

[21] មាត្រា២១៦ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ ឆ្នាំ២០០៨

[22] សាស្ត្រាចារ្យ ខាំ សុមករា៖ រដ្ឋបាលសាធារណៈ ឆ្នាំ២០១៣ ទំព័រទី៨៣

**១.២.១.២. ការរៀបចំសេវាសាធារណៈ**

នៅក្នុងតួនាទីបម្រើកិច្ចការរដ្ឋបាលដែនដីឃុំ សង្កាត់ មានតួនាទីភារកិច្ចរៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ។[23] នៅក្នុងការត្រួតពិនិត្យឡើងវិញនូវមុខងារ និងការទទួលខុសត្រូវនីមួយៗ ដូចមានចែងនៅក្នុងច្បាប់ខាងលើនេះត្រូវផ្តល់អាទិភាពដល់ការពិនិត្យឡើងវិញនូវមុខងារជាមូលដ្ឋាន និងចាំបាច់ដែលមានផលប៉ះពាល់ផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ និងការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។[24]

**១.២.២. គោលការណ៍គ្រឹះ នៃសេវាសាធារណៈ**

រាល់សកម្មភាពទាំងឡាយដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ចក្នុងគោលដៅបម្រើប្រយោជន៍សាធារណៈ គឺជាសេវាសាធារណៈ។ ចំពោះការផ្តល់សេវាសាធារណៈទាំងអស់ គឺត្រូវចាំបាច់ស្របទៅតាមគោលការណ៍គ្រឹះចំនួនបីប្រភេទរួមមាន គោលការណ៍និរន្តរភាព គោលការណ៍កែតម្រូវ និងគោលការណ៍សមភាព។

**១.២.២.១. គោលការណ៍និរន្តរភាពនៃសេវាសាធារណៈ**

សេវាសាធារណៈត្រូវមានដំណើរការយ៉ាងជាប់លាប់ ទាន់ពេលវេលា ទៀងទាត់ មិនអាចឈប់ ឬផ្អាកបានឡើយ។ គោលការណ៍នេះជាផលវិបាក នៃនិរន្តរភាពរបស់រដ្ឋព្រោះរដ្ឋមានអត្ថិភាព ជារៀងរហូតទោះបីមានការផ្លាស់ប្តូររាជរដ្ឋាភិបាលក៏ដោយ។ ដូច្នេះសេវាសាធារណៈក៏ត្រូវបានគេរក្សាជានិរន្តរ៍ដែរ។

គោលការណ៍នេះសិក្សាក្រោមរូបភាពពីរ៖

- បុព្វសិទ្ធដែលត្រូវប្រគល់ទៅឱ្យរាជការ រាជការមានបុព្វសិទ្ធិគ្រប់គ្រាន់នៅក្នុងការកំណត់ពីសិទ្ធិផ្សេងៗប្រយោជន៍ដើម្បីធានាសេវាសាធារណៈ។ ការធ្វើកូដកម្ម គឺផ្ទុយទៅនឹងគោលការណ៍ នៃសេវា។ យ៉ាងណាមិញនៅក្នុងប្រទេសបារាំងគេមានច្បាប់ហាម មិនឱ្យយោធិន ប៉ូលីស មន្ត្រីពន្ធនាគារ និងចៅក្រមធ្វើកូដកម្មទេ។ ចំណែកនៅព្រះរាជាណាចក្រកម្ពុជាវិញបានចែងថាសិទ្ធិធ្វើកូដកម្ម បាតុកម្មដោយសន្តិវិធីត្រូវយកមកអនុវត្តក្នុងក្របខណ្ឌ នៃច្បាប់។[25]
- កាតព្វកិច្ចដែលធ្លាក់ទៅលើអំណាចសាធារណៈ រាជការមានបុព្វសិទ្ធបង្ខំឱ្យសម្បទានិកបម្រើ និងផ្តល់សេវាសាធារណៈឱ្យបានល្អ។ បើពុំនោះទេរាជការដាក់ទណ្ឌកម្ម (ផាកពិន័យ ផ្អាក ឬលុបចោល) ហើយនៅក្នុងករណីនេះរាជការជំនួសសម្បទានិកដែលករណីនេះចៅក្រមជាអ្នកមានសមត្ថកិច្ច។ តែផ្ទុយទៅវិញនេះរាជការមាន កាតព្វកិច្ចនៅក្នុងការផ្តល់នូវមធ្យោបាយហិរញ្ញវត្ថុ ដោយសម្បទានិកដើម្បីបំពេញបេសកកម្មរបស់ខ្លួនប្រសិនបើជាមានកាលៈទេសៈសេដ្ឋកិច្ចជាមូលហេតុនាំឱ្យក្រឡាប់ចាក់ ឬបាត់លំនឹងនៃការគ្រោងទុកដែលប្រការនេះគេហៅថារាជការអនុវត្តន៍ទ្រឹស្តី នៃការឥតព្រៀងទុកជាមុន។ ក៏ប៉ុន្តែបើមានការចង្អុលបង្ហាញថាសេវាសាធារណៈនេះ មិនអាចធ្វើឱ្យមានលំនឹងឡើងវិញខាងផ្នែកហិរញ្ញវត្ថុនោះ

[23] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[24] មាត្រា ២១៦ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០០៨

[25] មាត្រា៣៧ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ទេដោយផ្អែកតាមមូលដ្ឋានដើម នៃការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចនោះ ឬអាចបញ្ឈប់នូវអស្ថិរភាព អាទិភាព នៃកិច្ចសន្យារឿងអាទិភាពចំពោះសេវានោះតែម្តង។[26]

**១.២.២.២. គោលការណ៍កែតម្រូវនៃសេវាសាធារណៈ**

គោលការណ៍នេះ មានន័យថាសេវាសាធារណៈត្រូវមានការកែតម្រូវដែលផ្តល់ លទ្ធភាពឱ្យរាជ ទាមទារបានពីសម្បទានិកដែលជួនកាលធ្វើឱ្យកាន់តែប្រសើរឡើង នូវគុណភាពការងារហើយដែលជួនកាលនូវបរិមាណរបស់វា ដើម្បីបំពេញបំណងផលប្រយោជន៍ទូទៅនៅក្នុងករណីដែលមានការទាមទារនៃផលប្រយោជន៍ទូទៅនេះនាំឱ្យ មានការផ្លាស់ប្តូរសេវាសាធារណៈ។ អានុភាពនៃកិច្ចសន្យាសម្បទានមិនមែនជាឧបសគ្គដល់គោលការណ៍កែតម្រូវនៃសេវាសាធារណៈរបស់សម្បទានកនោះទេ។ សម្បទាន ក៏មានសិទ្ធិអំណាចគ្រប់គ្រាន់នៅក្នុងការកែប្រែជាឯកតោភាគីនៃកិច្ចសន្យាសម្បទានក្នុងផលប្រយោជន៍ទូទៅ។[27]

**១.២.២.៣. គោលការណ៍សមភាពនៃសេវាសាធារណៈ**

គោលការណ៍សមភាព នៃសេវាសាធារណៈនេះមានន័យថា អ្នកប្រើប្រាស់ដែលស្ថិតនៅក្នុងស្ថានភាពតែមួយដូចគ្នាតែអង្គច្បាប់ និងអង្គហេតុ។ គោលការណ៍សមភាព នៃសេវាសាធារណៈនេះត្រូវទទួលបាននូវអាកប្បកិរិយាដូចគ្នា។ គោលការណ៍សមភាពរវាងអ្នកប្រើប្រាស់សេវាសាធារណៈនេះ គឺមិនមែនជាគោលការណ៍មួយដែលមានលក្ខណៈដាច់ខាតនោះទេ។ ប៉ុន្តែដោយរបៀបមិនដាច់ខាតពោល គឺសមភាពទៅតាមប្រភេទ នៃអ្នកប្រើប្រាស់។ ដូចនេះគោលការណ៍សមភាព គឺដូចគ្នាតែចំពោះអ្នកដែលប្រើប្រាស់ សេវាសាធារណៈដែលស្ថិតនៅក្នុងប្រភេទតែមួយដូចគ្នាតែប៉ុណ្ណោះ។ ប៉ុន្តែមិនដូចគ្នាតែចំពោះអ្នក ដែលប្រើប្រាស់សេវាសាធារណៈមិនស្ថិតនៅក្នុងប្រភេទតែមួយលោកភាពខុសគ្នា នៃអាកប្បកិរិយាកើតមាន ហើយដែលទាក់ទងទៅនឹងការកំណត់តារាងតម្លៃ មានន័យថា សមភាពនៃរាស្ត្រប្រជាមានសិទ្ធិទាមទារឱ្យមានការគោរពវិធានចែងអំពីសេវាសាធារណៈនេះ។ សមភាព នៃសេវាសាធារណៈមិនបានហាមឃាត់ការបង្កើនតម្លៃផ្សេងៗគ្នានោះទេ។ សេវាសាធារណៈនោះត្រូវបំពេញបំណងឱ្យប្រភេទផ្សេងៗគ្នា នៃអ្នកប្រើប្រាស់ ចំពោះសេវាសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម។ ដោយហេតុថា ផលប្រយោជន៍ទូទៅអាចបញ្ជាក់ពីវិសមភាពបាននៅក្នុងចំណោមអ្នកប្រើប្រាស់នេះ(អតិថិតា)។ ប៉ុន្តែគោលការណ៍សមភាពនេះរាល់ភាពរើសអើងពណ៌សម្បុរចំពោះអ្នកប្រើប្រាស់សេវាសាធារណៈដែលមិនគោរពអព្យាក្រឹតភាពប្រកាន់ពូជសាសន៍ពណ៌សម្បុរត្រូវបានហាមឃាត់ជាដាច់ខាត។[28]

[26] សាស្ត្រាចារ្យហៀងសាងៈ នីតិរដ្ឋបាលទូទៅ ឆ្នាំ២០១៧ (បោះពុម្ពលើកទី៣) ទំព័រទី២២៥

[27] សាស្ត្រាចារ្យហៀងសាងៈ នីតិរដ្ឋបាលទូទៅ ឆ្នាំ២០១៧ (បោះពុម្ពលើកទី៣) ទំព័រទី២២៦

[28] សាស្ត្រាចារ្យហៀងសាងៈ នីតិរដ្ឋបាលទូទៅ ឆ្នាំ២០១៧ (បោះពុម្ពលើកទី៣) ទំព័រ២២៧

# ជំពូកទី២
# ការផ្តល់សេវាសាធារណៈ
# នៃរដ្ឋបាលឃុំ សង្កាត់

# ជំពូកទី២
# ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់

## ២.១. ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ឃុំ សង្កាត់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបញ្ជាក់ពីលទ្ធិប្រជាធិបតេយ្យកម្រិតទាបបំផុតនៅថ្នាក់មូលដ្ឋាន។

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់នៅក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់រាជធានី ខេត្តពាក់ព័ន្ធត្រូវសម្រេចដោយ អនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ តែក្នុងករណីដែលមានការពាក់ព័ន្ធដល់ព្រំប្រទល់របស់រាជធានី ខេត្តពាក់ព័ន្ធនោះការបង្កើត ការលុបចោល ជាពិសេសការកែប្រែព្រំប្រទល់ និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់នេះ ត្រូវសម្រេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រីផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[29]

យើងដឹងហើយថាឃុំ សង្កាត់ជានីតិបុគ្គល ដូចនេះរដ្ឋបាលឃុំ សង្កាត់នេះ មិនមែនជាមណ្ឌលរដ្ឋបាលដូចមុនទៀតទេ។ ផ្ទុយទៅវិញឃុំ សង្កាត់ ក្លាយទៅជាសមូហភាពដែនដីមួយដែលមានស្វ័យភាព។

ឃុំ សង្កាត់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងចន្លោះពីឆ្នាំ១៩០៣ និងឆ្នាំ១៩០៤ ដោយរបបអាណានិគមបារាំង ហើយត្រូវបានបញ្ជាក់ជាបន្តបន្ទាប់។ ព្រះរាជក្រឹត្យ ត្រូវបានប្រកាសឱ្យប្រើនូវថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩០៨ និងព្រះរាជក្រឹត្យប្រកាសឱ្យប្រើចុះថ្ងៃ២៤ ខែកញ្ញា ឆ្នាំ១៩១៩ ហើយជាពិសេសនោះ គឺដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់ចំណុចមាត្រា១៤៥ថ្មី។

### ២.១.១. ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

#### ក. ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានកំណត់ឱ្យជ្រើសរើសឡើងតាមរយៈការបោះឆ្នោតដោយផ្ទាល់ពីសំណាក់បងប្អូនប្រជាពលរដ្ឋនៃឃុំ សង្កាត់ របស់ខ្លួនស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។[30] ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាអង្គការតំណាងឱ្យប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ របស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ មានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ ថ្មីចូលកាន់មុខតំណែង។

#### ខ. រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ចៅសង្កាត់។

មេឃុំ ចៅសង្កាត់ មានអ្នកជំនួយការដូចខាងក្រោម៖ ចំពោះមេឃុំ អ្នកជំនួយការមានពីររូប៖

- ជំទប់ទី១ មួយរូប
- ជំទប់ទី២ មួយរូប ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប

[29] មាត្រា៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[30] មាត្រា១០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

- ចៅសង្កាត់រងទី១ មួយរូប និងចៅសង្កាត់រងទី២ មួយរូប។[31]

មេឃុំ ចៅសង្កាត់ មានសិទ្ធិចាត់តាំងគណកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់។ គណកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមាន សិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់ របស់ខ្លួនក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន។[32]

ឃុំ សង្កាត់ ត្រូវមានបុគ្គលិកក្របខណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូប ធ្វើជាស្មៀនឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ តែងតាំង ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់អនុលោមតាមការសម្រេច របស់ក្រុមប្រឹក្សាឃុំ សង្កាត់។[33] ឃុំ សង្កាត់ អាចជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការ និងការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិ ហើយអាចបន្ត ការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាអាណត្តិបន្ទាប់។

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងក្រុមប្រឹក្សាឃុំ សង្កាត់ នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់សម្រាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន។ មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូប និងសមាជិកមួយរូបជា ជំនួយការ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និងការតែងតាំងជំនួយការមេភូមិ។[34]

**មេភូមិមានភារកិច្ចៈ**

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យ ដើម្បីធានា សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ដើម្បីចាត់ចែង និងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារ និងភារកិច្ចរបស់ភូមិឱ្យបានសមស្រប។[35] ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសំឡេងឆ្នោតច្រើនជាងគេបង្អស់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ មានអាណត្តិស្មើនឹងអាណត្តិ របស់ក្រុមប្រឹក្សាឃុំ សង្កាត់។[36] ជំទប់ទី១ ចៅសង្កាត់រងទី១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះ និងលេខរៀង លើគេនៃបញ្ជីបេក្ខជនដែលបានទទួលសំឡេងឆ្នោតនៅលំដាប់ទី២។ ជំទប់ទី២ ចៅសង្កាត់រងទី២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខ

---

31 មាត្រា២៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

32 មាត្រា២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

33 មាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

34 មាត្រា៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

35 មាត្រា៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

36 មាត្រា៣២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

រៀងលើគេនៃបញ្ជីបេក្ខជន ដែលបានទទួលបានសំឡេងឆ្នោតលំដាប់ទី៣។[37] ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ណា បានផ្តល់ សំឡេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២។ ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើស សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ណាបានផ្តល់សំឡេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សាត្រូវជ្រើសរើស សមាជិកក្រុមប្រឹក្សាជាបេក្ខជនដែលមាន ឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសំឡេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួល តំណែងជាជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាបេក្ខជនដែល មានឈ្មោះលេខរៀងលើគេបង្អស់នៃបញ្ជីដែលបានទទួលសំឡេងឆ្នោតគាំទ្រលំដាប់ទី២ឱ្យទទួលតំណែងជា ជំទប់ទី២ ឬចៅសង្កាត់រងទី២។ តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់ បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់ តាមលក្ខខណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា១៦ នៃច្បាប់នេះ។ មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់ និងមុខតំណែងជាសមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ កាល បើមុខតំណែងណាមួយត្រូវបាត់បង់មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ។ ក្នុងករណីខាង លើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរតាមលក្ខខណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី២ មាត្រា១៦ នៃច្បាប់នេះ។ ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ចេញពីក្នុងបញ្ជីបេក្ខជនជាមួយផ្អែកតាមលក្ខខណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី២ មាត្រា១៦ នៃច្បាប់នេះ និងចាត់ឱ្យ សមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ ជំនួស ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែង។ ផ្អែកតាមលក្ខខណ្ឌខាងលើនេះ ការបាត់បង់មុខតំណែង និងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយពេលយ៉ាងយូរ១៤ថ្ងៃ។[38]

តំណែងជាជំទប់ទី១ ឬចៅសង្កាត់រងទី១ តំណែងជាជំទប់ទី២ ឬចៅសង្កាត់រងទី២ ត្រូវបាត់បង់ពីមុខតំណែងក្នុងករណីដែលសាមី ខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់ តាមលក្ខខណ្ឌដូចមានចែង ក្នុងវាក្យខ័ណ្ឌទី១ មាត្រា១៦ នៃច្បាប់នេះ។ ក្នុងករណីតំណែង ជាជំទប់ទី១ ឬចៅសង្កាត់រងទី១ តំណែងជាជំទប់ទី២ ឬចៅសង្កាត់រងទី២ ត្រូវបានបាត់បង់មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ។ ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជន

[37] មាត្រា៣៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[38] មាត្រា៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយហ្នឹងជំទប់ទី១ ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២ ឱ្យទទួល តំណែងជំនួសជំទប់ ឬចៅសង្កាត់រង ដែលបានបាត់បង់ពីមុខតំណែង និងត្រូវជ្រើសរើស សមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរតាមលក្ខខណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី២ មាត្រា១៦ នៃច្បាប់នេះ។ ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី១ ឬចៅសង្កាត់ រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២ អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី២ មាត្រា១៦ នឹងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែង ជាជំទប់ទី១ ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២ ជំនួសតំណែងជំទប់ទី១ ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២ ដែលបានបាត់បង់ពីមុខតំណែង។ ផ្អែកតាមលក្ខខណ្ឌខាងលើនេះ និងលក្ខខណ្ឌដែលបានចែងក្នុងមាត្រា៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែង និងការទទួលតំណែងជាជំទប់ទី១ ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុង រយពេលយ៉ាងយូរ១៤ថ្ងៃ។[39]

**មេឃុំ ចៅសង្កាត់ បំពេញតួនាទីភារកិច្ចដូចខាងក្រោម៖**

- អនុវត្តសេចក្តីសម្រេចក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិ និងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំផែនការហិរញ្ញវត្ថុ និងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាច របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខ្លួនប្រគល់ឱ្យ។[40]

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យ និងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រងនៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន។ ជំទប់ ឬចៅសង្កាត់រងត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោមជំទប់ទី១ ឬ ចៅសង្កាត់រងទី១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជំទប់ទី២ ឬចៅសង្កាត់រងទី២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវា សាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ។ ចំពោះមេឃុំ ចៅសង្កាត់ អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែងខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន។[41]

### គ. តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

ក្រុមប្រឹក្សារដ្ឋបាលឃុំ សង្កាត់ មានតួនាទីពីរប្រភេទគឺ៖

- តួនាទីបំរើកិច្ចការមូលដ្ឋានសម្រាប់បំរើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋ របស់ខ្លួន
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។[42]

[39] មាត្រា៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[40] មាត្រា៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[41] មាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[42] មាត្រា៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

**គ១. តួនាទីបម្រើកិច្ចការមូលដ្ឋាន**

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះ ដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់ អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។[43]

**គ២. តួនាទីជាភ្នាក់ងារតំណាងរដ្ឋ**

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះអាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវការបង្កើន សមត្ថភាព និងផ្គត់ផ្គង់ មធ្យោបាយ សម្ភារៈ ថវិកា សម្រេចអនុវត្ត។ ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ តែប៉ុណ្ណោះ។[44]

**២.១.១.១. ការតាមដាន ការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសម្រាប់ធ្វើការតាមដាន និងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ ដើម្បី ពិនិត្យមើលអំពីអត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាច និងការបំពេញតួនាទីភារកិច្ចរបស់ឃុំ សង្កាត់ នីមួយៗ ជាពិសេសពិនិត្យមើលការវិវឌ្ឍន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់ នានារួមទាំងការប៉ាន់ប្រមាណអំពីការធ្វើអន្តរាគមន៍ និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាច និងការបំពេញតួនាទីភារកិច្ច។ ក្នុងការតាមដាន និងត្រួតពិនិត្យ ការធ្វើអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចរំលែកអំណាចដល់មន្ត្រីដែលជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ។ ចំពោះឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់។ ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញ តាមលក្ខខណ្ឌទាំងឡាយនៃច្បាប់ដែលបានចែងដូចជាព្រះរាជក្រឹត្យ អនុក្រឹត្យ លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុង និងដីកាឃុំ សង្កាត់។

**ការតាមដាន ត្រួតពិនិត្យ និងធ្វើអន្តរាគមន៍រួមមានការងារៈ**

- ស៊ើបអង្កេត និងវាយតម្លៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ។[45]

[43] មាត្រា៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[44] មាត្រា៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[45] មាត្រា៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផល និងស្របទៅតាមទំហំនៃកិច្ចការ ដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវដោយភ្ជាប់ជាមួយនូវការណែនាំ និងការគាំទ្រសំខាន់ចាំបាច់ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អាចបំពេញភារកិច្ចដែលច្បាប់បានតម្រូវជាធម្មតា។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ។ កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ច ដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរាជរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់នោះជាបន្ទាន់ ហើយត្រូវធ្វើ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញទៅតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការ និងមុខការការងាររដ្ឋបាលមូលដ្ឋាន ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំអនុម័ត និងអនុវត្តនូវផែនការអភិវឌ្ឍឃុំ សង្កាត់ ក្នុងគោលបំណងកំណត់នូវទស្សនវិស័យកម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។ ផែនការអភិវឌ្ឍឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិ។ ផែនការអភិវឌ្ឍឃុំ សង្កាត់ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងឆ្នាំទី១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំដោយក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខ្លួន។

**ក្នុងការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចាត់វិធានការដូចតទៅៈ**

- វាយតម្លៃអំពីកម្រិតអត្ថិភាពនៃការអភិវឌ្ឍ និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់ របស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់ និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់ មាន និងធនធានដែលបានទទួល
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានាតាមរយការផ្តល់សេវា និងការអភិវឌ្ឍហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ផ្តល់សេវា និងការអភិវឌ្ឍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យ តាមដាន និងវាយតម្លៃចំពោះលទ្ធផលនៃការអនុវត្តន៍ផែនការអភិវឌ្ឍ
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតម្លៃអំពីកម្រិតនៃការអភិវឌ្ឍថ្មីៗក្នុងឃុំ សង្កាត់ របស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់ ជូនប្រជាពលរដ្ឋរបស់ខ្លួន។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការការអភិវឌ្ឍឃុំ សង្កាត់ របស់ខ្លួន។[46] ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទីស្ថិតិ និងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រ និងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល។ ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ណាមួយធ្វើឡើងមិនស្របតាមលក្ខខណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ កែតម្រូវផែនការរបស់ខ្លួនឱ្យបានសម ស្របក្នុងអំឡុងពេលយ៉ាងយូរ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចំលងនៃផែនការនោះ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍឃុំ សង្កាត់ របស់ខ្លួនឱ្យបានសមស្របតាម ការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរាល់ការអនុវត្តផែនការ កម្មវិធី គម្រោង និងការផ្តល់សេវានានាប្រកបដោយតម្លាភាព និងមានការទទួលខុសត្រូវខ្ពស់។ ក្រុមប្រឹក្សាឃុំ សង្កាត់ នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ចំពោះផែនការកម្មវិធី និងគម្រោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយ ដែលខ្លួនបានជ្រើសយក។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់ អំពីវិធីផ្សេងៗក្នុងការអនុវត្តផែនការ និងក្នុងការត្រួតពិនិត្យ វាយតម្លៃចំពោះការប្រើប្រាស់មូលនិធិសម្រាប់ផែនការអភិវឌ្ឍឃុំ សង្កាត់។[47]

**ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពីៈ**

- កិច្ចការជាអាទិភាព គោលដៅសម្រាប់ផ្តល់សេវា និងគម្រោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ នាឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាពគោលដៅសម្រាប់ផ្តល់សេវា និងគម្រោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់
- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក
- កិច្ចការជាអាទិភាព គោលដៅសម្រាប់ផ្តល់សេវា និងគម្រោងផែនការអភិវឌ្ឍរបស់ឃុំ សង្កាត់ ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ។[48]

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា៦៩ នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តម្កល់ទុកជាសាធារណៈ និងចម្លងចែកជូនអង្គការសមាគម និងសាធារណៈជនសំខាន់ៗ ដោយគិតត្រឹមថ្លៃដើម។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗ ដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងនៅក្នុងមាត្រា៦៩ និងមាត្រា៧០ នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលនៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់។

[46] មាត្រា៦៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[47] មាត្រា៦៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[48] មាត្រា៦៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទបញ្ញត្តិនានាដែលបានចែងក្នុងជំពូកទី៦នៃច្បាប់នេះ។

**២.១.១.២. ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ សង្កាត់**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់។ ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗ។ ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យ និងពន្ធនៃការជួល។ ក្នុងករណីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូល នេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់។ ប្រភេទកម្រិត និងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗខាងលើនេះត្រូវកំណត់ដោយច្បាប់។ ឃុំ សង្កាត់ មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលសម្រាប់ថវិការបស់ខ្លួន។

**ធនធានវិភាជន៍នេះរួមមានៈ**

- ការផ្ទេរទាំងមូល ឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាន និងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ។ ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់ តាមរតនាគារខេត្ត ក្រុង។ ការរៀបចំ និងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ។[49]

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កម្រៃចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត។ ប្រាក់កម្រៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗ ដែលឃុំ សង្កាត់ ទទួលបានពីប្រាក់ចំណូលរដ្ឋ។ រាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាល ត្រូវផ្តល់កម្រៃសមស្របដល់ឃុំ សង្កាត់ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ។ ក្នុងករណីដែលការប្រគល់អំណាចមុខងាររបស់រដ្ឋមានលក្ខណជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយពេលយូរអង្វែងសម្រាប់ផ្តល់ឱ្យឃុំ សង្កាត់។ ការរៀបចំប្រាក់កម្រៃខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។ រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់។ មូលនិធិឃុំ សង្កាត់ បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំនេញពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់។ ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្ត ឬតាមអត្រាជាក់លាក់ មួយសម្រាប់ថេរៈវេលាយ៉ាងតិច៣ឆ្នាំ និងមិនលើសពី៥ឆ្នាំ ដែលកំណត់ដោយអនុក្រឹត្យ។ នីតិវិធីអនុវត្តជាក់ស្តែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ។ មូលនិធិឃុំ សង្កាត់បានមកពីការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ អនុប្បទាន និងការខ្ចីពីប្រភពក្នុងប្រទេស និងក្រៅប្រទេស។ ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ។ របៀបរបបចាត់ចែងវិធាននៃការប្រើប្រាស់ និងនីតិវិធីនៃការបើកប្រាក់ចំណាយពីមូលនិធិឃុំ សង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យ។ ឃុំ សង្កាត់ត្រូវរៀបចំ និងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ។ ថវិកាឃុំ សង្កាត់ ត្រូវរៀបចំទៅតាមទំរង់មួយ និងអនុម័តនៅ

[49] មាត្រា៧៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

ក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទ មួយអនុលោមទៅតាមប្រព័ន្ធថវិកាជាតិ។ ថវិកាឃុំ សង្កាត់ ត្រូវមានតុល្យភាពរវាងចំណូលសរុប និងចំណាយសរុប។ ឃុំ សង្កាត់ អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន។ ថវិកាឃុំ សង្កាត់ ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាព និងសេចក្តីត្រូវការនៃផែនការអភិវឌ្ឍ និងកម្មវិធីនយោបាយរបស់ឃុំ សង្កាត់។ នីតិវិធីនៃការរៀបចំ និងការអនុម័តថវិកាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ។ ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ។ ឃុំ សង្កាត់ មិនអាចធានារ៉ាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ។ ឃុំ សង្កាត់ មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋ មកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់។ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនអែង និងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ។ ឃុំ សង្កាត់ អាចប្រើប្រាស់ និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង។ ឃុំ សង្កាត់ ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យបានគង់វង្សហើយទ្រព្យសម្បត្តិទាំងនោះឃុំ សង្កាត់ គ្មានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ។ នីតិវិធីចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ។[50]

ឃុំ សង្កាត់ ត្រូវបង្កើតឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាន និងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួនដែលក្នុងនោះរួមមាន៖

- បទដ្ឋានហិរញ្ញវត្ថុ និងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ
- ការចាត់ចែងគ្រប់គ្រងទ្រព្យសម្បត្តិ៖ តម្រូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវ។ ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាន និងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ។[51]

របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ។[52]

### ២.១.២. តួនាទី និងភារកិច្ចរបស់អង្គភាពទទួលបន្ទុក

នៅក្នុងការបំពេញភារកិច្ចមេឃុំ ចៅសង្កាត់ ត្រូវផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ព្រមទាំងត្រូវមានអព្យាក្រឹតភាពនៅក្នុងសកម្មភាពការងាររបស់ខ្លួន។

#### ២.១.២.១. ក្នុងឋានៈតំណាងឱ្យរាស្ត្រប្រជា

**ក្នុងឋានៈតំណាងឱ្យរាស្ត្រប្រជា**

- ការពារផលប្រយោជន៍រាស្ត្រប្រជាដែលរស់នៅក្នុងឃុំ សង្កាត់
- ការពារ និងគោរពសិទ្ធិសេរីភាពរបស់រាស្ត្រប្រជាក្នុងឃុំ សង្កាត់
- ការណែនាំប្រជាពលរដ្ឋក្នុងការតវ៉ា ឬធ្វើសំណើទៅអាជ្ញាធរដែលពាក់ព័ន្ធ ឬធ្វើបណ្តឹងទៅតុលាការដើម្បីការពារផលប្រយោជន៍របស់រាស្ត្រប្រជានៅក្នុងឃុំ សង្កាត់

[50] មាត្រា៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[51] មាត្រា៨២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[52] មាត្រា៨៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

- បំផុសប្រជាជនឱ្យបំពេញកាតព្វកិច្ចដែលជាផលប្រយោជន៍រួមរបស់ឃុំ សង្កាត់ ឧទាហរណ៍៖ ជួសជុលផ្លូវ ដាំដើមឈើជាដើម
- ផ្តល់មតិទៅអាជ្ញាធររដ្ឋបាលថ្នាក់លើពីបញ្ហាដែលពាក់ព័ន្ធផលប្រយោជន៍រាស្ត្រប្រជា។

**២.១.២.២. ក្នុងឋានៈតំណាងឱ្យរដ្ឋ**

- ជាអ្នកទទួលខុសត្រូវចំពោះការដឹកនាំរដ្ឋបាលឃុំ សង្កាត់ និងនយោបាយនៅក្នុងឃុំ សង្កាត់
- គ្រប់គ្រង និងធ្វើស្ថិតិប្រជាជន
- គ្រប់គ្រងបញ្ជីរាយនាមប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត និងស្ថិតិជនបរទេស
- ដឹកនាំនគរបាលប៉ុស្តិ៍រដ្ឋបាល
- ជាមន្ត្រីអត្រានុកូលដ្ឋាន "ក៣"
- សហការ និងជួយដល់មន្ត្រីពន្ធដារ ដែលមានបេសកម្មប្រមូលពន្ធដារនៅក្នុងឃុំ សង្កាត់របស់ខ្លួន
- សហការជាមួយឃុំ សង្កាត់ ដែលមាននៅជិតព្រំប្រទល់គ្នានៅក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ និងបង្ការបង្ក្រាបបទល្មើសនានា។

## ២.១.៣. ការត្រួតពិនិត្យ លើរដ្ឋបាលឃុំ សង្កាត់

### ២.១.៣.១. ការត្រួតពិនិត្យលើអង្គការឃុំ សង្កាត់

ជាការត្រួតពិនិត្យលើសមាសឃុំ សង្កាត់ និងគណនេយ្យកររបស់ឃុំ សង្កាត់គឺ៖

- ទាក់ទងបេក្ខភាពជាមេឃុំ ចៅសង្កាត់ បញ្ជីឈ្មោះសមាជិក ក្រុមប្រឹក្សា ឃុំ សង្កាត់។ ទាក់ទងទៅនឹងការតែងតាំងស្មៀនឃុំ សង្កាត់ ដោយអាជ្ញាធរ រដ្ឋបាលថ្នាក់ជាតិ ពោលគឺស្មៀនឃុំ សង្កាត់ ត្រូវតែងតាំងតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីធ្វើការតាមដានរាល់សកម្មភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់
- បញ្ហាហិរញ្ញវត្ថុវិញ គណនេយ្យរាជធានី ខេត្ត ក្រុង ត្រូវជ្រើសតាំងជាគណនេយ្យករ ឃុំ សង្កាត់។ តែជាគណនេយ្យករដែលត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សរុបមកអាជ្ញាធររដ្ឋបាលថ្នាក់ជាតិ នៅតែមានវត្តមានយ៉ាងសំខាន់ នៅក្នុងរដ្ឋបាលឃុំ សង្កាត់ ប្រយោជន៍ដើម្បីធ្វើការត្រួតពិនិត្យលើមនុស្សក៏ដូចជាសកម្មភាពរបស់រដ្ឋបាលឃុំ សង្កាត់។

### ២.១.៣.២. ការត្រួតពិនិត្យលើសេចក្តីសម្រេច

**ក. ផ្នែករដ្ឋបាល**

រាល់សេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់ ដែលមានខ្លឹមសារផ្ទុយពី រដ្ឋធម្មនុញ្ញ សន្ធិសញ្ញា ច្បាប់ បទបញ្ជា និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតត្រូវមោឃភាពដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នេះជាការត្រួតពិនិត្យអាណាព្យាបាលភាព(បច្ឆាកាល)។

**ខ. ផ្នែកហិរញ្ញវត្ថុ**

រាល់គម្រោងថវិការបស់ឃុំ សង្កាត់ មុននឹងអនុម័តត្រូវដាក់ជូនទៅអភិបាលរាជធានី ខេត្ត ក្រុងជាមុនសិន ដើម្បីត្រួតពិនិត្យអនុលោមភាពថវិកា។ នៅក្នុងករណីផ្ទុយនឹងអនុលោមភាព ដែលកំណត់ឡើងដោយអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០២ ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ នោះអភិបាលរាជធានី

ខេត្ត ក្រុង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឃុំ សង្កាត់ ដើម្បីធ្វើការកែតម្រូវឡើងវិញ។ នៅក្នុងករណីដែលរដ្ឋបាលឃុំ សង្កាត់ មិនយល់ព្រមមានតែរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប៉ុណ្ណោះ ដែលជាអ្នកសម្រេចចុងក្រោយ។

## ២.២. នីតិវិធីចំពោះការងារអត្រានុកូលដ្ឋាន នៃរដ្ឋបាលឃុំ សង្កាត់

មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ទទួលពិនិត្យកត់ត្រារឿងហេតុសំខាន់ៗ ដែលទាក់ទងនឹង កំណើត អាពាហ៍ពិពាហ៍ មរណភាពចូលទៅក្នុងសៀវភៅអត្រានុកូលដ្ឋាន និងចេញសេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋាននៅក្នុងឆ្នាំដែលមិនទាន់ដាច់ ហើយត្រូវធ្វើការកែតម្រូវអក្ខរាវិរុទ្ធលើអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ និងធ្វើការកែតម្រូវ ឬបដិសេធអត្រានុកូលដ្ឋានតាមអំណាចសាលក្រមស្ពាលរបស់តុលាការ ឬតាមបទប្បញ្ញត្តិច្បាប់។

### ២.២.១. នីតិវិធីរដ្ឋបាលមន្ត្រីមានសមត្ថកិច្ចនៃរដ្ឋបាលឃុំ សង្កាត់

#### ២.២.១.១. មេឃុំ ចៅសង្កាត់

មេឃុំ ចៅសង្កាត់ មន្ត្រីអត្រានុកូលដ្ឋានត្រូវមានការទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋានដែលខ្លួនបានអនុវត្ត និងមានភារកិច្ចចុះហត្ថលេខានិងបោះត្រាលើសំបុត្រអត្រានុកូលដ្ឋាន និងមានសិទ្ធចេញលិខិតអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និងរៀបពិធីបុណ្យសពបូជាបញ្ចុះសព។

មន្ត្រីអត្រានុកូលដ្ឋានត្រូវសហការជាមួយសមត្ថកិច្ចមូលដ្ឋាន ទាក់ទងនឹងការងារអត្រានុកូលដ្ឋាន និងធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ របស់ខ្លួន ឱ្យបានយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនក្នុងការងារអត្រានុកូលដ្ឋានហើយត្រូវបង្កឱ្យមានលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមកទំនាក់ទំនងអត្រានុកូលដ្ឋាន។ មេឃុំ ចៅសង្កាត់ដែលជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវតែធ្វើរបាយការណ៍អំពីស្ថិតិនៃចំនួនគ្រួសារជាប្រចាំ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ដែលបានមកសុំចុះសំបុត្រអត្រានុកូលដ្ឋាន ក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើត អាពាហ៍ពិពាហ៍ និងមរណភាពជារៀងរាល់ខែ និងរាល់ដំណាច់ឆ្នាំនីមួយៗ ហើយត្រូវផ្ញើរជូនទៅសាលាស្រុក ឬសាលាខណ្ឌសាមី។ មន្ត្រីអត្រាកូលដ្ឋានត្រូវបញ្ជូនសៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលដាច់យកទៅតម្កល់នៅសាលាស្រុក ឬសាលាខណ្ឌផ្ទាល់ ០១ច្បាប់ និងបញ្ជូនទៅសាលាខេត្ត ឬក្រុងចំនួន០១ច្បាប់។[53]

#### ២.២.១.២. ជំទប់ ឬមេឃុំចៅសង្កាត់រង

នៅពេលដែលមន្ត្រីអត្រានុកូលដ្ឋានអវត្តមាន មិនបានមកបំពេញភារកិច្ចរបស់ខ្លួននោះ ភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានជាបន្ទុករបស់ជំទប់ទីមួយ និងទីពីរ។ ជំទប់ គឺសំដៅលើមេឃុំ ឬចៅស្កាត់រង គឺជាជំនួយការរបស់មេឃុំចៅសង្កាត់ ក្នុងការអនុវត្តភារកិច្ច និងជំនួសឱ្យមេឃុំ ចៅសង្កាត់ ទៅតាមឋានានុក្រម នៃជំទប់នៅពេលមេឃុំ ចៅសង្កាត់អវត្តមាន ជំទប់ ឬចៅសង្កាត់រងអនុវត្តភារកិច្ចលើកិច្ចការរដ្ឋបាល សង្គមកិច្ច ការងារចរន្តសេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈហើយត្រូវទទួលអនុវត្តរាល់ភារកិច្ចបន្ថែមពីលើភារកិច្ចទាំងអស់នេះ ដែលមេឃុំ ឬចៅសង្កាត់ សម្រេចដាក់ឱ្យប្រតិបត្តិ។

ក្នុងករណីតំណែងជំទប់ទី១ ឬចៅសង្កាត់ទី១ ជំទប់ទី២ ឬចៅសង្កាត់ទី២ ត្រូវបានបាត់បង់តំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជននោះក៏ត្រូវបាត់បង់ព្រមពេលជាមួយគ្នាដែរ។ ករណីនេះត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជន ដើម្បីឱ្យទទួល

[53] មាត្រា៩ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០

តំណែងជំនួសជំទប់ ឬមេឃុំ ចៅសង្កាត់រង ដែលបានបាត់បង់ពីតំណែង និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី មកជំនួសកន្លែង ដែលទំនេរផ្សេងទៀត។ ក្នុងករណីបញ្ជីបេក្ខជន ដែលត្រូវកាន់កាប់តំណែងជំទប់ទី១ ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅ សង្កាត់រងទី២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសបេក្ខជនចេញពីបញ្ជីនោះ បញ្ចូលជា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រគល់ឱ្យក្រុមប្រឹក្សារូបនោះទទួលតំណែងជំទប់ទី១ ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២ ដែលបានបាត់បង់ពីមុខតំណែង។ ការបាត់បង់មុខតំណែង និងការទទួលតំណែងជាជំទប់ទី១ ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២ ត្រូវធ្វើដោយប្រកាសរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងយូរ១៤ថ្ងៃ។[54]

### ២.២.១.៣. ការងារអត្រានុកូលដ្ឋាន

នៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ននេះការផ្តល់សេវាសាធារណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការគ្រប់គ្រងរដ្ឋបាលដែនដីនៅព្រះរាជាណាចក្រឱ្យមានសណ្តាប់ធ្នាប់ល្អ និងការរស់នៅប្រកបដោយចីរភាព។ ដោយហេតុថាប្រជាពលរដ្ឋយើងភាគច្រើនមិនសូវចាប់អារម្មណ៍ និងស្វែងយល់ច្បាស់ពីកិច្ចការអត្រានុកូលដ្ឋាន និងសារៈប្រយោជន៍នោះទេ ប៉ុន្តែពួកគាត់ដឹងច្បាស់អំពីអត្ថប្រយោជន៍ថាមានតម្រូវការចាំបាច់ដែលច្បាប់មានជាអាទិ៍។ ដោយពួកគាត់ស្វែងយល់ច្បាស់ពេលដែលពួកគាត់ត្រូវបញ្ជូនកូនចូលរៀនត្រង់ពេលចុះឈ្មោះ ធ្វើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៅពេលដែលពួកគាត់មានតម្រូវការរៀបអាពាហ៍ពិពាហ៍ មានសមាជិកគ្រួសាររបស់ពួកគាត់ទទួលមរណភាព ឬមានតម្រូវការផ្សេងៗទៀតជាដើម ដែលជាហេតុធ្វើឱ្យពួកគាត ភ្ញាក់ខ្លួនចាំបាច់ត្រូវតែធ្វើកិច្ចការទាំងនេះ។ ដោយចង់ឱ្យប្រជាពលរដ្ឋទាំងអស់ស្វែងយល់ឱ្យច្បាស់អំពី លិខិតអត្រានុកូលដ្ឋានកំណើត លិខិតអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងលិខិតអត្រានុកូលដ្ឋានមរណៈភាព ដែលគេអាចហៅម្យ៉ាងទៀតយ៉ាងខ្លីបានថា កើត ការ កប់។

ក្នុងនោះរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានចែកចេញជាបីថ្នាក់ដូចជា៖

- រដ្ឋបាលរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រដ្ឋបាលឃុំ សង្កាត់

ដោយឡែកពាក្យថា អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់គ្នារវាងសញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែងដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ ក្នុងន័យឱ្យជននោះទទួលបានសិទ្ធិពេញលេញព្រមទាំងសេរីភាពត្រឹមត្រូវ និងមានករណីយកិច្ច។ បើយើងនិយាយពីសំបុត្រអត្រានុកូលដ្ឋានវិញ គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃប្រជាពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែនដីដែលមានសមត្ថកិច្ចកំណត់ នៃច្បាប់ព្រះរាជាណាចក្រកម្ពុជា។[55]

[54] មាត្រា៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា

[55] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ទំព័រទី១២ ឆ្នាំ២០០៥

**ចំពោះសំបុត្រអត្រានុកូលដ្ឋាននេះបីប្រភេទ៖**

- សំបុត្រកំណើត
- សំបុត្រអាពាហ៍ពិពាហ៍
- សំបុត្រមរណភាព

### ២.២.១.៤. អត្រានុកូលដ្ឋានកំណើត

**ក. និយមន័យ**

កំណើតជាព្រឹត្តិការណ៍គតិយុត្តដែលនាំឱ្យកើតមាននូវរូបវន្តបុគ្គលពោល គឺជាការចាប់ផ្ដើមកកើតនូវសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលគ្រប់រូប។ ដើម្បីឱ្យបានក្លាយជារូបវន្តបុគ្គលត្រូវមានលក្ខខណ្ឌពីរយ៉ាងគឺ៖

- កើតមកជាមនុស្ស
- កើតមករស់ ហើយអាចនឹងរស់បាន។[56]

**ខ. សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងកំណើត**

សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងកំណើតរួមមាន៖

- សៀវភៅអត្រានុកូលដ្ឋានកំណើត (សម្រាប់ប្រជាពលរដ្ឋខ្មែរ)
- សៀវភៅអត្រានុកូលដ្ឋានកំណើតសម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត

ចំពោះសៀវភៅចម្លងសំបុត្រកំណើត និងចម្លងសំបុត្របញ្ជាក់កំណើត មិនចាត់ទុកជាសៀវភៅអត្រានុកូលដ្ឋាននោះទេ។

**គ. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើត**

ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើតរួមមាន៖

- សំបុត្រកំណើត
- សំបុត្របញ្ជាក់កំណើត
- សេចក្ដីចម្លងសំបុត្រកំណើត
- សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត។

**ឃ. នីតិវិធីនៃការធ្វើអត្រានុកូលដ្ឋានកំណើត**

បើមានទារកកើត ឪពុក ឬម្ដាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្ដាយទារកនោះ មិនឱ្យហួស ៣០ថ្ងៃ ដោយបញ្ជាក់ឱ្យបានច្បាស់ថា ឪពុក និងម្ដាយនៃទារកនោះ មានខាន់ស្លា ឬឥតខាន់ស្លា។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍ របស់ឪពុក និងម្ដាយទារកនោះ។ បើឪពុក ម្ដាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសណ្ដាន ឬអ្នកនៅជិតខាងដែលបានឃើញ និងដឹងឮផ្ទាល់ពីទារកនោះកើតឱ្យទៅចុះសៀវភៅកំណើត ឱ្យបានទាន់ពេលកំណត់ឱ្យបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក

[56] កម្រងឯកសារ ស្ដីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ទំព័រទី១ ឆ្នាំ២០០៥

និង ម្តាយទារកនោះជាប់ទៅជាមួយផង។[57] នាមត្រកូលរបស់ទារក អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬអាចយកឈ្មោះជីតាខាងឪពុក ឬអាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន។ ឪពុក ម្តាយ ឬអាណាព្យាបាល ជាអ្នកដាក់នាមខ្លួនឱ្យទារក។[58] បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬសង្កាត់ នៃទីកន្លែងដែលរើសបាននោះ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុ និងចុះក្នុងសៀវភៅកំណើត ដោយរកឈ្មោះដាក់ឱ្យ ហើយបើក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំកំណើតទារកដែលរើសបាននោះ ដោយស្មាន និងឈ្មោះឪពុក ម្តាយដាក់ថាមិនស្គាល់។ បើមានជនណា សុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ។ ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើសបាននោះ ទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ទារកនោះ និងកំណត់ហេតុស្តីអំពីការប្រគល់ទារកនោះ ជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា។[59] ទារកកើតពីឪពុក ម្តាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅកំណើតដែរ។ នៅពេលធ្វើសំបុត្រកំណើត បើឪពុកម្តាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះបានឆ្លើយទទួលស្គាល់ដោយដាក់លាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថាទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក ម្តាយ នោះថាជាឪពុក ម្តាយរបស់កូននោះ។ ករណីមានតែឪពុក ឬមានម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ ឯងប៉ុណ្ណោះ។ ក្រោយពេលឪពុក ឬម្តាយបានប្តឹងចុះក្នុងសៀវភៅកំណើត ឪពុក ឬម្តាយណា ដែលមិនទទួលស្គាល់ទារកនោះ ឪពុក ឬម្តាយនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន។ កូនឥតខាន់ស្លាដែលឪពុក ម្តាយបានទទួលស្គាល់នឹងទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឪពុក ម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា។ ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ធ្វើដំណាលគ្នានឹងពេលចុះអាពាហ៍ពិពាហ៍ ឬក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន។[60] ដោយយោងទៅតាម កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋានយើងបើទារកដែលកើតពីឪពុកម្តាយគ្មានចំណងមិត្តអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចាំបាច់ចុះក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើតដែរ៖

- ក្នុងករណីមានតឪពុក ឬមានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូន ដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ
- ក្រោយពេលឪពុក ឬម្តាយបានប្តឹងចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឪពុក ឬម្តាយណាដែលមិនទាន់ ទទួលស្គាល់ទារកនោះ ឪពុក ឬម្តាយនោះអាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន។ កូនឥតខាន់ស្លាដែលឪពុក ម្តាយបានទទួលស្គាល់ នឹងទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពី
- កំណើតកូននោះ ឪពុក ម្តាយរបស់កូននោះបានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា

---

[57] មាត្រា ១៧ អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពី អត្រានុកូលដ្ឋាន ឆ្នាំ២០០០

[58] មាត្រា ១៨ អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពី អត្រានុកូលដ្ឋាន ឆ្នាំ២០០០

[59] មាត្រា១៩ អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពី អត្រានុកូលដ្ឋាន ឆ្នាំ២០០០

[60] មាត្រា២៣ អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពី អត្រានុកូលដ្ឋាន ឆ្នាំ២០០០

- ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នានឹងពេលចុះអាពាហ៍ពិពាហ៍ ឬក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន។

**ង. ចំពោះលិខិតស្នាមនានា ដែលទាក់ទងនឹងទារកនៃឳពុក ម្តាយជាពលរដ្ឋខ្មែរ**

អ្នកទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសំបុត្រកំណើត ត្រូវបង្ហាញចំពោះមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួន ដូចខាងក្រោម៖

- លិខិតបញ្ជាក់ទទួលស្គាល់កំណើត
- លិខិតបញ្ជាក់របស់ឳពុកម្តាយទារក អំពីនាមត្រកូល នាមខ្លួន និង ថ្ងៃខែឆ្នាំកំណើតរបស់ទារក បើឳពុកម្តាយទារក ពឹងពាក់សាច់ញាតិ ឬអ្នកជិតខាងឱ្យទៅរាយការណ៍ជំនួស
- សំបុត្រកំណើតច្បាប់ដើមចាស់ ក្នុងករណី អ្នកកើតមុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយមានសំបុតកំណើតច្បាប់ដើម ដើម្បីប្តូរយកសំបុត្រកំណើតថ្មី
- សៀវភៅគ្រួសារដែលមានឈ្មោះឳពុក ម្តាយទារក (ប្រសិនបើមាន)
- សំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឳពុក ម្តាយទារក ( ប្រសិនបើមាន)។[61]

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកនូវលិខិតស្នាមចាំបាច់ពាក់ព័ន្ធនឹងកំណើតទារកក្នុងសំណុំឯកសារកំណើត នៅឃុំ ឬសង្កាត់

- លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងកើតរបស់ទារក បើទារកកើតនៅមន្ទីរពេទ្យ
- លិខិតបញ្ជាក់ទទួលស្គាល់របស់មេភូមិ បើទារកកើតនៅផ្ទះ
- កំណត់ហេតុអំពីកំណើតទារករបស់អ្នកទទួលខុសត្រូវពន្ធនាគារ បើទារកកើតនៅក្នុងពន្ធនាគារ
- លិខិតរបស់ឳពុក ម្តាយទារកបញ្ជាក់ពីនាមត្រកូល នាមខ្លួន និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារក (ករណីឳពុកម្តាយពឹងពាក់អ្នកដទៃឱ្យទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតជំនួស
- សំបុត្រកំណើតច្បាប់ដើមចាស់ ក្នុងករណី អ្នកកើតមុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយមានសំបុត្រកំណើតច្បាប់ដើម ដើម្បីប្តូរយកសំបុត្រកំណើតថ្មី។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់លិខិតស្នាមឱ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ពាក់ព័ន្ធនឹងកំណើតដែលត្រូវរក្សាទុក។[62]

**សម្រាប់ទារកដែលកើតចេញពីឳពុកម្តាយជាពលរដ្ឋខ្មែរ**

នៅពេលមានអ្នកមករាយការណ៍ សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសុំសំបុត្រកំណើត និងបន្ទាប់ពី បានពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរ ចុះបញ្ជីកំណើតចំនួន០២ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើតភ្លោះ។

---

[61] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ទំព័រ៦០

[62] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ទំព័រ៦០

**សម្រាប់ទារកដែលកើតចេញពីជនបរទេស និងជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់នៅក្នុងដែនដីព្រះរាជាណាចក្រកម្ពុជាយើង**

ជនបរទេស និងជនអន្តោប្រវេសន្តដែលបានរស់នៅស្របច្បាប់ ហើយបានកើតទារកនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឪពុកម្តាយទារកនោះ អាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់ ឬអាចទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន។

ចំពោះជនបរទេស ឬជនអន្តោប្រវេសន្តស្របច្បាប់ ការមករាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតត្រូវតែឪពុក និងម្តាយផ្ទាល់ទើបបាន គឺមិនអនុញ្ញាតឱ្យអ្នកដទៃមករាយការណ៍ជំនួសឡើយ។

**លិខិតស្នាមនានាដែលឪពុកម្តាយទារកត្រូវបង្ហាញមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតៈ**

- លិខិតស្នើសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត
- លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងកើតរបស់ទារក បើទារកកើតនៅមន្ទីរពេទ្យ
- លិខិតឆ្លងដែននៃប្រទេសសាមីរបស់ឪពុកម្តាយទារក និងទិដ្ឋាការដែលនៅមានសុពលភាព លិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាដែលនៅមានសុពលភាព (ចំពោះជនបរទេស ជនអន្តោប្រវេសន្ត)
- សំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍
- លិខិតស្នាមផ្លូវការផ្សេងៗដែលចេញដោយអាជ្ញាធរនៃប្រទេសសាមីឪពុកម្តាយទារក (ប្រសិនបើមាន)
- លិខិតស្នាមផ្លូវការផ្សេងៗ ដែលចេញដោយអាជ្ញាធរនៃព្រះរាជាណាចក្រកម្ពុជា (ប្រសិនបើមាន)

**មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងកំណើតទារកៈ**

- លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងកើតរបស់ទារក បើទារកកើតនៅមន្ទីរពេទ្យ
- ច្បាប់ថតចម្លងលិខិតឆ្លងដែន និងច្បាប់ថតចម្លងទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា
- លិខិតស្នើសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត
- ច្បាប់ថតចម្លងលិខិតស្នាមផ្លូវការផ្សេងៗ ដែលចេញដោយអាជ្ញាធរនៃព្រះរាជាណាចក្រកម្ពុជា ឬអាជ្ញាធរនៃប្រទេសសាមីរបស់ឪពុកម្តាយទារក (ប្រសិនបើមាន)។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យលិខិតស្នាមឱ្យបានច្បាស់លាស់ បើឃើញត្រឹមត្រូវតាមការកំណត់ខាងលើហើយទើបចាប់ផ្តើមសរសេរចូលបញ្ជីកំណើត ដោយអនុវត្តដូចគ្នានឹងការសរសេរចុះបញ្ជីកំណើត សម្រាប់ទារកពលរដ្ឋខ្មែរដែរ។

**ច. ការសរសេរសំបុត្រកំណើតច្បាប់ដើមមួយសន្លឹក**

ក្រោយពេលសរសេរចុះបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានកំណើតទាំងពីររួចហើយនាពេលនោះ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចូលទៅក្នុងសំបុត្រកំណើតច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្ន កុំឱ្យខុសពីខ្លឹមសារ នៅក្នុងបញ្ជីកំណើត។ បើសិនចំពោះការប្រគល់សំបុត្រកំណើតច្បាប់ដើមមួយសន្លឹកក្រោយពីសរសេរចុះហត្ថលេខា និងបោះត្រាលើបញ្ជីទាំងពីរ និងសំបុត្រកំណើតច្បាប់ដើមមួយសន្លឹករួចហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់សំបុត្រកំណើតច្បាប់ដើមនេះ ទៅឱ្យអ្នកមករាយការណ៍កំណើតទារកដែលបានស្នើសុំចុះសៀវភៅ

អត្រានុកូលដ្ឋានកំណើតដោយមិនបង់ថ្លៃអ្វីឡើយ និងណែនាំឱ្យរក្សាទុកដាក់ឱ្យបាន គង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្រកំណើតច្បាប់ដើម ជូនជាលើកទីពីរបានទេ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវជម្រាបអ្នកមករាយការណ៍ថា សំបុត្រកំណើតច្បាប់ដើម គឺជាឯកសារផ្ទាល់ខ្លួនមានតែមួយច្បាប់ប៉ុណ្ណោះ មិនត្រូវយកទៅប្រើប្រាស់ដោយភ្ជាប់ជាមួយឯកសារណាមួយនោះទេ ដូច្នេះគួរធ្វើសេចក្តីចម្លងសំបុត្រកំណើតឱ្យហើយដើម្បីងាយស្រួលក្នុងការប្រើប្រាស់។

**ឆ. ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងសំបុត្របញ្ជាក់កំណើត**

ពលរដ្ឋខ្មែរដែលកើតមុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយគ្មានសំបុត្រកំណើតច្បាប់ដើម អាចសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងសំបុត្របញ្ជាក់កំណើតបាន តាមគំរូណែនាំថ្មី នៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន០២រូប ជានីតិជន ហើយត្រូវមានទីលំនៅ ពិតប្រាកដ នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីក្រសួងស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះ សៀវភៅអត្រានុកូលដ្ឋានកំណើត មិនត្រូវខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬសោធននិវត្តន៍ជាផ្លូវការឡើយ។

**ជ. លិខិតស្នាមនានា ដែលទាក់ទងនឹងការបញ្ជាក់កំណើត**

**សាមីខ្លួន និងសាក្សី ត្រូវយកជាប់ជាមួយនូវលិខិតស្នាមចាំបាច់មួយចំនួន ដូចខាងក្រោម៖**

- សៀវភៅគ្រួសាររបស់សាមីខ្លួន និងរបស់សាក្សី
- អត្តសញ្ញាណបណ្ណរបស់សាមីខ្លួន និងរបស់សាក្សី (ប្រសិនបើមាន)
- ឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី បើជាមន្ត្រីរាជការ

**បើអាចធ្វើបាន មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងបញ្ជាក់កំណើត**

- ច្បាប់ថតចម្លងសៀវភៅគ្រួសាររបស់សាមីខ្លួន និងរបស់សាក្សី
- ច្បាប់ថតចម្លងអត្តសញ្ញាណបណ្ណរបស់សាមីខ្លួន និងរបស់សាក្សី
- ច្បាប់ថតចម្លងឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី បើជាមន្ត្រីរាជការ។

មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លិខិតស្នាមទៅឱ្យសាមីខ្លួន និងសាក្សីវិញ ក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក។

### ២.២.១.៥. អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

**ក. និយមន័យ**

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នា តាមបញ្ញត្តិច្បាប់ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន អាពាហ៍ពិពាហ៍នឹងមានអនុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របទៅតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។[63]

[63] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ទំព័រទី១

ការរៀបអាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្តពីភាគីទាំងពីរ។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ ហើយគ្មានជនណាមួយអាចបង្ខំបុគ្គលម្នាក់ឱ្យរៀបអាពាហ៍ពិពាហ៍ ឬរារាំងមិនឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយបើអាពាហ៍ពិពាហ៍នោះរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី មិនមែនជាការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ទេ។

នៅក្នុងមេរៀននេះ ការប្រើពាក្យថា "អាពាហ៍ពិពាហ៍" ក្នុងន័យថា "អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ឬការចុះបញ្ជីអាពាហ៍ពិពាហ៍" នៅចំពោះមុខមន្រ្តីអត្រានុកូលដ្ឋាន។

**ខ. ប្រភេទនៃការរៀបអាពាហ៍ពិពាហ៍**

ការរៀបអាពាហ៍ពិពាហ៍ មាន៤ប្រភេទ ដូចខាងក្រោម៖

- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅក្នុងប្រទេសកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ នៅក្នុងប្រទេសកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេសដែលរស់នៅស្របច្បាប់ នៅក្នុងប្រទេស
- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេសដែលកំពុងតែរស់នៅក្នុងប្រទេសកម្ពុជាស្របច្បាប់។

**គ. លក្ខខណ្ឌដែលអាចរៀបអាពាហ៍ពិពាហ៍បាន និងលក្ខខណ្ឌមិនអាចរៀបអាពាហ៍ពិពាហ៍**

**លក្ខខណ្ឌដែលអាចរៀបអាពាហ៍ពិពាហ៍បាន**

- បុរសត្រូវមានអាយុចាប់ពី ២០ឆ្នាំឡើង
- នារីត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើង
- ក្នុងករណីពិសេស បុរសដែលមានអាយុមិនគ្រប់២០ឆ្នាំ និងនារីមានអាយុមិនគ្រប់១៨ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ព្រមទាំងមានការយល់ព្រមពីឪពុក ម្តាយ ឬអាណាព្យាបាល
- ក្នុងករណីសហព័ទ្ធណាមួយបាត់ខ្លួនលើសពីមួយឆ្នាំ ដោយគ្មានអ្នកណាដឹងថាស្លាប់ ឬរស់ សហព័ទ្ធម្នាក់ទៀត អាចរៀបអាពាហ៍ពិពាហ៍ទៀតបាន បើផុតរយៈពេល១៥ថ្ងៃ ចាប់ពីថ្ងៃប្រកាសសាលក្រមដែលបញ្ជាក់ថាជននោះបានបាត់ខ្លួនពិតមែន ករណីនេះគ្មានជនណាអាចប្តឹងបដិសេធអាពាហ៍ពិពាហ៍ថ្មីនេះបានឡើយ ទោះជាសហព័ទ្ធដែលបាត់ខ្លួនត្រឡប់មកវិញក៏ដោយ។

**លក្ខខណ្ឌមិនអាចរៀបអាពាហ៍ពិពាហ៍៖**

- បុគ្គលមានភេទដូចគ្នា
- បុគ្គលគ្មានពលានុភាពនៃលិង្គ
- បុគ្គលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគដែលមិនទាន់បានព្យាបាលជាដាច់
- ជនវិកលចរិក មិនដឹងខុសត្រូវ
- បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ
- បុគ្គលដែលជាប់ចំណងសាច់ញាតិលោហិត (ញាតិដែលមានឈាមជាមួយគ្នា) ឬញាតិពន្ធ (សាច់ថ្លៃ) ក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះជាចំណងនោះមានខាន់ស្លា ឬឥតខាន់ស្លា ឬសាច់ញាតិចិញ្ចឹម។

**ឃ. សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍**

សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍ រួមមាន៖

- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ (សម្រាប់ប្រជាពលរដ្ឋខ្មែរ)
- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍

ចំពោះសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍មិនចាត់ទុកជាសៀវភៅអត្រានុកូលដ្ឋាននោះទេ។

**ង. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍**

ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍រួមមាន៖

- សំបុត្រអាពាហ៍ពិពាហ៍
- សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍
- សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

**ច. ការប្រកាសផ្សាយបណ្ណប្រកាសអាពាហ៍ពិពាហ៍ជាសាធារណៈ**

បុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាផ្លូវការ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី។

បុរស នារី ដែលមកសុំច្បាប់រៀបអាពាហ៍ពិពាហ៍ ត្រូវភ្ជាប់មកជាមួយនូវ

- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត
- លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ របស់សាមីខ្លួនទាំង២នាក់។ លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយទាំងពីរនាក់ ត្រូវចេញដោយមេឃុំ ចៅសង្កាត់សាមី
    - បើក្នុងករណីមេម៉ាយ ឬពោះម៉ាយ ដោយប្តី ឬប្រពន្ធស្លាប់ ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព
    - បើក្នុងករណីមេម៉ាយ ឬពោះម៉ាយដោយលែងលះត្រូវភ្ជាប់មកជាមួយនូវសាលក្រមតុលាការ
- សៀវភៅគ្រួសាររបស់សាមីខ្លួនទាំង២នាក់ (ប្រសិនបើមាន)

នៅពេលទទួលបានពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យឱ្យបានហ្មត់ចត់ចំពោះបុរស នារីដែលបានដាក់ពាក្យសុំនោះ

- បើពិនិត្យទៅឃើញថា មិនមានលក្ខណៈត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារទេ មន្ត្រីអត្រានុកូលដ្ឋាន មិនអាចអនុញ្ញាតឱ្យបុរស នារីនោះ រៀបអាពាហ៍ពិពាហ៍បានឡើយ
- បើពិនិត្យទៅឃើញថា មានលក្ខណៈត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចេញបណ្ណប្រកាសអាពាហ៍ពិពាហ៍ដែលគ្រោងនឹងធ្វើនោះជាសាធារណៈចំនួន៥ច្បាប់

- ០១ច្បាប់ បិទផ្សាយជាសាធារណៈ នៅលំនៅដ្ឋានសាមីខ្លួននារី
- ០១ច្បាប់ បិទផ្សាយជាសាធារណៈ នៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី
- ០១ច្បាប់ រក្សាទុកជាឯកសារនៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី
- ០២ច្បាប់ ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានខាងបុរស ដើម្បីយកទៅបិទផ្សាយនៅតាមទីសាធារណៈលំនៅដ្ឋានសាមីខ្លួនបុរស ដើម្បីយកទៅបិទផ្សាយជាសាធារណៈនៅលំនៅដ្ឋានសាមីខ្លួន០១ច្បាប់ និងនៅសាលឃុំ ឬសង្កាត់សាមីខ្លួនបុរស០១ច្បាប់។

បណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍-ពិពាហ៍ថ្ងៃចុះបញ្ជីអាពាហ៍ពិពាហ៍ដើម្បីឱ្យជនដែលមានផលប្រយោជន៍ ក្នុងរឿងនោះអាចប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ផុតរយៈពេល១០ថ្ងៃ អាពាហ៍ពិពាហ៍ អាចធ្វើទៅបាន បើគ្មានការប្ដឹងជំទាស់។ បើមានបណ្ដឹងជំទាស់ នឹងអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្ដឹងជំទាស់ត្រូវបានដោះស្រាយរួចរាល់តាមគោលការណ៍ដែលបានចែងក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។

**មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរបណ្ណប្រកាសអាពាហ៍ពិពាហ៍** :

- នាមត្រកូល និងនាមខ្លួន សញ្ជាតិ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ និងទីលំនៅបច្ចុប្បន្ននៃអនាគតប្ដី ឬប្រពន្ធ។
- នាមត្រកូល និងនាមខ្លួន ថ្ងៃខែឆ្នាំកំណើត មុខរបរ និងទីលំនៅបច្ចុប្បន្នរបស់ឪពុកម្ដាយ នៃអនាគតប្ដីប្រពន្ធ (បើឪពុក ឬម្ដាយស្លាប់ត្រូវដាក់ថាស្លាប់ផង)

**ឆ. ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍**

សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍ គឺសម្រាប់ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នា ក្នុងស្ថានភាពជាប្ដី ប្រពន្ធចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ និងពលរដ្ឋខ្មែរដែលបានរៀបអាពាហ៍ពិពាហ៍មុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយមានសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម។ ក្រោយរយៈពេល១០ថ្ងៃ នៃការបិទផ្សាយជាសាធារណៈនូវបណ្ណប្រកាសអាពាហ៍ពិពាហ៍ និងប្រសិនបើគ្មាន ការប្ដឹងជំទាស់អំពីអាពាហ៍ពិពាហ៍នេះទេសាមីខ្លួនទាំង២នាក់អាចសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសុំសំបុត្រអាពាហ៍ពិពាហ៍ ដែលចាត់ទុកជាការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដោយនាំទៅ ជាមួយនូវសាក្សីគ្រប់អាយុការ០២រូប សាក្សីជាភេទប្រុស ត្រូវមានអាយុចាប់ពី២០ឆ្នាំឡើងទៅ បើសាក្សីជាភេទស្រី ត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។ សាក្សីទាំង២រូប ត្រូវយកមកជាមួយនូវសៀវភៅគ្រួសារ ឬអត្តសញ្ញាណបណ្ណរបស់ខ្លួន។

- ក្នុងករណីប្ដី ប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ មុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយមានសំបុត្រអាពាហ៍ ពិពាហ៍ច្បាប់ដើមចាស់ នៅពេលមកសុំប្ដូរសំបុត្រអាពាហ៍ពិពាហ៍តាមគំរូថ្មី ត្រូវយកមកជាមួយនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមចាស់
- ក្នុងករណីសហព័ទ្ធណាម្នាក់ស្លាប់ សំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមចាស់ មិនអាចយកមកប្ដូរសំបុត្រអាពាហ៍ពិពាហ៍តាមគំរូថ្មីបានទេ។

## ជ. ការសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍

### ជ១. ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅក្នុងប្រទេស

- ប្រជាពលរដ្ឋខ្មែរដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ ត្រូវតែអនុវត្តទៅតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារជាធរមាន និងអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន
- មន្ត្រីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ នៃលំនៅដ្ឋាននារី ជាអធិបតីនៃពិធីរៀបអាពាហ៍ពិពាហ៍នេះ
- នៅពេលមានសាមីខ្លួនប្តី ប្រពន្ធមកសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសុំសំបុត្រអាពាហ៍ពិពាហ៍ និងបន្ទាប់ពីពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវ ទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍ចំនួន០២ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ភ្លោះ
- របៀបសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍ នៃសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ដែលបានចុះលេខ និងចុះឆ្នាំរួចហើយ។

### ជ២. ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឬជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា

ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឬជនអន្តោប្រវេសន៍ដែលរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងត្រូវអនុវត្តតាម នីតិវិធីនៃការសុំរៀបអាពាហ៍ពិពាហ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងនីតិវិធីនៃការចុះបញ្ជីអាពាហ៍ពិពាហ៍របស់ក្រសួងមហាផ្ទៃ។

ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ត្រូវបំពេញបែបបទតាមនីតិវិធីនានារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដោយមាន៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍របស់ភាគីខ្មែរ និងរបស់ភាគីបរទេស
- លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ របស់ភាគីខ្មែរ និងរបស់ភាគីបរទេស
- លិខិតបញ្ជាក់ពីស្ថានទូតរបស់ភាគីបរទេសប្រចាំនៅក្រុងភ្នំពេញ
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់ភាគីខ្មែរ
- សៀវភៅគ្រួសាររបស់ភាគីខ្មែរ
- លិខិតពិនិត្យសុខភាពរបស់សាមីខ្លួនទាំង២រូប
- លិខិតឆ្លងដែន និងទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា មានសុពលភាពរបស់ភាគីបរទេស។

ក្រោយពីបានពិនិត្យឯកសារត្រឹមត្រូវហើយ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវចេញបណ្ណប្រកាសអាពាហ៍ពិពាហ៍ និងបិទផ្សាយជាសាធារណៈក្នុងរយៈពេល១០ថ្ងៃ។ ព្រមជាមួយគ្នានេះ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដែលមានចុះហត្ថលេខាបញ្ជាក់ពីមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវមានការបញ្ជាក់ពីអភិបាលស្រុក ខណ្ឌ ខេត្ត ក្រុង និងបញ្ជូនមកក្រសួងការបរទេស។ ក្រោយពីក្រសួងការបរទេសអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ហើយ ទើបអនុវត្តតាមនីតិវិធីនៃការចុះ បញ្ជីអាពាហ៍ពិពាហ៍របស់ក្រសួងមហាផ្ទៃ ដោយសាមីខ្លួនទាំង២រូប និង

សាក្សី ០២រូប គ្រប់អាយុការ មកបង្ហាញខ្លួន នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីសុំចុះបញ្ជីអាពាហ៍ពិពាហ៍ (ក្រោយពីបិទផ្សាយជាសាធារណៈនូវបណ្ណប្រការអាពាហ៍ពិពាហ៍រយៈពេល១០ថ្ងៃ។

ការសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរជាមួយនឹងជនបរទេស ឬជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តដូចគ្នានឹងការចុះបញ្ជីអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរជាមួយពលរដ្ឋខ្មែរដែរ លើកលែងតែចំណុចមួយចំនួននៃភាគីបរទេស ដែលត្រូវបំពេញដូចខាងក្រោម៖

- សញ្ជាតិ ត្រូវសរសេរសញ្ជាតិជនបរទេស ឬជនអន្តោប្រវេសន្តដែលបានរៀបអាពាហ៍ពិពាហ៍
- ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវសរសេរទីលំនៅរបស់សាមីខ្លួនប្តី ឬប្រពន្ធនៅប្រទេសដើមរបស់ខ្លួនជាអក្សរខ្មែរដោយបញ្ជាក់ពីទីលំនៅឯបរទេសឱ្យបានពិតប្រាកដ
- លេខអត្តសញ្ញាណបណ្ណ ត្រូវសរសេរលេខលិខិតឆ្លងដែន និងថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព ឬលេខទិដ្ឋាការ ឬលេខលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា និងថ្ងៃ ខែ ឆ្នាំដែលមានសុពលភាព

បើលិខិតឆ្លងដែន ឬទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាហួសពេលកំណត់ គឺមិនអនុញ្ញាតឱ្យចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ទេ ហើយទន្ទឹមនេះមន្ត្រីអត្រានុកូលដ្ឋាន ត្រូវរាយការណ៍ឱ្យមន្ត្រីមានសមត្ថកិច្ចភ្លាម។

**ជ៣. ការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនអន្តោប្រវេសន្ត ជាមួយជនបរទេស និងជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា**

ជនបរទេស និងជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនអន្តោប្រវេសន្តបាន ដោយអនុវត្តតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ដែលមានចែងក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋាន នៅទីកន្លែងដែលខ្លួន ស្នាក់នៅជាប់លាប់ ដោយប្រាប់ពីទីកន្លែង និងពេលវេលារៀបអាពាហ៍ពិពាហ៍នោះឱ្យបានច្បាស់លាស់។ ការសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អាចទៅសុំចុះនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ឬអាចទៅសុំចុះនៅ សាលាឃុំ ឬសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់ ដោយអនុវត្តតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។ មន្ត្រីអត្រានុកូលដ្ឋាននៅឃុំ ឬសង្កាត់ អាចចុះសៀវភៅ អាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តនោះបាន ដោយអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍នៅឃុំ ឬសង្កាត់ សម្រាប់បុគ្គលជាជនបរទេស និងជនអន្តប្រវេសន្តស្របច្បាប់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អនុវត្តដូចគ្នានឹងការណែនាំចុះសៀវភៅអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរជាមួយពលរដ្ឋខ្មែរដែរ លើកលែងចំណុចមួយចំនួន ដូចខាងក្រោម៖

- **សញ្ជាតិ** ត្រូវសរសេរសញ្ជាតិជនបរទេស ឬជនអន្តោប្រវេសន្តដែលបានរៀបអាពាហ៍ពិពាហ៍
- **ទីលំនៅឯបរទេស** ត្រូវសរសេរទីលំនៅរបស់សាមីខ្លួនប្តីប្រពន្ធ នៅប្រទេសដើមរបស់ខ្លួនជាអក្សរខ្មែរដោយបញ្ជាក់ពីទីលំនៅឯបរទេសឱ្យបានត្រឹមត្រូវ
- **លិខិតឆ្លងដែនលេខមានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ៖** ត្រូវសរសេរលេខលិខិតឆ្លងដែន និងថ្ងៃ ខែ ឆ្នាំដែលមានសុពលភាព

- **ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា លេខ ថ្ងៃ ខែ ឆ្នាំ៖** ត្រូវសរសេរលេខទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា និង ថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព។

បើលិខិតឆ្លងដែន ឬទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាហួសពេលកំណត់ គឺមិនអនុញ្ញាតឱ្យចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ទេ ហើយទន្ទឹមនេះមន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ឱ្យមន្ត្រីមានសមត្ថកិច្ចភ្លាម។

**ជ៤. ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេសដែលកំពុងរស់នៅស្របច្បាប់ ឯបរទេស**

នីតិវិធីនៃការចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ចំពោះពលរដ្ឋខ្មែររៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ឬពលរដ្ឋខ្មែររៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសដែលកំពុងរស់នៅស្របច្បាប់ឯបរទេស នឹងមានការណែនាំជាក្រោយ។

### ២.២.១.៦. ការងារអត្រានុកូលដ្ឋានមរណៈភាព

**ក. និយមន័យ**

មរណភាពរបស់បុគ្គលម្នាក់ គឺជាព្រឹត្តិការណ៍គតិយុត្តិមួយ ព្រោះថាមរណភាពនាំអោយបុគ្គលិកលក្ខណៈគតិយុត្តិរបស់បុគ្គលនោះត្រូវបញ្ចប់នៅពេលមរណភាពក៏ដោយក៏ច្បាប់បានកំណត់ទទួលស្គាល់ និងបានផ្តល់នូវអានុភាពខាងផ្លូវច្បាប់ខ្លះ ដូចជាបណ្តាំសាសន៍ ជាដើម។ នឹងចាត់ទុកថាមរណភាព ក្នុងករណីមានបុគ្គលណាម្នាក់បានបាត់ខ្លួន ឬអវត្តមានក្នុងថេរវេលាមួយដែល ច្បាប់បានកំណត់ ហើយគ្មាននរណាដឹងថាជននោះស្លាប់ ឬរស់មានញាតិលោហិត ឬអ្នកមានផលប្រយោជន៍ពាក់ព័ន្ធបានប្តឹងសុំឱ្យតុលាការប្រកាសពីការបាត់ខ្លួនរបស់ជននោះ ឬអវត្តមានប្រសិនបើតុលាការចេញសាលក្រមបញ្ជាក់ថាការបាត់ខ្លួន ឬអវត្តមាន ថាជាមរណភាព។[64]

**ខ. សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព**

សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាពរួមមាន៖

- សៀវភៅអត្រានុកូលដ្ឋានមរណភាព (សម្រាប់ប្រជាពលរដ្ឋខ្មែរ)
- សៀវភៅអត្រានុកូលដ្ឋានមរណភាពសម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព

ចំពោះសៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាពអត្រានុកូលដ្ឋាននោះទេ។

**គ. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព**

ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាពរួមមាន៖

- សំបុត្រមរណភាព
- សំបុត្របញ្ជាក់មរណភាព
- សេចក្តីចម្លងសំបុត្រមរណភាព
- សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព

[64] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ទំព័រទី២ ឆ្នាំ២០០៥

**ឃ. ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសំបុត្រមរណភាព**

ការសរសេរ ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសំបុត្រមរណភាព គឺសម្រាប់អ្នកស្លាប់ទាំងឡាយដែលបានស្លាប់ ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ និងអ្នកស្លាប់ទាំងឡាយ មុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ដែលមានសំបុត្រមរណភាពច្បាប់ដើម។ ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃក្រោយពីថ្ងៃទទួលមរណភាព។ ក្រោយថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ បើមានជនណាស្លាប់ទុកឱ្យហួសរយៈពេល១៥ថ្ងៃ ពុំបានទៅរាយការណ៍ ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្រុមគ្រួសារ នៃអ្នកស្លាប់ ត្រូវប្តឹងសុំសំបុត្រមរណភាពពីមឃុំ ចៅសង្កាត់សាមី ដោយបង់ថ្លៃសំបុត្រមរណភាព ដល់អាជ្ញាធរឃុំ សង្កាត់សាមីចំនួន១.០០០រៀល (មួយពាន់រៀលគត់) សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅ នៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង៤.០០០រៀល (បួនពាន់រៀលគត់) សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅ ក្រៅពីខេត្តខាងលើ។

**ង. លិខិតស្នាមនានា ដែលពាក់ព័ន្ធនឹងសព**

អ្នកទៅរាយការណ៍អំពីមរណភាពដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព មន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួន ដូចខាងក្រោមៈ

លិខិតជូនដំណឹងមរណភាព

- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងឃាតកម្ម ឧក្រិដ្ឋកម្ម
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់ទៅស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងពន្ធនាគារ

សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ (ប្រសិនបើមាន។ សំបុត្រមរណភាពច្បាប់ដើមចាស់ ក្នុងករណី អ្នកស្លាប់មុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយមាន សំបុត្រមរណភាពច្បាប់ដើម ដើម្បីប្តូរយកសំបុត្រមរណភាពថ្មី។

**ក្នុងករណី សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្ត ត្រូវមានឯកសារ២បន្ថែមទៀត**

- លិខិតឆ្លងដែនរបស់អ្នកស្លាប់ ដែលនៅមានសុពលភាព
- ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅមានសុពលភាព

បញ្ជាក់ បើលិខិតស្នាមណាមួយមានការសង្ស័យ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើទំនាក់ទំនងជាមួយនឹងសមត្ថកិច្ច ដែលពាក់ព័ន្ធនឹងលិខិតស្នាមនោះ។

**មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងសពៈ**

- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀតករណីអ្នកស្លាប់ទៅស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ
- សំបុត្រមរណភាពច្បាប់ដើមចាស់ក្នុងករណី អ្នកស្លាប់មុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយមានសំបុត្រមរណភាពច្បាប់ដើម ដើម្បីប្តូរយកសំបុត្រមរណភាពថ្មី

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់លិខិតស្នាមដែលពាក់ព័ន្ធនឹងសពឱ្យទៅអ្នករាយការណ៍វិញក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក។

**ច. ការសរសេរលិខិតសរសេរលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជាសព ឬបញ្ចុះសព**

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសណ្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ច នៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជាសព ឬបញ្ចុះសពក្នុងករណីអ្នកស្លាប់ដោយ ជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យ ទាក់ទងដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋណាមួយ។ បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាតដែលអាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សង្គម មន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ទៅមន្ទីពេទ្យ ឬផ្នែកអនាម័យភ្លាម។ បើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋាន ត្រូវអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពតាមការសម្រេចនោះ។ ប្រសិនបើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យដល់អំពើឃាតកម្មនៃបទល្មើស ឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយណាដែលបានឃើញ ឬដឹងព្រឹត្តហេតុការណ៍នោះ ត្រូវរាយការណ៍ ដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ភ្លាម ដើម្បីឱ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និងដោះស្រាយរួសរាន់។ ក្រោយពីមានការសម្រេចយ៉ាងណាពីភ្នាក់ងារមានសមត្ថកិច្ចទើបមន្ត្រីអត្រានុកូលដ្ឋាន អនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពបាន។ បើមានពលរដ្ឋខ្មែររស់នៅក្នុងឃុំ ឬសង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬសង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលអ្នកស្លាប់បាន រស់នៅ មុនពេលស្លាប់ ដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់នោះ ឱ្យទៅយកសពមកធ្វើបុណ្យ និងចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឃុំ ឬសង្កាត់ដែលអ្នកស្លាប់នោះបានរស់នៅជាប់លាប់ មុនពេលស្លាប់។ ករណីអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬគ្មានអ្នកស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ ត្រូវចាត់ចែងបូជា ឬបញ្ចុះសពនោះ និងចុះសៀវភៅមរណភាពក្នុងឃុំ ឬសង្កាត់នោះ។ នៅពេលមានអ្នកមករាយការណ៍អំពីមរណភាព ដើម្បីសុំលិខិតអនុញ្ញាតធ្វើបុណ្យបូជា ឬបញ្ចុះសព សុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសុំសំបុត្រមរណភាពចំពោះ

មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យមើលលិខិតស្នាម ឱ្យបានច្បាស់លាស់ បើឃើញត្រឹមត្រូវទៅតាមការកំណត់ហើយ ត្រូវសរសេរលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសព ទៅតាមលក្ខណៈ នៃការស្លាប់នោះ។

**ឆ. ការសរសេរចុះបញ្ជីមរណភាព**

**ឆ១. សម្រាប់ប្រជាពលរដ្ឋខ្មែរ**

នៅពេលមានអ្នកមករាយការណ៍អំពីមរណភាព និងបន្ទាប់ពីពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចុះបញ្ជីមរណភាពចំនួន០២ច្បាប់មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាពភ្លោះ។ ចំពោះទណ្ឌិតដែលស្លាប់ក្នុងពន្ធនាគារ ករណីមានអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ អ្នកទទួលខុសត្រូវនៃពន្ធនាគារនោះ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ទណ្ឌិតនោះ គឺដើម្បីមន្ត្រីទទួលបន្ទុកការងារអត្រានុកូលដ្ឋានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព។

ចំពោះសាកសពដែលមិនស្គាល់ មន្ត្រីអត្រានុកូលដ្ឋានក៏ត្រូវតែសរសេរចុះក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាពដែរ ដោយសរសេរយោងកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ច នៅរឹមទំព័រខាងឆ្វេងនៃបញ្ជីមរណភាព ហើយសរសេរចុះនៅក្នុងបញ្ជីមរណភាព តាមខ្លឹមសារនៃកំណត់ហេតុរបស់សមត្ថកិច្ចដូចជា៖

- ភេទ
- ទីកន្លែងស្លាប់ យកកន្លែងដែលឃើញសាកសព
- មូលហេតុស្លាប់តាមបណ្តឹងរបស់អ្នករាយការណ៍ យកតាមកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ច
- ថ្ងៃ ខែ ឆ្នាំ ស្លាប់យកតាមកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ច

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ចច្បាប់ចម្លង០១ច្បាប់ ជាឯកសារនៅសាលាឃុំ សង្កាត់។

**ឆ២. សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់ ក្នុងព្រះរាជាណាចក្រកម្ពុជា**

ជនបរទេស និងជនអន្តោប្រវេសន្តរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលស្លាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬអ្នកទទួលខុសត្រូវ អាចទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព នៅសាលាឃុំ ឬសង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់មុនពេលស្លាប់ ឬអាចទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅស្ថានទូតស្ថានអគ្គកុងស៊ុល ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនជាអ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន។ បើចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅសាលាឃុំ ឬសង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង។

**ជ. ការសរសេរសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក**

ក្រោយពេលសរសេរចុះបញ្ជីទាំងពីររួចហើយ នៃសៀវភៅអត្រានុកូលដ្ឋានមរណភាពទាំងពីររួចហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចូលទៅក្នុងសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្នកុំឱ្យខុសពីខ្លឹមសារនៅក្នុងបញ្ជីមរណភាព ដោយដកស្រង់យកចំណុចសំខាន់ៗពីបញ្ជីមរណភាព។ ការប្រគល់សំបុត្រមរណភាពច្បាប់ដើមមួយសន្លឹកក្រោយពីសរសេរចុះហត្ថលេខា និងបោះត្រាលើបញ្ជីទាំងពីរ សំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក រួចហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់សំបុត្រមរណភាពច្បាប់ដើមនេះ ទៅឱ្យអ្នកមក

រាយការណ៍ អំពីមរណភាពដែលសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ដោយមិនបង់ថ្លៃអ្វីឡើយ និងណែនាំឱ្យរក្សាទុកដាក់ឱ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្រមរណភាពច្បាប់ដើម ជូនជាលើកទីពីរបានទេ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវជម្រាបអ្នកមករាយការណ៍ថា សំបុត្រមរណភាពច្បាប់ដើម គឺជាឯកសារដែលមាន តែមួយច្បាប់ប៉ុណ្ណោះ មិនត្រូវយកទៅប្រើប្រាស់ ដោយភ្ជាប់ជាមួយឯកសារ ណាមួយនោះទេ ដូច្នេះគួរធ្វើសេចក្តីចម្លងសំបុត្រមរណភាពឱ្យហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់។

នៅពេលចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងធ្វើសំបុត្រមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរដោយផ្អែកតាមខ្លឹមសារនៃសំបុត្រកំណើត សំបុត្របញ្ជាក់កំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

**ឈ. ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព និងសំបុត្របញ្ជាក់មរណភាព**

ការសរសេរ ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព និងសំបុត្របញ្ជាក់មរណភាព គឺសម្រាប់អ្នកស្លាប់ ទាំងឡាយដែលបានស្លាប់ មុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយមិនមានសំបុត្រមរណភាពច្បាប់ដើម។ ពលរដ្ឋខ្មែរដែលស្លាប់ មុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសណ្តានដែលនៅរស់ អាចមកសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាពបាន តាមគំរូណែនាំថ្មី នៅសាលាឃុំ ឬសង្កាត់ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្ន ដោយនាំសាក្សីចំនួន ០២រូប នីតិជនហើយមានទីលំនៅពិតប្រាកដមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

**ញ. អ្នកមានសិទ្ធិសុំចុះបញ្ជីបញ្ជាក់មរណភាព អ្នកមានសិទ្ធិសុំចុះបញ្ជីបញ្ជាក់មរណភាព**

- បើប្តីស្លាប់ អ្នកមានសិទ្ធិ គឺប្រពន្ធ
- បើប្រពន្ធស្លាប់ អ្នកមានសិទ្ធិ គឺប្តី
- បើឪពុក ម្តាយស្លាប់ អ្នកមានសិទ្ធិ គឺកូនទី១
- បើឪពុក ម្តាយ និងកូនទី១ស្លាប់ អ្នកមានសិទ្ធិ គឺកូនទី២។

**ដ. ការសរសេរចុះបញ្ជីបញ្ជាក់មរណភាព**

នៅពេលមានអ្នកមកសុំបញ្ជាក់មរណភាព និងបន្ទាប់ពីពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីបញ្ជាក់មរណភាពចំនួនពីរច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាពភ្លោះ។

ការចុះបញ្ជីបញ្ជាក់មរណភាពនៃសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវអនុវត្តដូចគ្នានឹងការសរសេរចុះបញ្ជីមរណភាពនៃសៀវភៅអត្រានុកូលដ្ឋានមរណភាព។

**ឋ. ការសរសេរសំបុត្របញ្ជាក់មរណភាពច្បាប់ដើមមួយសន្លឹក**

ក្រោយពេលសរសេរបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាពទាំងពីររួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចូលទៅក្នុងសំបុត្របញ្ជាក់មរណភាពច្បាប់ដើមមួយសន្លឹកដោយប្រុងប្រយ័ត្នឱ្យខុសពីខ្លឹមសារក្នុងបញ្ជីបញ្ជាក់មរណភាព ដោយដកស្រង់យកចំណុចសំខាន់ៗពីបញ្ជីបញ្ជាក់មរណភាព។ ចំពោះការប្រគល់សំបុត្របញ្ជាក់មរណភាពច្បាប់ដើមមួយសន្លឹកក្រោយពីសរសេរចុះហត្ថលេខា និងការបោះត្រាលើសំបុត្រ

បញ្ជាក់មរណភាពច្បាប់ដើមមួយសន្លឹករួចហើយឱ្យបានគង់វង្ស គឺដើម្បីជៀសវាងការបាត់បង់ ពីព្រោះពុំអាចធ្វើសំបុត្របញ្ជាក់មរណភាពច្បាប់ដើម មន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់ទៅឱ្យអ្នកមកសុំបញ្ជាក់មរណភាព និងណែនាំឱ្យរក្សាទុកដាក់ជូនជាលើកទីពីរបានទេ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវជម្រាបអ្នកមកសុំបញ្ជាក់ថា សំបុត្របញ្ជាក់មរណភាពច្បាប់ដើម គឺជាឯកសារដែល មានតែមួយច្បាប់ប៉ុណ្ណោះ មិនត្រូវយកទៅប្រើប្រាស់ ដោយភ្ជាប់ជាមួយឯកសារណាមួយនោះទេដូច្នេះគួរតែធ្វើសេចក្ដីចម្លងសំបុត្របញ្ជាក់មរណភាពឱ្យហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់។ នៅពេលចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព និងធ្វើសំបុត្របញ្ជាក់មរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរដោយផ្អែកតាមខ្លឹមសារនៃឯកសារអត្រានុកូលដ្ឋានសំបុត្រកំណើត សំបុត្របញ្ជាក់កំណើត សំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

**ឱ. សេចក្ដីចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព**

ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាពក្នុងឆ្នាំមិនទាន់ដា ត្រូវសុំចម្លង ឬសុំស្រង់ នៅសាលាឃុំ ឬសាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ហើយត្រូវបោះត្រាផង។ ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាស្រុក ខណ្ឌ ឬនៅតុលាការខេត្ត ក្រុងសាម៉ី។

- បើសុំចម្លង ឬសម្រង់នៅសាលាស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាលស្រុក ខណ្ឌ និងបោះត្រាផង
- បើសុំចម្លង ឬសម្រង់នៅតុលាការខេត្ត ក្រុង ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី (មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននិងត្រូវបញ្ជាក់ហត្ថលេខានោះដោយប្រធានតុលាការ ឬចៅក្រមជំនួស និងបោះត្រាផង

ប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅស្ថានទូតស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ៖

- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព នៅក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូតស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង
- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់ នៅក្រសួងមហាផ្ទៃ ឬក្រសួងយុត្តិធម៌ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់ទុកនៅទីនោះ។

**ឃ. ការសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព**

មន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវពិនិត្យមើលសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ដែលអ្នកមកសុំចម្លងយកមកដោយធ្វើការ

- ពិនិត្យមើលថា តើសន្លឹកនៃសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពនោះ ពិតជាត្រឹមត្រូវ ដែលចេញដោយក្រសួងមហាផ្ទៃ មែនដែរ ឬទេ?

- ផ្ទៀងផ្ទាត់សំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពនោះ ជាមួយបញ្ជីក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាព ឬក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព នូវចំណុចមួយចំនួនដូចជាឆ្នាំដែលអនុវត្តនៃសៀវភៅអត្រានុកូលដ្ឋាន លេខសៀវភៅអត្រានុកូលដ្ឋាន លេខបញ្ជីអត្រានុកូលដ្ឋាន។

នៅពេលពិនិត្យសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព ឃើញថាជាសំបុត្រច្បាប់ដើមពិតប្រាកដ ហើយទើបមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន អាចចាប់ផ្ដើមសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព។ ការសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព ដោយចម្លងចេញពីរដូចជា សៀវភៅអត្រានុកូលដ្ឋានមរណភាព បើសុំចម្លងសំបុត្រមរណភាព។ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព បើសុំចម្លងសំបុត្របញ្ជាក់មរណភាព។

### ២.២.២. បញ្ហាប្រឈម

ប្រទេសកម្ពុជាជាប្រទេសដ៏ក្មេងខ្ចី និងមានកំណើនប្រជាជនលឿនជាងគេបង្អស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានចំនួនប្រជាជនប្រមាណជាង១៦លាននាក់ នៅឆ្នាំ២០១៩។ យោងតាមធនាគារពិភពលោក អត្រាកំណើតក្នុង ១,០០០នាក់ របស់ប្រទេសនេះបានធ្លាក់ចុះតិចតួច ពី ២៥,៥ នៅឆ្នាំ ២០១០ ទៅ ២២,៤ នៅឆ្នាំ ២០១៨ និងមកដល់ឆ្នាំ២០២១នេះ។ ជាមួយនឹងកំណើនសេដ្ឋកិច្ច និងភាពកាន់តែប្រសើរឡើងនៅក្នុងជីវភាពរស់នៅ និងសុខភាពរបស់ប្រជាជន អាយុរស់នៅមធ្យមរបស់ប្រជាជន គឺកំពុងកើនឡើង មានន័យថា ប្រជាជនរស់នៅបានយូរជាងពេលដែលពួកគេស្ថិតនៅអំឡុងទើបតែបញ្ចប់សង្គ្រាមស៊ីវិល។

ការផ្ដល់សេវាសាធារណៈនៅព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន គឺនៅមានចំណុចខ្វះខាតមួយចំនួន ដែលត្រូវកែលម្អជាច្រើន ជាពិសេសតម្រូវឱ្យមានផ្លាស់ប្ដូរនូវនីតិវិធី និងរបៀបរបបធ្វើការជាច្រើន ដើម្បីបំពេញតម្រូវការចាំបាច់របស់ប្រជាជនស្របតាមផែនការយុទ្ធសាស្ត្រក្នុង ការផ្ដល់សេវាសាធារណៈនៃរដ្ឋបាលឃុំសង្កាត់។

#### ២.២.២.១. បញ្ហាប្រឈមក្នុងការអនុវត្តតួនាទី

ក្នុងការអនុវត្តតួនាទីនាពេលកន្លងមក គឺមានការជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន រួមមានៈ

- ការងារអាទិភាពមានច្រើននៅក្នុងការអនុវត្តដែលពិបាកនឹងសម្រេចបានតាមការគ្រោងទុក
- កម្លាំងធនធានមនុស្សមិនបានប្រមូលផ្ដុំ គឺស្ថិតនៅរាយប៉ាយដែលធ្វើឱ្យផលិតភាព ប្រសិទ្ធភាព និងការអនុវត្តការងារនៅមានកម្រិត
- ថវិកាសម្រាប់គាំទ្រដល់ដំណើរការអនុវត្តកម្មវិធីជាតិនៅមានការយឺតយ៉ាវ នីតិវិធីច្រើន ស្មុគស្មាញដែលធ្វើឱ្យការទម្លាក់ និងផ្ដល់ថវិកាសម្រាប់ការអនុវត្តមិនបានទាន់ពេលវេលា
- ការគាំទ្រពីដៃគូអភិវឌ្ឍទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុនៅមានតិចតួច
- សមត្ថភាពមន្ត្រីអត្រានុកូលដ្ឋាននៅក្នុងការចូលរួមអនុវត្តការងារកែទម្រង់នៅមានកម្រិតទាំងសមត្ថភាពចំណេះដឹងជំនាញនិងការគ្រប់គ្រង
- ការចូលរួម និងការប្ដេជ្ញាចិត្តរបស់មន្ត្រីអត្រានុកូលដ្ឋាននៅក្នុងការងារផ្ដល់សេវានៅមានកម្រិត
- គុណផល និងវិន័យនៅក្នុងការបំពេញការងាររបស់មន្ត្រីអត្រានុកូលដ្ឋាន នៅមានកម្រិត

- បញ្ហាពេលវេលា គឺទាមទាររយៈពេលយូរដើម្បី ទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិបានឃើញ និងបានយល់អំពីសមិទ្ធផលការងារ
- សមត្ថភាពក្នុងការគ្រប់គ្រងការអនុវត្តការងារមិនបានក្លាយជាប្រព័ន្ធការងារ (យន្តការនៃការគ្រប់គ្រង)
- ការចូលរួមអនុវត្តការងារកែទម្រង់នៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត
- ការលើកទឹកចិត្តទាំងថវិកា និងមិនមែនថវិកានៅតែជាបញ្ហាសម្រាប់អ្នកដឹកនាំ និងអ្នកអនុវត្តការងារ
- ចំណេះដឹងរបស់មន្ត្រីអគ្រានុកូលដ្ឋាន និងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈនៅមានកម្រិត
- យន្តការ និងប្រព័ន្ធរាយការណ៍នៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃនៅមានកម្រិត។

**២.២.២.២. បញ្ហាប្រឈមចំពោះហិរញ្ញវត្ថុសាធារណៈ នៃរដ្ឋបាលឃុំ សង្កាត់**

នៅពេលអនុវត្តតួនាទីជាក់ស្តែង មន្ត្រីអគ្រានុកូលដ្ឋានតែងតែមានការជួបបញ្ហាទាក់ទងហ្នឹងហរិញ្ញវត្ថុ និងធនធានមនុស្សដូចជា៖

**ក. បញ្ហាប្រឈមទី១**

ការជាប់ពាក់ព័ន្ធទៅនឹងកម្រិតភាពនៃហិរញ្ញវត្ថុ ធនធានមនុស្ស និងប្រសិទ្ធ ភាពនៃការគ្រប់គ្រងពេលវេលា។ ត្រង់ចំណុចនេះ មានសកម្មភាពការងារច្រើន និងបានអនុវត្តសកម្មភាពការងារទាំង នោះរៀងៗខ្លួនដែលធ្វើឱ្យមានការចំណាយច្រើនទាំងពេលវេលា ធនធានមនុស្ស និងថវិកា។

ក្នុងការដោះស្រាយបញ្ហាទាំងនេះ ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលលោកបាននឹងកំពុងតែបន្តអនុវត្តន៍គោលនយោបាយរបស់ខ្លួន និងបង្កើតឱ្យមានការផ្តល់មតិដូចជាការស្នើឱ្យអង្គសិក្ខាសាលាធ្វើការពិភាក្សាដើម្បីរកដំណោះស្រាយរួម គ្នាលើបញ្ហាប្រឈមដែលបានលើកឡើងពាក់ព័ន្ធការងារផ្តល់សេវាជូនប្រជាពលរដ្ឋ។

ការអនុវត្តការងារជាលក្ខណៈក្រុមការងារគម្រោង ក្នុងការសិក្សាអំពីមុខងារ រចនាសម្ព័ន្ធ និងនីតិវិធីនៃការបំពេញការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការអនុវត្តការងារ ជាក្រុមការងារគម្រោងនេះ បានអនុញ្ញាតឱ្យមានការបន្សុំគ្នារវាងសកម្មភាពការងារ និងប្រព័ន្ធរដ្ឋបាលនៃក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ និងការងាររបស់លេខាធិការដ្ឋាននៃគណៈកម្មាការកែទម្រង់រដ្ឋបាលសាធារណៈដែលបានជួយបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិកា ធនធានមនុស្ស និងពេលវេលា។

**ខ. បញ្ហាប្រឈមទី២**

ភាពខ្វះចន្លោះនៃការចូលរួមអនុវត្តន៍សកម្មភាពការងារដែលបានដាក់ចេញប្រកប ដោយស្មារតីសហការភាពជាម្ចាស់ និងការទទួលខុសត្រូវ។ កន្លងមកហើយសង្កេតឃើញថា ការចូលរួមជំរុញ និងការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈដែលបានដាក់ចេញ មានដូចជា៖ ការអនុវត្តគោលនយោបាយ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងការផ្តល់សេវាសាធារណៈនៅមានកម្រិតនៅឡើយ។ ត្រង់ចំណុចនេះថ្នាក់ដឹកនាំរាជរដ្ឋាភិបាលបានស្នើឱ្យមានការចូលរួមពីឯកឧត្តម លោកជំទាវ ដែល ជាសមាជិក សមាជិកានៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បន្តចូលរួមជំរុញការអនុវត្តការងារទម្រង់រដ្ឋបាលសាធារណៈ និងបង្កើនស្មារតីភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់លើការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរៀងខ្លួន ជាពិសេសនោះគឺការផ្តល់សេវាសាធារណៈដើម្បីឱ្យកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ទទួលបានជោគជ័យ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីឆ្លងកាត់តាមរយៈការសិក្សាស្រាវជ្រាវអំពីប្រធានបទស្តីពី ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ ខាងលើរួចមក យើងសង្កេតឃើញថា សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ គឺជាប្រភេទសេវាមួយប្រភេទដែលបម្រើប្រយោជន៍សាធារណៈជូនប្រជាពលរដ្ឋដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលដែលមានដែនសមត្ថកិច្ចគ្រប់គ្រង និងដឹកនាំក្នុងនាមខ្លួនជាអ្នកផ្តល់សេវា ហើយប្រជាពលរដ្ឋជាអ្នកប្រើប្រាស់សេវាស្ថិតក្រោមចំណុះនៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺរដ្ឋបាលឃុំ សង្កាត់។ ម៉្យាងវិញទៀតសេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ គឺផ្តោតទៅលើការងារមូលដ្ឋាន និងសេវាពាក់ព័ន្ធទៅនឹងអធិបតេយ្យភាពរដ្ឋដូចជា អត្រានុកូលដ្ឋានកំណើត អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងអត្រានុកូលដ្ឋានមរណភាពជាដើម។ ទោះជាយ៉ាងនេះក៏ប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក ចុះ ថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិបានបញ្ញត្តិយ៉ាងច្បាស់គ្រប់ករណីដែលអាចកើតមានឡើងងាយស្រួលដល់ការអនុវត្តក្នុងទិដ្ឋភាពជាក់ស្តែង។

ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងរដ្ឋបាលដែនដីឃុំ សង្កាត់។ ជាក់ស្តែង ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ គឺនៅមានចន្លោះខ្វះខាត ទៅតាមតំបន់ដាច់ស្រយាល និងជនបទ។ ប៉ុន្តែដោយមើលឃើញតាមស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ននេះនៅព្រះរាជាណាចក្រកម្ពុជាយើងទទួលរងនូវការរីករាលដាល នៃជម្ងឺកូវីដ-១៩ ដែលបណ្តាលឱ្យប៉ះពាល់គ្រប់វិស័យទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ហេតុដូចនេះទើបធ្វើឱ្យ ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ មានផលវិបាក និងគុណវិបត្តិ ជាច្រើនក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ។

ស្របតាមស្ថានភាពជាក់ស្តែង ការផ្តល់សេវាសាធារណៈនៃរដ្ឋបាលឃុំ សង្កាត់ ដែលក្នុងនាមខ្លួនជាសេនាធិការនៃរាជរដ្ឋាភិបាល និងក្នុងនាមជាអ្នកផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋដែលមានតួនាទីភារកិច្ចគ្រប់គ្រងដឹកនាំ អភិវឌ្ឍន៍ នៅក្នុងដែនដីរបស់ខ្លួន។

សរុបសេចក្តីមកតាមរយៈលទ្ធផលដោយផ្អែកតាមគោលនយោបាយ និងវិធានការរបស់ថ្នាក់ដឹកនាំរួមទាំងការខិតខំ ប្រឹងប្រែងដោយផ្ទាល់របស់អាជ្ញាធរឃុំសង្កាត់ទូទាំងប្រទេសដោយមានការគាំទ្រពីក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិអាជ្ញាធរខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំងអង្គការជាតិ និងអន្តរជាតិនានាបានធ្វើឱ្យការផ្តល់សេវា និងពាក់ព័ន្ធនឹងអត្រានុកូលដ្ឋាន គ្រប់ប្រភេទជូនប្រជាពលរដ្ឋសម្រេចបានលទ្ធផលគួរជាទីមោទនៈ។ បើទោះបីជាមានកំហុសឆ្គង និងឧបសគ្គខ្លះៗក៏យើងអាចវាយតម្លៃខ្ពស់ពីការខិតខំប្រឹងប្រែងរបស់ស្ថាប័នគ្រប់ជាន់ថ្នាក់ព្រោះថាកម្ពុជាជាប្រទេសដែលអាចចាត់ទុកបានថានៅក្មេងខ្ចី ទើបតែរួចផុតពីវិបត្តិសង្គ្រាមរ៉ាំរ៉ៃ និងបញ្ហាកូវីត-19 ផងដែរ យើងមិនអាចប្រៀបធៀបទៅនឹងបណ្តាប្រទេសអភិវឌ្ឍន៍ដទៃទៀតបានទេ។ យើងមានតែសង្ឃឹមយ៉ាងមុតមាំថារាជរដ្ឋាភិបាលកម្ពុជានៅតែបន្តការយកចិត្តទុកដាក់ខ្ពស់ទៅលើ វិស័យសេវាសាធារណៈទៅតាមយុទ្ធសាស្ត្រចតុកោណ៖ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីប្រធានបទដូចដែលបានបកស្រាយខាងលើរួចមកនេះថ្វីត្បិតតែបច្ចុប្បន្ននេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាយើងបានធ្វើកំណែទម្រង់ និងអនុវត្តគោលនយោបាយ នៃរដ្ឋបាលសាធារណៈចំពោះយុទ្ធសាស្ត្រចតុកោណមកដល់ដំណាក់ទី៤ នីតិកាលទី៦ មកក៏ដោយក៏និន្នាការធំៗ បញ្ហាប្រឈម និងកាលានុភាពរបស់កម្ពុជាយើងចំពោះការផ្តល់សេវាសាធារណៈនៅមិនទាន់មានភាពច្បាស់លាស់ និងជំនឿទុកចិត្តគ្រប់គ្រាន់ពីសំណាក់មហាជនដែរ។ ក្រុមរបស់យើងខ្ញុំសូមធ្វើការផ្តល់នូវអនុសាសន៍មួយចំនួនដើម្បីចូលរួមផ្តល់ជាគំនិតក្នុងការសិក្សាឈ្វេងយល់បន្ថែមដូចតទៅ៖

- គួរពង្រឹងទៅលើសមត្ថភាព សីលធម៌ និងអត្តចរិតរបស់មន្ត្រីទទួលបន្ទុកក្នុងនាមខ្លួនជាអ្នកផ្តល់សេវាដល់ប្រជាពលរដ្ឋ ហើយជាពិសេស គឺមិនមានការរើសអើង ឬប្រកាន់ទៅលើ ជាតិសាសន៍ ពណ៌សម្បុរ និងនិន្នាការនយោបាយនោះទេ ត្រូវមានតម្លាភ្នុងការផ្តល់ និងទទួលសេវា
- មានការចុះត្រួតពិនិត្យ និងវាយតម្លៃទៅលើរបៀបរបបការងារជាប្រចាំ
- គួរយកចិត្តទុកដាក់ ទៅលើការផ្តល់សេវាជូនប្រជាពលរដ្ឋ ក្នុងការងារអត្រានុកូលដ្ឋាន ដូចជាអត្រានុកូដ្ឋានកំណើត អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងអត្រានុកូលដ្ឋានមរណភាព ជាពិសេសពន្លឿនរាល់ឯកសារដែលចាំបាច់សម្រាប់ប្រជាពលរដ្ឋ
- គួរផ្សព្វផ្សាយរាល់លិខិតបទដ្ឋានគតិយុត្ត ច្បាប់ ប្រកាសនានា និងនីតិវិធីក្នុងការដោះស្រាយបញ្ហាដែលកើតមានជាក់ស្តែងនៅក្នុងឃុំ សង្កាត់ជូនដល់ប្រជាពលរដ្ឋដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ការរស់នៅ
- សូមឱ្យមានការពន្យល់ និងណែនាំពីភាពចាំបាច់នៃការចុះបញ្ជីអត្រានុកូលដ្ឋានទាំងអត្រានុកូលដ្ឋានកំណើត អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងអត្រានុកូលដ្ឋានមរណភាព ជូនដល់ប្រជាពលរដ្ឋឱ្យបានជ្រាបជាដំណឹង
- សំណូមពរឱ្យមានការធ្វើអត្រានុកូលដ្ឋានមរណភាព ភ្ជាប់ជាមួយក្រដាសវេជ្ជសាស្ត្រ ឬលិខិតកោសល្យវិច្ច័យសាកសព
- គួរមានការរាយការណ៍ ឬជារបាយការណ៍ ពីសំណាក់មន្ទីរពេទ្យទាំងសាធារណៈ និងឯកជនទៅមន្ត្រីអត្រានុកូដ្ឋាន ទាក់ទងនឹងការកើត និងការស្លាប់
- គួរតែមានការរឹតបណ្តឹង និងកំណត់ពីកម្រិតចំណេះដឹង និងបទពិសោធន៍ការងារ របស់មេឃុំ ចៅសង្កាត់ដែលជាប់ឆ្នោត
- ស្នើសុំឱ្យមានការផ្តល់ជូននូវគ្រឿងបរិក្ខារ ឬសារពើភ័ណ្ឌនានា ជូនដល់មន្ត្រីអត្រានុកូលដ្ឋានដើម្បីជួយសម្រួលការងារប្រចាំថ្ងៃ និងមន្ត្រីផ្នែកដទៃទៀត
- គួរមានការបណ្តុះបណ្តាលនានាតាមរយៈការធ្វើសិក្ខាសាលា សន្និបាត ជូនដល់មន្ត្រីថ្នាក់ក្រោមជាតិ និងមានការលើកទឹកចិត្តដល់មន្ត្រីដែលមានភាពសកម្មក្នុងការបំពេញការងារ។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពី ការគ្រប់គ្រង ឃុំ-សង្កាត់ បែបវិមជ្ឈការ ឆ្នាំ២០១៧
- ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨
- ច្បាប់ស្តីពី សម្បទាន( នស.រកម.១០០៧.០២៧ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០០៧)
- ច្បាប់ស្តីពី ការគ្រប់គ្រង ឃុំ-សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០១
- ព្រះរាជក្រឹត្យលេខនស/រកត/១២៩២.៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី លក្ខន្តិកៈនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល និងព្រះរាជក្រមលេខ ជស/រកម/០៦៩៦.០៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- អនុក្រឹត្យស្តីពីការកែសម្រួល អនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋានលេខ១៧ អនក្របក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤
- ប្រកាសអន្តរក្រសួងលេខ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## ២. ឯកសារយោងស្នាដៃនិពន្ធ និងចងក្រង

- ក្រសួងមុខងារសាធារណៈ៖ ផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ (ឆ្នាំ២០១៩)
- សាស្ត្រាចារ្យ ហៀង សាង៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៤ ឆ្នាំ២០១៧
- គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់៖ កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអគ្រានុកូលដ្ឋាន ឆ្នាំ២០១៥
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលកម្រងពត៌មានសេវាសាធារណៈស្តីពី ចង្កោមសេវាទី២ ទី៥ ទី៦ និងទី៧ ឆ្នាំ២០១១
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ (ភ្នំពេញក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ២០០៦)
- បណ្ឌិត សាយ បូរី៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ឆ្នាំ២០០២
- ឯកសារជំនួយស្មារតីស្តីពី សេវាសាធារណៈ (រៀបរៀងដោយ ជួប បិតថេរឫទ្ធិ)

- ក្រសួងមុខងារសាធារណៈ៖ ការកែលម្អគុណភាពសេវាសាធារណៈ
- រាជរដ្ឋាភិបាលកម្ពុជា៖ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤
- សាស្ត្រាចារ្យ ឌឿក ពិដោរ៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពផ្សាយអង្គរ ឆ្នាំ២០០៩
- សាស្ត្រាចារ្យ ខាំ សុមករា៖ រដ្ឋបាលសាធារណៈ បោះពុម្ពផ្សាយ ឆ្នាំ២០១៣

## ៣. ឯកសារយោងជាគេហទំព័រ

- គេហទំព័រ https://www.sciencedaily.com/terms/public_services.htm
- គេហទំព័រ https://www.worldbank.org/en/news/feature/2017/02/09/enhancing-the-quality-of-public-service-delivery-in-cambodia
- គេហទំព័រ https://ncdd.gov.kh/services/
- គេហទំព័រ https://opendevelopmentcambodia.net/km/?
- គេហទំព័រ https://opendevelopmentcambodia.net/km/social-accountability/civil-status/

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

**១. ឧបសម្ព័ន្ធរូបភាព**

ឧបសម្ព័ន្ធ៖ សកម្មភាពរបស់មន្ត្រីអត្រានុកូលដ្ឋានដែលបានពីចុះផ្តល់សេវាជូនប្រជាពលរដ្ឋផ្ទាល់។

**២. ឧបសម្ព័ន្ធគតិយុត្តិ**

ឧបសម្ព័ន្ធទី១៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

ឧបសម្ព័ន្ធទី៣៖ ច្បាប់ស្តីពី សម្បទាន (នស.រកម.១០០៧.០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧)

ឧបសម្ព័ន្ធទី៤៖ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១

ឧបសម្ព័ន្ធទី៥៖ ព្រះរាជក្រមលេខ ជសរកម ០៦៩៦ ០៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៦ ប្រក

ឧបសម្ព័ន្ធទី៦៖ អនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន

ឧបសម្ព័ន្ធទី៧៖ អនុក្រឹត្យលេខ១៧ អនក្របក ស្តីពីការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន។

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធ៖ សកម្មភាពរបស់មន្ត្រីអត្រានុកូលដ្ឋានដែលបានចុះផ្តល់សេវាជូនដល់ប្រជាពលរដ្ឋផ្ទាល់នៅឃុំ សង្កាត់ដែលខ្លួនរស់នៅប្រចាំថ្ងៃ









សកម្មភាព៖ ការពន្យល់ណែនាំពីសំណាក់មន្ត្រីអត្រានុកូលដ្ឋាន ពីប្រភេទសេវាសាធារណៈ

# ឧបសម្ព័ន្ធគតិយុត្ត

# រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

# បុព្វកថា

# យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភធំទូលាយថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយទ្រុឌទ្រោម ឱនថយមហាសោកស្តាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈ មោះមុត ប្តូរផ្តាច់ រួបរួមគ្នាពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា "កោះសន្តិភាព" ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើង រីកចំរើនលូតលាស់ សម្បូររុងរឿង ជានិច្ច និរន្តរ៍ ។

**ក្នុងឆន្ទៈមោះមុតនេះ**

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ ពីអង្គការរដ្ឋ ។

**មាត្រា ៣៦.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៧.-**

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨.-**

ច្បាប់រ៉ាប់រង មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនធ្វើឡើយ ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំ តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុស

**មាត្រា ៥៥.-**

សន្ធិសញ្ញា និង កិច្ចព្រមព្រៀងទាំងឡាយណា ដែលមិនសមស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវលុបចោល ។

## ជំពូកទី៥
## អំពី សេដ្ឋកិច្ច

**មាត្រា ៥៦.-**

ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះនឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៧.-**

ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។ ថវិកាជាតិត្រូវបានកំណត់ឱ្យអនុវត្តតាមច្បាប់ ។

របបគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុ ត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៨.-**

ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថា ជារបស់រដ្ឋ ។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៩.-**

រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភោគោត្តសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល ។

**មាត្រា ៦០.-**

ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី ។ ការតំរូវឱ្យលក់ផលិតផលជូនរដ្ឋ ឬការយកភោគផល ឬទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយ ត្រូវហាមឃាត់ វៀរលែងតែក្នុងករណីពិសេសដែលមានច្បាប់អនុញ្ញាត ។

**មាត្រា ៦១.-**

រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់តាំងពីតំបន់ដាច់-

ស្រយាល ដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន ។

**មាត្រា ៦២.-**

រដ្ឋយកចិត្តទុកដាក់ ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផល ជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល ។

**មាត្រា ៦៣.-**

រដ្ឋយកចិត្តទុកដាក់ គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ មានកម្រិតសមរម្យ ។

**មាត្រា ៦៤.-**

រដ្ឋហាមឃាត់ និងផ្តន្ទាទោសជាទម្ងន់ដល់ជនណាដែលនាំចូលផលិតផល លក់ដូរ គ្រឿងញៀន ទំនិញក្លែងក្លាយ ហួសរយៈពេលប្រើ ដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើ ។

## ជំពូកទី៦

## អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច

**មាត្រា ៦៥.-**

រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កំរិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ ដល់វិស័យអប់រំកាយ និងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

**មាត្រា ៦៦.-**

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីអោយប្រជាពលរដ្ឋគ្រប់រូប មានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត ។

**មាត្រា ៦៧.-**

រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស ។

រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈ និងឯកជននៅគ្រប់ភូមិសិក្សា ។

**មាត្រា ៦៨.-**

រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសំរាប់ប្រជាពលរដ្ឋគ្រប់រូប ដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។

រដ្ឋជួយផ្សព្វផ្សាយ និងលើកតំកើងសាលាបាលី និងពុទ្ធិកសិក្សា ។

**មាត្រា ៦៩.-**

រដ្ឋមានកាតព្វកិច្ចថែរក្សា និង ពង្រីកវប្បធម៌ជាតិ ។

រដ្ឋមានកាតព្វកិច្ចការពារ និងពង្រីកភាសាខ្មែរឱ្យសមស្រប នឹងសេចក្ដីត្រូវការ ។

រដ្ឋមានកាតព្វកិច្ចថែរក្សា និងការពារប្រាសាទបុរាណ វត្ថុសិល្បៈបុរាណ និងកែលំអរមណីដ្ឋានប្រវត្តិសាស្ត្រឡើងវិញ ។

**មាត្រា ៧០.-**

បទល្មើសទាំងឡាយដែលប៉ះពាល់ ឬ ទាក់ទងនឹងបេតិកភ័ណ្ឌវប្បធម៌ និងបេតិកភ័ណ្ឌសិល្បៈ ត្រូវផ្ដន្ទាទោសជាទម្ងន់ ។

**មាត្រា ៧១.-**

បរិវេណបេតិកភ័ណ្ឌជាតិ ក៏ដូចជាបេតិកភ័ណ្ឌដែលបានបញ្ចូលជាបេតិកភ័ណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹតដែលមិនឱ្យមានសកម្មភាពយោធា ។

**មាត្រា ៧២.-**

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺ និងព្យាបាលជម្ងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគ ដោយឥតបង់ថ្លៃនៅតាម មន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ។

រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ ។

**មាត្រា ៧៣.-**

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា ។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុកហើយឥតទីពឹង ។

**មាត្រា ៧៤.-**

រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។

**មាត្រា ៧៥.-**

រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គម ដល់កម្មករ និងនិយោជិត ។

នស/រកម/០៣៩៩/០១

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រា ១១ ជំពូកទី ២ ស្តីពី **ព្រះមហាក្សត្រ** នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ**កម្ពុជា** ដែលត្រូវបានសភាធម្មនុញ្ញ អនុម័តនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣

## បង្គាប់

**មាត្រា១ :** ប្រកាសឱ្យប្រើជាផ្លូវការ នូវច្បាប់ស្តីពីការកែប្រែមាត្រា ២៨នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាដែលរដ្ឋសភា បានអនុម័ត នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

**មាត្រា២ :** ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

ធ្វើនៅព្រះរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤

ក្នុងព្រះបរមនាថ និងតាមព្រះរាជចំណារ

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងត្រា

**ជា ស៊ីម**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់ធម្មនុញ្ញ

# ស្តីពី

# វិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨

# ៣០ ៣៤ ៥១ ៩០ ៩១ ៩៣

# និងមាត្រាទាំងឡាយ នៃជំពូកទី ៨

# ដល់

# ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ

ច្បាប់ធម្មនុញ្ញនេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ១៩៩៩ ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី ២ ។

**ភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៩**

**ប្រធានរដ្ឋសភា**

**ហត្ថលេខា និងត្រា**

**នរោត្តម រណឫទ្ធិ**

នស/រកម/០៣៩៩/០១

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-ទ្រង់យល់សម័យប្រជុំវិសាមញ្ញពេញអង្គ នៃរដ្ឋសភានៅថ្ងៃទី ២-៣-៤ ខែ មីនា ឆ្នាំ ១៩៩៩

-យោងតាមសំណើរបស់ ប្រធានរដ្ឋសភា ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៩

## ត្រាស់បង្គាប់

**មាត្រា១ :** ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩ ។

**មាត្រា២ :** ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេល ឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩

ព្រះរាជលញ្ចករ

**នរោត្តម សីហនុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

# ច្បាប់រដ្ឋធម្មនុញ្ញ
# ស្តីពី
# វិសោធនកម្មមាត្រា ១៩ និង មាត្រា ២៩ នៃរដ្ឋធម្មនុញ្ញ

**មាត្រាតែមួយ :** មាត្រា១៩ និងមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញត្រូវបានកែប្រែដូចតទៅ :

**មាត្រា ១៩ ថ្មី-**

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុង មាត្រា ១១៩ ថ្មី ។

**មាត្រា ២៩ ថ្មី-**

ព្រះមហាក្សត្រទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធា និងស៊ីវិលតាមច្បាប់កំណត់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យ
ប្រជុំរដ្ឋសភា លើកទី ៦ នីតិកាលទី ២ ។
ភ្នំពេញ.ថ្ងៃទី ខែ កក្កដា ឆ្នាំ ២០០១

**នរោត្តមរណឫទ្ធិ**

**ព្រះរាជក្រម**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៤
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ នៃព្រឹទ្ធសភា នាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤
- យោងតាមសំណើ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ របស់ព្រឹទ្ធសភា សមាជិករដ្ឋសភា នីតិកាលទី ៣

# ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់ធម្មនុញ្ញបន្ថែម
# សំដៅ
# ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

**មាត្រា ១.-**

ច្បាប់ធម្មនុញ្ញនេះ មានគោលដៅធានាក្នុងគ្រប់កាលៈទេសៈនូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមស្របតាមតំរូវការនៃភាពចាំបាច់ ។

**មាត្រា ២.-**

នៅដើមនីតិកាលថ្មីនីមួយៗ រដ្ឋសភា ក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភា មុននឹងផ្តើមការងាររបស់ខ្លួន និងក្រោយពេលសំរេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗ អាចចាប់ផ្តើមអនុម័ត អត្ថបទដែលមានចរិក ជារដ្ឋធម្មនុញ្ញ ឬច្បាប់ដើម្បីអនុវត្តបាននូវគោលដៅដូចមានចែងក្នុងមាត្រា ១ ។

អត្ថបទទាំងនេះ ក្រោយពីបានត្រូវទទួលការបោះឆ្នោតអនុម័តដោយរដ្ឋសភារួចហើយ ត្រូវតែបានទទួលជាបន្ទាន់នូវចំណាត់ការដោយរួសរាន់ពីសំណាក់ព្រឹទ្ធសមាជិករដ្ឋសភា តាមនីតិវិធីកំណត់សំរាប់ អត្ថបទទាំងនោះ រហូតដល់ពេលដែលត្រូវបានប្រកាសអោយចូលជាធរមាន ។

**មាត្រា ៣.-**

ក្នុងករណីដែលឃើញថា នីតិវិធីនៃមាត្រា ៨២ និង១១៩ថ្មី នៃរដ្ឋធម្មនុញ្ញ មិនអាចសំរេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បី ជ្រើសតាំងប្រធាន អនុប្រធាន រដ្ឋសភា ក៏ដូចជា ប្រធាន និងអនុប្រធាន គណៈកម្មការក្នុងពេលជាមួយគ្នា និងការផ្តល់សេចក្តីទុកចិត្តចំពោះ រាជរដ្ឋាភិបាល ។

**មាត្រា ៤.-**

ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្តត្រូវអនុវត្តដូចតទៅ :

- បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជា ប្រធាន និងអនុប្រធានគណៈកម្មការ ជំនាញទាំងអស់ នៃរដ្ឋសភា ត្រូវរៀបចំ និងស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- តាមសេចក្តីស្នើពីគណបក្សនយោបាយ ដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រ នៃគណបក្សនយោបាយដែលឈ្នះឆ្នោត អោយបង្កើតរាជរដ្ឋាភិបាល ។

វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូរផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលរួចផ្ញើបញ្ជី រាយនាមសមាជិកទាំអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- ព្រឹទ្ធសមាជិករដ្ឋសភា ត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជន ប្រធាន អនុប្រធាន នៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការ ជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជន នាយករដ្ឋមន្ត្រី និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត ។

**មាត្រា ៥.-**

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់ មិនអាចជជែកពិភាក្សាអ្វីឡើយ ហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះ ក្រោយការប្រកាសលទ្ធផល នៃការបោះឆ្នោតជាកញ្ចប់នេះដែរ ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬមិនព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយ ដែលព្រឹទ្ធសមាជិករដ្ឋសភាបានដាក់ជូន ។ ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយវិធីលើកដៃ ។

**មាត្រា ៦.-**

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណី ការបោះឆ្នោតជុំទីមួយមិនបានសំរេច នីតិវិធីដដែលនេះ នឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

**មាត្រា ៧.-**

ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានប្រកាសជាការប្រញាប់ និងយកមកអនុវត្តចាប់តាំងពីដើម នីតិកាល បច្ចុប្បន្ននេះទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ញឹក ប៊ុនឆៃ**

ពរល.០៤.០៧.១១៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**ព្រឹទ្ធសមាជិក និងជាប្រធានអង្គប្រជុំរដ្ឋសភា**

**ហត្ថលេខា**

**ជា សុន្ទ**

នស/រកម/០៣០៦/០០៦

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់តំណាងរាស្ត្រចំនួនលើសពីមួយភាគបួននៃចំនួនតំណាងរាស្ត្រទាំងមូល
- បានទ្រង់យល់លិខិតលេខ ៨២ លស ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់សម្តេចនាយករដ្ឋមន្ត្រី
- បានទ្រង់យល់លិខិតលេខ ០០១/០១/២០០៦ កបធ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជសារព្រះមហាក្សត្រចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦
- បានទ្រង់យល់លិខិតលេខ ២៥៤ រស ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៦ របស់រដ្ឋសភា
- បានទ្រង់យល់លិខិតលេខ ០១៣/០៣០៦/ពស/នវ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០៦ របស់ព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១ថ្មី (មួយ) មាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាអនុម័តនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភា លើកទី ៤ នីតិកាលទី ៣ និងដែល-

ព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

# ច្បាប់រដ្ឋធម្មនុញ្ញ
# ស្ដីពី
# វិសោធនកម្ម
# មាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨
# មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ
# និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការ
# ជាប្រក្រតីនៃស្ថាប័នជាតិ

## មាត្រាតែមួយ.-

មាត្រា ៨២ មាត្រា ៨៨ ថ្មី មាត្រា ៩០ ថ្មី មាត្រា ៩៨ ថ្មី មាត្រា ១០៦ ថ្មី មាត្រា ១១១ ថ្មី (មួយ) មាត្រា ១១៤ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានកែប្រែដូចតទៅ :

## មាត្រា ៨២.- ថ្មី

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្ដើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធាន រដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៥ នៃរដ្ឋធម្មនុញ្ញ ។

## មាត្រា ៨៨.- ថ្មី(ពីរ)

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភា នឹងយកជាការបានលុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែល

តម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩០.~ ថ្មី(ពីរ)**

រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩៨.~ ថ្មី**

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញ្ញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

**មាត្រា ១០៦.~ ថ្មី (មួយ)**

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភាដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ១១១.~ ថ្មី (ពីរ)**

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

**មាត្រា ១១៤.~ ថ្មី (មួយ)**

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ៦.~ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម**

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦

ពរល.០៦០៣.១២៤

**ព្រះហត្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខ : ១១៣ ច.ល

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ ថ្ងៃទី ខែ មីនា ឆ្នាំ ២០០៦**

**ហត្ថលេខា**

**ណារិទ្ធ តាន់**

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែ មេសា ឆ្នាំ ២០០៨ នា សម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបាន ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរដ្ឋបាល
# រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ២១២.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានសិទ្ធិទទួលមូលនិធិ និងការគាំទ្រពីដៃគូអភិវឌ្ឍនានា និងពីប្រភពផ្សេងៗទៀតដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។

## ផ្នែកទី ២

## មុខងារ

**មាត្រា ២១៣.-**

រាជរដ្ឋាភិបាល គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសម្រេចឱ្យបាននូវគោលបំណងរួមក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ២១៤.-**

ក្រុមប្រឹក្សាប្រភេទនីមួយៗ ត្រូវរួមចំណែកក្នុងការសម្រេចឱ្យបាននូវគោលបំណងរួមនេះ ដោយធ្វើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរឱ្យអនុលោមតាមច្បាប់នេះប្រកបដោយប្រសិទ្ធភាព ។

**មាត្រា ២១៥.-**

ក្នុងការពិនិត្យមើលឡើងវិញនូវមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានានិងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវផ្តល់អាទិភាពដល់បញ្ហាដែលទាក់ទងនឹងផ្នែកនានាដូចខាងក្រោម :

-កសិកម្ម

-អប់រំ

-ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន

-សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច

-ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច

-ការប្រើប្រាស់ដីធ្លី

-ការផលិត និងការចែកចាយអគ្គិសនី

-ការគ្រប់គ្រងទឹក

-ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយ សម្ភារៈចាំបាច់ ដើម្បីគាំទ្រ និងចាត់ចែងការទទួលខុសត្រូវទាំងនេះ និង

-តម្រូវការពិសេស ឬ តម្រូវការដែលបានកំណត់ជាក់លាក់ សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រនិងកេរដំណែលវប្បធម៌ផងដែរ ។

**មាត្រា ២១៦.-**

ក្នុងការត្រួតពិនិត្យមើលឡើងវិញនូវមុខងារ និងការទទួលខុសត្រូវនីមួយៗដូចមានចែងក្នុងមាត្រា ២១៥ នៃច្បាប់នេះ ត្រូវផ្តល់អាទិភាពដល់ការពិនិត្យមើលឡើងវិញនូវមុខងារជាមូលដ្ឋាន និងចាំបាច់ដែលមានផលប៉ះពាល់ផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ និងការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។

**មាត្រា ២១៧.-**

គោលបំណងនៃការពិនិត្យមើលឡើងវិញនូវមុខងារ និងការទទួលខុសត្រូវទាំងនេះ គឺដើម្បីកំណត់មុខងារ និងការទទួលខុសត្រូវដែលនឹងត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សាឃុំ ឱ្យក្រុមប្រឹក្សាសង្កាត់ ឱ្យក្រុមប្រឹក្សាស្រុក ឱ្យក្រុមប្រឹក្សាក្រុង ឱ្យក្រុមប្រឹក្សាខេត្ត ឱ្យក្រុមប្រឹក្សារាជធានី ឬ ត្រូវរក្សាទុកជាមុខងារ និងការទទួលខុសត្រូវរបស់ថ្នាក់ជាតិ ។

ការកំណត់ឡើងវិញនូវមុខងារ និងការទទួលខុសត្រូវខាងលើនេះ ត្រូវធានាឱ្យបានថា មុខងារ និងការទទួលខុសត្រូវដែលបានផ្ទេរ ត្រូវធ្វើឡើងជាមួយនឹងការផ្ទេរធនធានសមស្របដើម្បីគ្រប់គ្រង និងចាត់ចែងមុខងារ និងការទទួលខុសត្រូវទាំងនោះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០៨

នស/រកម.០៥០៨/០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ: ៥៥៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ច្បាប់

# ស្តីពី

# សម្បទាន

ច្បាប់នេះត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម

លេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងជំរុញ និងសម្រួលការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដោយហិរញ្ញប្បទានឯកជននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំរើផលប្រយោជន៍សាធារណៈ និងបំពេញសេចក្តីត្រូវការរបស់សង្គម និងសេដ្ឋកិច្ចជាតិ។

**មាត្រា ២.-**

ច្បាប់នេះមានវិសាលភាពគ្រប់គ្រងសម្បទានទាំងឡាយ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ។

សម្បទានត្រូវផ្តល់តាមរយៈកិច្ចសន្យាសម្បទាន ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**មាត្រា ៣.-**

វាក្យសព្ទ័សំខាន់ៗនៅក្នុងច្បាប់នេះមានន័យដូចខាងក្រោមៈ

-**ការអនុញ្ញាត** សំដៅដល់ការអនុញ្ញាត ការជម្រះបញ្ជី ការយល់ព្រម ការផ្តល់អាជ្ញាប័ណ្ណ ការផ្តល់លិខិតអនុញ្ញាត ឬការចុះបញ្ជីនានា ដែលត្រូវទទួលយកពីស្ថាប័នមានសមត្ថកិច្ច ដើម្បីអនុវត្តគម្រោងសម្បទានដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

-**សម្បទាន** សំដៅដល់ទង្វើណាមួយជារបស់រដ្ឋ ដែលស្ថាប័នមានសមត្ថកិច្ចផ្តល់ទង្វើនោះ ទៅឱ្យឯកជននូវផ្នែកណាមួយឬទាំងស្រុងនៃការអនុវត្តគម្រោងលើផ្នែកហេដ្ឋារចនាសម្ព័ន្ធណាមួយដែលជាធម្មតាស្ថាប័នមានសមត្ថកិច្ចនោះ ជាអ្នកទទួលខុសត្រូវ ហើយដែលឯកជននោះ ទទួលភារកិច្ចមួយផ្នែកធំលើការសាងសង់ និង/ឬហានិភ័យ ឬទទួលបាននូវផលចំណេញ តាមរយៈការទូទាត់សងវិញពីរដ្ឋាភិបាលនូវប្រាក់ចំណូល ឬកម្រៃ និង ការ

យកថ្លៃឈ្នួល ដែលបានប្រមូលយកពីអ្នកប្រើប្រាស់ ឬពីអតិថិជន។ ទង្វើរបស់រដ្ឋទាំងនោះ ចាប់ពីពេលនេះតទៅនឹងត្រូវកំណត់ថា“សម្បទាន”នៅក្រោមច្បាប់នេះដោយមិនគិតពីឈ្មោះ ស្របច្បាប់ដែលបានប្រើប្រាស់សម្រាប់ទង្វើនោះឡើយ។

**-សម្បទានិក** សំដៅដល់បុគ្គលដែលអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្រោម កិច្ចសន្យាសម្បទាន ដែលបានធ្វើជាមួយស្ថាប័នជាប់កិច្ចសន្យា។

**-កិច្ចសន្យាសម្បទាន** សំដៅដល់ កិច្ចព្រមព្រៀងដែលភ្ជាប់កាតព្វកិច្ចទៅវិញទៅមករវាងស្ថាប័នជាប់កិច្ចសន្យាជាមួយសម្បទានិក ក្នុងនោះមានការកំណត់ពី គោលការណ៍និង លក្ខខណ្ឌសម្រាប់អនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

**-បុគ្គល** សំដៅដល់ រូបវន្តបុគ្គល ឬនីតិបុគ្គល។

**-គម្រោងសម្បទាន** សំដៅដល់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្រោម ការផ្តល់សម្បទានណាមួយ។

**-ស្ថាប័នជាប់កិច្ចសន្យា** សំដៅដល់ស្ថាប័នមានសមត្ថកិច្ចដែលមានសិទ្ធិចុះកិច្ចសន្យាសម្បទាន ដូចមានចែងក្នុងមាត្រា ៤ នៃច្បាប់នេះ។

**-សំណង់ហេដ្ឋារចនាសម្ព័ន្ធ** សំដៅដល់សំណង់ជារូបវន្តនិងប្រព័ន្ធដែលផ្តល់ សេវាកម្មដោយផ្ទាល់ ឬដោយប្រយោលដល់សាធារណជនទូទៅ។

**-គម្រោងហេដ្ឋារចនាសម្ព័ន្ធ** សំដៅដល់គំនូរប្លង់ ការសាងសង់ ការថែទាំ ឬការធ្វើអាជីវកម្មនៃសំណង់ហេដ្ឋារចនាសម្ព័ន្ធថ្មី ឬការធ្វើទំនើបភាវូបនីយកម្ម ការធ្វើនីតិសម្បទាការពង្រីក ការគ្រប់គ្រង ឬការធ្វើអាជីវកម្មនៃសំណង់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។

**-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** សំដៅដល់គម្រោងវិនិយោគ ដែលទទួលបាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយអនុលោម ទៅតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.~**

ស្ថាប័នមានសមត្ថកិច្ចទាំងអស់ ដែលមានភារកិច្ចទទួលផ្ញើគម្រោងហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងវិស័យ ហេដ្ឋារចនាសម្ព័ន្ធ ដូចមានចែងក្នុងមាត្រា៥ នៃច្បាប់នេះរួមមានក្រសួង ស្ថាប័ន សាធារណៈ នីតិបុគ្គលរបស់រដ្ឋ អាជ្ញាធរមូលដ្ឋាន ដែលបានទទួលប្រតិភូកម្មនូវអំណាចដោយ អនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិចុះកិច្ចសន្យាសម្បទានលើគម្រោង ហេដ្ឋារចនាសម្ព័ន្ធ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន និងមានសិទ្ធិចុះកិច្ចព្រមព្រៀងពាក់ព័ន្ធបន្ទាប់បន្សំ រួមទាំងកិច្ចព្រមព្រៀងដែលមានគោលបំណងសម្រួលការងារ ហិរញ្ញប្បទាន ដូចមានចែងក្នុងមាត្រា៦ និងមាត្រា៧ នៃច្បាប់នេះ និងបទប្បញ្ញត្តិទាំងឡាយ ដែលមានចែង នៅក្នុងអនុក្រឹត្យ។

**មាត្រា ៥.~**

កិច្ចសន្យាសម្បទាន ដែលមានទំនាក់ទំនងទៅនឹងសំណង់ហេដ្ឋារចនាសម្ព័ន្ធតាមរយៈ ការផ្គត់ផ្គង់សេវា ដោយផ្ទាល់ឬដោយប្រយោល ដើម្បីជាប្រយោជន៍សាធារណៈត្រូវបានចូល រួមដោយស្ថាប័នពាក់ព័ន្ធលើវិស័យដូចតទៅ ÷

ក-ការផលិត ការបញ្ជូន និងការចែកចាយ ថាមពលអគ្គិសនី។

ខ-ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធដឹកជញ្ជូន មានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ព្រលាន យន្តហោះ កំពង់ផែ ផ្លូវដែក ព្រែកជីក។

គ-ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ។

ឃ-ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន។

ង-ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្ភារៈបម្រើឱ្យគម្រោងផ្នែកទេសចរណ៍មានជា អាទិ៍ រមណីយដ្ឋាន ទេសចរណ៍ សារមន្ទីរ។

ច-ហេដ្ឋារចនាសម្ព័ន្ធ បម្រើឱ្យវិស័យឧស្ម័ននិងប្រេង មានជាអាទិ៍ បំពង់បង្ហូរប្រេង និងឧស្ម័ន។

ឆ-ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបូមស្តារ ។

ជ-ប្រព្រឹត្តិកម្ម និងការគ្រប់គ្រងសំណល់។

ឈ-ហេដ្ឋារចនាសម្ព័ន្ធសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំនិង វិស័យកីឡា។

ញ-ហេដ្ឋារចនាសម្ព័ន្ធ បម្រើឱ្យតំបន់សេដ្ឋកិច្ចពិសេស និងលំនៅដ្ឋានសង្គម។

ដ-ហេដ្ឋារចនាសម្ព័ន្ធ បម្រើឱ្យប្រព័ន្ធធារាសាស្ត្រ និងការងារកសិកម្ម។

ឋ-វិស័យផ្សេងៗទៀត ដែលច្បាប់ដោយឡែកណាមួយអនុញ្ញាតឱ្យមានការផ្តល់ នូវសម្បទាន។

**មាត្រា ៦.-**

កិច្ចសន្យាសម្បទាន អាចអនុវត្តតាមទម្រង់ដូចខាងក្រោម ៖

-សាងសង់ អាជីវកម្ម និងផ្ទេរ

-សាងសង់ ជួល និងផ្ទេរ

-សាងសង់ ផ្ទេរ និងអាជីវកម្ម

-សាងសង់ ធ្វើម្ចាស់ និងអាជីវកម្ម

-សាងសង់ ធ្វើម្ចាស់ អាជីវកម្ម និងផ្ទេរ

-សាងសង់ សហការ និងផ្ទេរ

-ពង្រីក អាជីវកម្ម និងផ្ទេរ

-ទំនើបភាវូបនីយកម្ម អាជីវកម្ម និងផ្ទេរ

-ទំនើបភាវូបនីយកម្ម ធ្វើម្ចាស់ និងអាជីវកម្ម

-ជួល និងអាជីវកម្ម គ្រប់គ្រង ឬកិច្ចព្រមព្រៀងគ្រប់គ្រង ឬជម្រើសដទៃទៀតនៃ ទម្រង់ទាំងនោះ ឬទម្រង់ប្រហាក់ប្រហែល ដោយរួមបញ្ចូលទាំងការអនុវត្តសំណង់ហេដ្ឋា-រចនាសម្ព័ន្ធនៃសម្ព័ន្ធអាជីវកម្មរួម រវាងសាធារណៈ និងឯកជន។

**មាត្រា ៧.-**

កិច្ចសន្យាសម្បទានណាមួយអាចត្រូវចាប់ផ្តើមធ្វើបាន លុះត្រាតែគម្រោងហេដ្ឋារចនា-សម្ព័ន្ធនោះ ត្រូវបានអនុម័តជាមុនថាជាគម្រោងសម្បទានស្របតាមនីតិវិធីដែលមានចែងនៅក្នុងអនុក្រឹត្យ។

## ជំពូកទី ២
## ការសម្របសម្រួលផ្នែករដ្ឋបាល និងសេវាកម្ម

**មាត្រា ៨.-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជាស្ថាប័នច្រកចេញ-ចូលតែមួយ សម្រាប់ទទួលការអនុ-ញ្ញាតដែលជាតម្រូវការចាំបាច់ ក្នុងការអនុវត្តគម្រោងវិនិយោគ ស្របតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។បន្ទាប់ពីបានទទួលការស្នើសុំអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមកិច្ចសន្យាសម្បទាន ពី សម្បទានិក ដែលជ្រើសរើសឱ្យអនុវត្តគម្រោង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវ :

ក-ផ្តល់ជូននូវការលើកទឹកចិត្តដល់សម្បទានិក ដោយអនុលោមទៅតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

ខ-ធ្វើការបញ្ជាក់អំពីការអនុញ្ញាតទាំងឡាយដែលត្រូវទទួលបាន សម្រាប់គម្រោងសម្បទាន ពីស្ថាប័នមានសមត្ថកិច្ចដែលទទួលខុសត្រូវក្នុងការចេញលិខិតអនុញ្ញាត។

គ-ទទួលយកឱ្យទាន់ពេលវេលានូវរាល់លិខិតអនុញ្ញាត ដែលបានចែងក្នុងមាត្រានេះពីស្ថាប័នពាក់ព័ន្ធ ជំនួសមុខឱ្យសម្បទានិក នៅពេលដែលព័ត៌មាននិងឯកសារចាំបាច់ទាំងឡាយត្រូវបានផ្តល់គ្រប់ចំនួនពីសម្បទានិក។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់រយៈពេលមួយ សម្រាប់ស្ថាប័នទទួលខុសត្រូវក្នុងការផ្តល់លិខិតអនុញ្ញាតលើគម្រោងសម្បទានលើកលែងតែមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីស្ថាប័ននេះ នៅមុនរយៈពេលនៃការកំណត់នោះ។

**មាត្រា ៩.-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាស្ថាប័នសេវាកម្មប្រមូលផ្តុំ ក្នុងការផ្តល់ព័ត៌មានទូទៅតាមការស្នើពីអ្នកវិនិយោគដែលចង់វិនិយោគក្នុងគម្រោងសម្បទាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយរាប់បញ្ចូលទាំងព័ត៌មានដូចមានចែងក្នុងមាត្រា៨ ចំណុច ក និង ខ នៃច្បាប់នេះ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវផ្តល់ជូនអ្នកវិនិយោគដែលមានសក្តានុពលនានានូវការថតចម្លងឯកសារច្បាប់ និងបទប្បញ្ញត្តិផ្សេងៗស្តីអំពីការដាក់ពាក្យសុំជាទូទៅ នៃគម្រោងសម្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១០.-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានភារកិច្ច :

ក-ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលកម្ពុជា អំពីបញ្ហាពាក់ព័ន្ធនឹងគោលនយោបាយសម្បទាន និង ផ្តល់អនុសាសន៍ ដើម្បីកែលំអឱ្យកាន់តែប្រសើរឡើងនូវច្បាប់និងបទប្បញ្ញត្តិទាំងឡាយសម្រាប់អនុវត្តគម្រោងសម្បទាន

ខ-ជួយដល់ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ក្នុងការធ្វើអត្តសញ្ញាណកម្មនិងវាយតម្លៃលើកាលានុវត្តភាពនានា សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធដែលឯកជនធ្វើហិរញ្ញប្បទាន ព្រមទាំងជួយ ផ្សព្វផ្សាយដល់សហគមន៍អ្នកវិនិយោគ នូវគម្រោងទាំងឡាយណាដែលអាចដំណើរការបាន

គ-បង្កើននូវភាពជំនាញចាំបាច់ក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬជួយវាយតម្លៃពីខាងក្រៅ ដើម្បីជួយស្ថាប័នជាប់កិច្ចសន្យា ក្នុងការរៀបចំការដេញថ្លៃ និងការត្រួតពិនិត្យគម្រោងសម្បទានដែលស្មុគស្មាញ

ឃ-លើកការស្នើអំពីនីតិវិធីធ្វើការជ្រើសរើសគំរូនិងគំរូឯកសារសម្រាប់ធ្វើគម្រោងដើម្បីធ្វើសនិទានកម្ម លើការធ្វើហិរញ្ញប្បទាន ការអនុវត្ត និងការត្រួតពិនិត្យគម្រោងសម្បទាន

ង-សម្របសម្រួលក្នុងការកសាងសមត្ថភាព និងការបណ្តុះបណ្តាលដល់មន្ត្រីរាជការ ដែលធ្វើការងារពាក់ព័ន្ធនឹងការងារសម្បទាន

ច-រក្សាទុកនូវបញ្ជីស្តីពីកិច្ចសន្យាសម្បទាន និងរាល់ឯកសារនៃគម្រោងសម្បទាន ដើម្បីទុកឱ្យស្ថាប័នជាប់កិច្ចសន្យាធ្វើការវាយតម្លៃនិងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។

## ជំពូកទី ៣
## ការជ្រើសរើស និងការរៀបចំ សម្បទានិក

### មាត្រា ១១.-

ស្ថាប័នជាប់កិច្ចសន្យា ត្រូវធ្វើការជ្រើសរើសសម្បទានិក តាមនីតិវិធីដេញថ្លៃជាលក្ខណៈជាតិ ឬអន្តរជាតិ ឬតាមនីតិវិធីចរចា ដោយផ្អែកទៅតាមកាលៈទេសៈ ។

នីតិវិធីនៃការជ្រើសរើសសម្បទានិកនឹងមានចែងនៅក្នុងអនុក្រឹត្យ ។

### មាត្រា ១២.-

នៅពេលដែលដំណើរការជ្រើសរើសសម្បទានិកត្រូវបានបំពេញសព្វគ្រប់ ហើយស្ថាប័នជាប់កិច្ចសន្យាក៏បានត្រៀមក្នុងការទទួលពាក្យដេញថ្លៃចុងក្រោយ ឬការស្នើចរចាហើយនោះ ស្ថាប័នជាប់កិច្ចសន្យាត្រូវតែទទួល បាននូវការអនុម័តជាគោលការណ៍សម្រាប់លក្ខខណ្ឌចុងក្រោយនៃកិច្ចសន្យាសម្បទាន តាមការតម្រូវនិងស្របតាមនីតិវិធីដែលនឹងមានចែងនៅក្នុងអនុក្រឹត្យ។

ប្រសិនបើការពិនិត្យឡើងវិញនូវកិច្ចសន្យាសម្បទានដែលបានរៀបចំស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះធ្វើឱ្យ បេក្ខជនដែលបានជ្រើសរើសតាមនីតិវិធីត្រឹមត្រូវហើយ រងនូវផលប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន បេក្ខជននោះអាចដកពាក្យដេញថ្លៃ ឬការស្នើរបស់ខ្លួនដោយមិនទទួលរងនូវការបាត់បង់ប្រាក់តម្កល់សម្រាប់ធានាការដេញថ្លៃឡើយ។

### មាត្រា ១៣.-

បន្ទាប់ពីបានទទួលការអនុម័តយល់ព្រមដូចមានចែងក្នុងមាត្រា១២ នៃច្បាប់នេះស្ថាប័នជាប់កិច្ចសន្យា ត្រូវចេញសេចក្តីជូនដំណឹងពីការយល់ព្រមផ្តល់សម្បទាន ទៅបេក្ខជនដែលបានជ្រើសរើស មុននឹងអនុវត្តការចុះកិច្ចសន្យាសម្បទាននេះ។

ស្ថាប័នជាប់កិច្ចសន្យា និងសម្បទានិក ត្រូវចុះហត្ថលេខាលើកិច្ចសន្យាសម្បទានក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការជូនដំណឹង ស្តីពីការផ្តល់សម្បទាន។

រយៈពេលនេះអាចពន្យារបាន ប្រសិនបើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងស្ថាប័នជាប់កិច្ចសន្យានិងសម្បទានិក ។ ការខកខានរបស់ស្ថាប័នជាប់កិច្ចសន្យាក្នុងការអនុវត្តស្របតាមមាត្រា១៣ កថាខ័ណ្ឌ ទី២ នៃច្បាប់នេះ នឹងអាចឱ្យសម្បទានិកមានសិទ្ធិក្នុងការដកពាក្យដេញថ្លៃ ឬដកការស្នើចរចា ដោយមិនទទួលរងនូវការបាត់បង់ប្រាក់តម្កល់សម្រាប់ធានាការដេញថ្លៃឡើយ។

## មាត្រា ១៤.-

ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបាននូវសេចក្តីជូនដំណឹងពីការយល់ព្រមផ្តល់សម្បទាន សម្បទានិកត្រូវតែបង្កើតដោយរួសរាន់ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានូវនីតិបុគ្គលមួយ ដែលនឹងអនុវត្តគម្រោងសម្បទាននិងដាក់ពាក្យសុំជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីទទួលបាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ស្របតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

## មាត្រា ១៥.-

លើកលែងតែមានការតម្រូវដោយបទប្បញ្ញត្តិនៃច្បាប់នេះឬច្បាប់ដទៃទៀត ភាគីជាប់កិច្ចសន្យាត្រូវកំណត់ ក្នុងកិច្ចសន្យាសម្បទាន នូវករណីដូចខាងក្រោម :

ក-ប្រភេទ វិសាលភាព បមាណពីការងារដែលត្រូវបំពេញ និងសេវាកម្មដែលត្រូវផ្តល់ដោយសម្បទានិក។

ខ-ការលើកទឹកចិត្តដែលត្រូវផ្តល់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការចំណាយ បង្កើនល្បឿននៃការសាងសង់ និងបង្កើនគុណភាពនៃកិច្ចដំណើរការ និងការថែទាំដើម្បីជាប្រយោជន៍សាធារណៈ។

គ-រាល់កម្រៃថ្លៃបង់ការប្រើប្រាស់ ថ្លៃឈ្នួលជួលឬចំណាយផ្សេងៗ ដែលត្រូវដាក់ឱ្យសម្បទានិកអនុវត្ត ត្រូវតែបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច។

ឃ-ការព្រមព្រៀងលើការទទួលយកហានិភ័យរៀងៗខ្លួន ឬការព្រមព្រៀងពីការទទួលយកហានិភ័យរួមគ្នា។

ង-ការកម្រិតសេវាកម្ម និងបមាណីដែលតម្រូវឱ្យសម្បទានិកអនុវត្តនៅក្នុងប្រតិបត្តិការនិងការគ្រប់គ្រងសំណង់ហេដ្ឋារចនាសម្ព័ន្ធនិងផលវិបាកនៃការមិនអនុវត្តស្របតាមកម្រិតសេវាកម្មនិងបមាណីដែលបានកំណត់។

ច-យន្តការបង់ប្រាក់។

ឆ-ការប្តេជ្ញាចិត្ត និងកិច្ចសហប្រតិបត្តិការរបស់ស្ថាប័នជាប់កិច្ចសន្យា និងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ក្នុងការគាំទ្រការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ក្នុងអំឡុងពេលសម្បទាន។

ជ-ករណីផ្សេងៗទៀត ប្រសិនបើភាគីទាំងពីរយល់ថាសមស្រប។

**មាត្រា ១៦.-**

សម្បទានិកត្រូវអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដោយសាមីខ្លួនទទួលបន្ទុកការចំណាយទាំងអស់ និង រ៉ាប់រងរាល់ហានិភ័យហើយមិនត្រូវពឹងផ្អែកលើការសុំឥណទាន ឬការធានាពីស្ថាប័នជាប់កិច្ចសន្យាឡើយ។ ក្នុងកាលៈទេសៈពិសេស ការធានាអាចត្រូវផ្តល់បាន តែការធានានោះត្រូវអនុវត្តស្របទៅនឹងនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុនិងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។

**មាត្រា ១៧.-**

ដោយអនុលោមតាមការដាក់កំហិតណាមួយ ដែលមានចែងក្នុងកិច្ចសន្យាសម្បទាន ឬមាននៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា សម្បទានិកមានសិទ្ធិបង្កើតសិទ្ធិប្រាតិភោគលើទ្រព្យសម្បត្តិ សិទ្ធិ ឬផលប្រយោជន៍របស់ខ្លួន រួមបញ្ចូលនូវអ្វីទាំងឡាយដែលពាក់ព័ន្ធនៅក្នុងគម្រោងសម្បទាន ដើម្បីធានានូវរាល់ហិរញ្ញប្បទានដែលត្រូវការ សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ។

លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យាសម្បទាន ម្ចាស់ភាគហ៊ុននៃសម្បទានិកមានសិទ្ធិធ្វើការអះអាង ឬបង្កើតសិទ្ធិប្រាតិភោគនៅក្នុងភាគហ៊ុនរបស់ខ្លួនជាសម្បទានិក ដើម្បីធានានូវរាល់ហិរញ្ញប្បទាន ដែលត្រូវការសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ។

**មាត្រា ១៨.-**

នៅពេលដែលមានការរំលោភធ្ងន់ធ្ងរពីសំណាក់សម្បទានិក ឬដោយហេតុការណ៍ណាមួយដែលជាមូលហេតុនាំឱ្យមានការបញ្ចប់កិច្ចសន្យាសម្បទាន ស្ថាប័នជាប់កិច្ចសន្យាអាចយល់ព្រមជាមួយស្ថាប័នដែលផ្តល់ ហិរញ្ញប្បទានសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធដោយដាក់ជំនួសសម្បទានិកដោយបុគ្គលថ្មី ដើម្បីចាត់តាំងឱ្យធ្វើកិច្ចការតាមកិច្ចសន្យាសម្បទានដែលមានស្រាប់ ស្របតាមលក្ខខណ្ឌនិងនីតិវិធីដែលបានព្រមព្រៀងគ្នាជាមុន រវាងស្ថាប័នជាប់កិច្ចសន្យាជាមួយស្ថាប័នដែលជាអ្នកផ្តល់ហិរញ្ញប្បទាននោះ។

**មាត្រា ១៩.-**

សិទ្ធិ និងកាតព្វកិច្ចរបស់សម្បទានិកដែលមានចែងក្នុងកិច្ចសន្យាសម្បទាន មិនអាចផ្ទេរទៅតតិយជនបានទេ ប្រសិនបើគ្មានការអនុញ្ញាតជាមុនពីស្ថាប័នជាប់កិច្ចសន្យា។

ការគ្រប់គ្រងផលប្រយោជន៍របស់សម្បទានិក ដែលមានចែងនៅក្នុងកិច្ចសន្យាសម្បទាន មិនអាចផ្ទេរទៅ តតិយជនបានឡើយ ប្រសិនបើគ្មានការអនុញ្ញាតជាមុនពីស្ថាប័នជាប់កិច្ចសន្យា លើកលែងតែចំពោះការអនុវត្តសិទ្ធិ ប្រាតិភោគដែលបានចែងក្នុងមាត្រា១៧ នៃច្បាប់នេះ។

**មាត្រា ២០.-**

លើកលែងតែមានការចែងនៅក្នុងកិច្ចសន្យាសម្បទានច្បាស់លាស់ សម្បទានិកត្រូវទទួលខុសត្រូវលើគំនូរប្លង់និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដោយសាមីខ្លួនទទួលបន្ទុកការចំណាយទាំងអស់ និងរ៉ាប់រងរាល់ហានិភ័យ។គំនូរប្លង់ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធត្រូវតែស្របជាមួយនឹងច្បាប់និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ។ កិច្ចសន្យាសម្បទានអាចតម្រូវឱ្យមានអ្នកជំនាញការឯករាជ្យដើម្បីធ្វើរបាយការណ៍ជូនស្ថាប័នជាប់កិច្ចសន្យាលើករណីផ្សេងៗ ដែលទាក់ទងទៅនឹងសំណង់ហេដ្ឋារចនាសម្ព័ន្ធ។

**មាត្រា ២១.-**

លើកលែងតែមានចែងនៅក្នុងកិច្ចសន្យាសម្បទានច្បាស់លាស់ សម្បទានិកត្រូវធ្វើអាជីវកម្ម និងថែរក្សា សំណង់ហេដ្ឋារចនាសម្ព័ន្ធ ដោយសាមីខ្លួនទទួលបន្ទុកការចំណាយទាំងអស់ និង រ៉ាប់រងរាល់ហានិភ័យស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

លើកលែងតែមានចែងនៅក្នុងកិច្ចសន្យាសម្បទាន សម្បទានិកត្រូវធានានូវនិរន្តភាពក្នុង ការផ្តល់សេវាកម្ម។ ដូចដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន ស្ថាប័នជាប់កិច្ចសន្យាមាន សិទ្ធិកាន់កាប់ការងារអាជីវកម្មនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធជាបណ្តោះអាសន្ន ដើម្បីធានានូវ ប្រសិទ្ធិភាពនៃការផ្តល់សេវាកម្មដោយគ្មានរអាក់រអួល ក្នុងករណីសម្បទានិកមិនបានបំពេញ កាតព្វកិច្ចរបស់ខ្លួន តែតម្រូវឱ្យស្ថាប័នជាប់កិច្ចសន្យាធ្វើការជូនដំណឹងដល់សម្បទានិក ដើម្បី ធ្វើការកែតម្រូវការខកខានមិនបានអនុវត្តក្នុងរយៈពេលនោះ ដូចមានចែងនៅក្នុងកិច្ចសន្យា សម្បទាន ឬប្រសិនបើពុំមានចែងទេ គឺត្រូវធ្វើក្នុងពេលសមស្របណាមួយ។

**មាត្រា ២២.-**

ដើម្បីធានាការអនុវត្តដោយសម្បទានិកនូវកាតព្វកិច្ច ដែលមានចែងក្នុងកិច្ចសន្យាសម្បទាន និងដោយ ផ្អែកតាមតម្រូវការនៃកិច្ចសន្យា សម្បទានិកត្រូវតម្កល់ប្រាក់ធានាការអនុវត្ត កិច្ចសន្យាឱ្យបានពេញលេញសម្រាប់ដំណាក់កាលជាកំណត់នៃគម្រោងសម្បទានជូនស្ថាប័ន ជាប់កិច្ចសន្យា និងទៅតាមទម្រង់ ពេលវេលា និង បរិមាណ ដែលមានចែងនៅក្នុងកិច្ចសន្យា សម្បទាន។

**មាត្រា ២៣.-**

កិច្ចសន្យាសម្បទានអាចផ្តល់កាលានុវត្តភាពឱ្យសហគ្រាស និងស្ថាប័នស្រាវជ្រាវក្នុង ស្រុកមានលទ្ធភាព ចូលរួមនៅក្នុងការអភិវឌ្ឍបច្ចេកវិទ្យាកម្មន្តសាល ឬសកម្មភាពអភិវឌ្ឍ សេដ្ឋកិច្ចនិងសង្គម ដោយសហប្រតិបត្តិការជាមួយសម្បទានិក។ សហប្រតិបត្តិការដែលអាច នាំមកនូវប្រាក់ចំណូលបន្ថែមដល់សម្បទានិក ត្រូវតែផ្តល់ឱ្យសហគ្រាស និងស្ថាប័នរដ្ឋ ឯកជន ក្នុងស្រុកនូវឱកាសដ៏ពិត។ ដើម្បីទទួលបាននូវការបណ្តុះទិញ ការផ្គត់ផ្គង់ទំនិញ ការផ្តល់សេវាកម្ម

ក្នុងស្រុក និងក្រៅប្រទេស ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍបច្ចេកវិទ្យាពាក់ព័ន្ធទៅនឹងសកម្មភាពហេដ្ឋារចនាសម្ព័ន្ធ។

នៅពេលដែលធ្វើការវាយតំលៃឯកសារដេញថ្លៃ ស្ថាប័នជាប់កិច្ចសន្យាអាចគិតគូរដល់សក្តានុពលទូលំទូលាយនៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ដែលលើកឡើងដោយអ្នកដេញថ្លៃ ហើយដែលអាចកំណត់ជាលក្ខណៈវិនិច្ឆ័យនៅក្នុងសេចក្តីជូនដំណឹងអំពីការដេញថ្លៃទាក់ទងទៅនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

## មាត្រា ២៤.-

កិច្ចសន្យាសម្បទាន ត្រូវគ្រប់គ្រងដោយច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

ប្រសិនបើពុំមានច្បាប់ ឬបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ចែងអំពីករណីដែលពាក់ព័ន្ធនោះទេ បទប្បញ្ញត្តិនៃកិច្ចសន្យាសម្បទាន ត្រូវគ្រប់គ្រងដោយច្បាប់ដែលជ្រើសរើសដោយភាគីជាប់កិច្ចសន្យា ហើយដែលច្បាប់នោះមិនមានភាពផ្ទុយគ្នាទៅនឹងច្បាប់នៃព្រះរាជា-ណាចក្រកម្ពុជាឡើយ។

សម្បទានិកមានសិទ្ធិក្នុងការជ្រើសរើសច្បាប់គ្រប់គ្រងនៃកិច្ចព្រមព្រៀងបន្ទាប់បន្សំ ទាក់ទងនឹងការអនុវត្តគម្រោងសម្បទាន។

## មាត្រា ២៥.-

នៅពេលណាដែលកិច្ចសន្យាសម្បទាន បានតម្រូវឱ្យសម្បទានិកផ្ទេរ នៅពេលបញ្ចប់គម្រោងសម្បទាននូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់ លើសំណង់ហេដ្ឋារចនា-សម្ព័ន្ធជូនដល់ស្ថាប័នជាប់កិច្ចសន្យា ឬអ្នកដែលទទួលបានការតែងតាំង ការផ្ទេរនោះ ត្រូវស្របទៅនឹងពេលវេលាដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន។

សំណង់ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវផ្ទេរនោះ ត្រូវមានលក្ខណៈល្អស្របទៅតាមលក្ខ-ខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន និងត្រូវបានជម្រះឱ្យបានជ្រះស្រឡះនូវរាល់បំណុល បន្ទុក សិទ្ធិប្រាតិភោគ និងការតវ៉ាទាមទារនានា។

**មាត្រា ២៦.-**

ស្ថាប័នផ្តល់សម្បទាន ឬស្ថាប័នមានសមត្ថកិច្ចដទៃទៀត ដោយផ្អែកទៅតាមលក្ខខណ្ឌច្បាប់ ត្រូវជួយសម្បទានិកឱ្យទទួលបានសមស្របនូវសិទ្ធិប្រើប្រាស់ដីនិងសិទ្ធិដទៃទៀតដែលពាក់ព័ន្ធទៅនឹងទីតាំងគម្រោងដែលមានភាពចាំបាច់ដើម្បីអនុវត្តគម្រោងសម្បទាន។

សម្បទានិកមានសិទ្ធិប្រើប្រាស់សេវភាព ឬបង្កើតសេវភាពតាមការកំណត់នៃច្បាប់ភូមិបាល ក្នុងករណីដែលជាតម្រូវការសម្រាប់អនុវត្តគម្រោងសម្បទាន។

កិច្ចសន្យាសម្បទានអាចតម្រូវឱ្យសម្បទានិកធ្វើការទូទាត់ការធ្វើលទ្ធកម្មកម្មសិទ្ធិលើដីសិទ្ធិប្រើប្រាស់ដីសេវភាពនិងរបៀបនៃការចំណាយទាំងនោះ។

ចំណាយក្នុងការធ្វើលទ្ធកម្មកម្មសិទ្ធិលើដី សម្រាប់ពង្រីកគម្រោងហេដ្ឋារចនាសម្ព័ន្ធនានាជាបន្ទុករបស់សម្បទានិក លើកលែងតែករណីផ្សេងទៀតដែលមានចែងក្នុងកិច្ចសន្យាសម្បទាន។

**មាត្រា ២៧.-**

សម្បទានិកមានសិទ្ធិទទួល ឬប្រមូលថ្លៃប្រើប្រាស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធ ឬសេវាកម្មដែលខ្លួនបានផ្តល់ឱ្យ។ កិច្ចសន្យាសម្បទានត្រូវចែងអំពីវិធីនិងរូបមន្ត សម្រាប់បង្កើតនិងកែតម្រូវនូវតម្លៃ ឬប្រាក់កម្រៃទាំងនោះ។

ភាគីជាប់កិច្ចសន្យា អាចព្រមព្រៀងលើយន្តការដែលសំដៅធានានូវលំហូរជាប្រក្រតីនៃប្រាក់ចំណូលក្នុងអំឡុងពេលសម្បទាន ដោយការប្រឹងប្រែងរួមគ្នា។

**មាត្រា ២៨.-**

សម្បទានិក មានសិទ្ធិប្តូរប្រាក់ចំណូលរបស់ខ្លួនពីរូបិយវត្ថុក្នុងស្រុកទៅជារូបិយប័ណ្ណបរទេស និងមានសិទ្ធិផ្ទេររូបិយប័ណ្ណទាំងនោះទៅបរទេស ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២៩.-**

មានតែក្នុងអាណត្តិនៃកិច្ចសន្យាសម្បទានប៉ុណ្ណោះ ដែលសម្បទានិកមានសិទ្ធិទទួលបាននូវសំណង ក្នុងករណីចំណាយសម្រាប់ការអនុវត្តកិច្ចសន្យាសម្បទានបានកើនឡើងច្រើន ឬក្នុងករណីចំណូលដែលសម្បទានិកទទួលបានពីការអនុវត្តកិច្ចសន្យាមានការថយចុះច្រើន បើប្រៀបធៀបជាមួយចំណាយ និងចំណូលក្នុងការអនុវត្តកិច្ចសន្យាដែលបានគ្រោងទុកពីដំបូង ដោយមូលហេតុនៃការកែប្រែច្បាប់ ឬបទប្បញ្ញត្តិដែលអនុវត្តចំពោះសំណង់ហេដ្ឋារចនាសម្ព័ន្ធ ឬចំពោះសេវាកម្មដែលខ្លួនបានផ្តល់ បន្ទាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យាសម្បទាន។ សម្បទានិកត្រូវបង្ហាញពីផលវិបាកដែលបណ្តាលមកពីការកែប្រែនេះ និងពីផលវិបាកផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធ។

**មាត្រា ៣០.-**

សម្បទានិកត្រូវបង់សួយសារឬកម្រៃសម្បទាន តាមការកំណត់នៃកិច្ចសន្យាសម្បទានជូនរដ្ឋ ស្របតាមគោលការណ៍និងលក្ខខណ្ឌដែលបានបញ្ជាក់ក្នុងកិច្ចសន្យាសម្បទាន។

**មាត្រា ៣១.-**

ស្ថាប័នជាប់កិច្ចសន្យាត្រូវធ្វើការអង្កេតនិងធ្វើអធិការកិច្ច លើសកម្មភាពគម្រោងសម្បទាន ដើម្បីធានាថាគម្រោងបានសាងសង់ធ្វើអាជីវកម្ម និងថែទាំស្របទៅតាមច្បាប់និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា និង លក្ខខណ្ឌនៃកិច្ចសន្យាសម្បទាន។ ស្ថាប័នជាប់កិច្ចសន្យាមានសិទ្ធិចូលពិនិត្យកិច្ចការសំណង់ហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាការត្រួសបួង របាយការណ៍និងទិន្នន័យផ្សេងៗដែលមានភាពចាំបាច់សម្រាប់ធ្វើការអង្កេត និង ធ្វើអធិការកិច្ច ដោយអនុលោមទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាសម្បទាន។

ប្រសិនបើមិនមានករណីចាំបាច់ ការអង្កេតនិងអធិការកិច្ចនេះ មិនត្រូវជ្រៀតជ្រែកទៅនឹងដំណើរការការងារ និងការផ្តល់សេវាកម្មរបស់សម្បទានិកឡើយ។

**មាត្រា ៣២.-**

រាល់សកម្មភាពដែលទាក់ទងនឹងការអនុវត្តច្បាប់នេះ ត្រូវអនុវត្តឱ្យស្របទៅនឹងតម្រូវការនៃបមាណីសុខភាពនិងសុវត្ថិភាពនិងការងារបរិស្ថាន ដោយសម្បទានិកត្រូវថែរក្សាគ្រប់ពេលវេលានូវផែនការជាយថាហេតុនេះ ដើម្បីទប់ទល់នឹងគ្រោះថ្នាក់ និងភាពអាសន្នបន្ទាន់ដែលអាចនាំឱ្យ បាត់បង់ជីវិត ឬរងរបួស ការពុល ឬ ការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិដែលតម្រូវឱ្យមានដោយច្បាប់និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជានិងកិច្ចសន្យាសម្បទាន។

**មាត្រា ៣៣.-**

ក្នុងករណីដែលសំណង់ហេដ្ឋារចនាសម្ព័ន្ធ ត្រូវផ្ទេរជូនស្ថាប័នមានសមត្ថកិច្ច នៅពេលបញ្ចប់កិច្ចសន្យា សម្បទាន សម្បទានិកត្រូវផ្តល់នូវការបណ្តុះបណ្តាលជូនជនកម្ពុជា ដើម្បីអ្នកទាំងនោះអាចទទួលរ៉ាប់រងជំនួសនៅគ្រប់កម្រិត ក្នុងការធ្វើអាជីវកម្មនិងថែទាំសំណង់ហេដ្ឋារចនាសម្ព័ន្ធនោះជាបន្ត។ កិច្ចការទាំងនេះអាចធ្វើ នៅមុនពេលផុតកំណត់នៃរយៈពេលសម្បទានបាន ស្របទៅតាមលក្ខខណ្ឌដែលបានព្រមព្រៀងជាមួយស្ថាប័នជាប់កិច្ចសន្យានៅក្នុងកិច្ចសន្យាសម្បទាន។

**មាត្រា ៣៤.-**

ពាក់ព័ន្ធនឹងសកម្មភាពដែលទាក់ទងនឹងការអនុវត្តច្បាប់នេះ បុគ្គលសញ្ជាតិខ្មែរដែលចូលរួមប្រកួតប្រជែងការងារផ្គត់ផ្គង់ អាចត្រូវបានផ្តល់នូវកាលានុវត្តភាពពិតប្រាកដដើម្បីទទួលបាននូវការបញ្ជាទិញសម្រាប់ ការសាងសង់ ការផ្គត់ផ្គង់ទំនិញ និងសេវាកម្ម។

**មាត្រា ៣៥.-**

កិច្ចសន្យាសម្បទានមិនត្រូវបង្កើតនូវឯកាធិភាពឬបង្កើតនូវសិទ្ធិផ្តាច់មុខឡើយ។ ប៉ុន្តែដើម្បីជាផលប្រយោជន៍សាធារណៈ សិទ្ធិផ្តាច់មុខអាចបញ្ចូលបានក្នុងកិច្ចសន្យាសម្បទានដែលនឹងមានចែងនៅក្នុងអនុក្រឹត្យ។

**មាត្រា ៣៦.-**

សម្បទានិកត្រូវធានាថា ជនណាដែលធ្វើការឬផ្តល់សេវាអោយខ្លួន ដោយផ្ទាល់ក្តី ឬតាមរយៈនិយោជិតក្តីឬតាមរយៈអ្នកទទួលម៉ៅការក្តីឬអ្នកម៉ៅការបន្តក្តីត្រូវតែបំពេញកិច្ចការ ស្របទៅនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

ប្រសិនបើមានការខូចខាតដល់តតីយជន បង្កឡើងដោយជនណាម្នាក់ដែលធ្វើកិច្ចការឱ្យសម្បទានិកហើយតម្រូវឱ្យមានសំណង សម្បទានិកនិងអ្នកប្រព្រឹត្ត ត្រូវទទួលទូទាត់សំណងនោះតាមការទទួលខុសត្រូវរួមគ្នា និងទីទៃពីគ្នា។

## ជំពូកទី ៤
## ការបញ្ចប់អាណត្តិនៃសម្បទាន

**មាត្រា ៣៧.-**

កិច្ចសន្យាសម្បទាន ត្រូវបញ្ជាក់អំពីរយៈពេលសម្បទាន ដែលមិនត្រូវលើសពី ៣០ (សាមសិប) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាសម្បទាន ដោយផ្អែកតាមមាត្រា១៣ នៃច្បាប់នេះ។ ក្នុងករណីចាំបាច់ ដោយយោងទៅលើប្រភេទនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរាជរដ្ឋាភិបាលកម្ពុជាអាចកំណត់រយៈពេលសម្បទានវែងជាងនេះ។

រយៈពេលសម្បទាន ដែលបានកំណត់នៅក្នុងកិច្ចសន្យាសម្បទាន មិនអាចពន្យារបានឡើយ លើកលែងតែជាលទ្ធផលដែលចេញមកពីស្ថានភាពដូចខាងក្រោម :

១-ពន្យារដើម្បីបង្កើយការងារ ឬការបង្អាក់ដំណើរការដោយមូលហេតុនៃការរំលោភកិច្ចសន្យាដោយស្ថាប័នជាប់កិច្ចសន្យា ឬដោយទង្វើនៃស្ថាប័នមានសមត្ថកិច្ចដទៃទៀត។

២-ពន្យារដើម្បីបង្កើយការងារ ឬការបង្អាក់ដំណើរការដោយហេតុការណ៍ប្រធានសក្តិ ដូចដែលមានបញ្ជាក់ក្នុងកិច្ចសន្យាសម្បទាន ហើយដែលនាំឱ្យសម្បទានិកមិនអាចមានលទ្ធភាពបំពេញបានមកវិញនូវការចំណាយ ឬការខាតបង់ដែលបានបណ្តាលមកពីស្ថានភាពខាងលើរួមទាំងការធានារ៉ាប់រងលើគម្រោងសម្រាប់រយៈពេលសម្បទានដំបូង។

រយៈពេលសម្បទានដូចមានចែងនៅក្នុងកិច្ចសន្យាសម្បទាន អាចត្រូវបន្តបានដើម្បីអនុញ្ញាតឱ្យសម្បទានិកអាចស្តារចំណាយបន្ថែមដែលកើតឡើងដោយសារមានលក្ខខណ្ឌថ្មីៗរបស់ស្ថាប័នជាប់កិច្ចសន្យាដែលពុំបានគិតទុកជាមុននៅក្នុងកិច្ចសន្យាសម្បទាន ប្រសិនបើសម្បទានិកពុំអាចស្តារឡើងវិញបាននូវចំណាយទាំងនោះនៅក្នុងរយៈពេលសម្បទានដែលបានចែង។

**មាត្រា ៣៨.-**

កិច្ចសន្យាសម្បទានត្រូវបញ្ជាក់ ដោយមានភាពសមស្រប អំពីលក្ខខណ្ឌដែលផ្តល់សិទ្ធិឱ្យភាគីមួយអាចបញ្ចប់កិច្ចសន្យាមុនថ្ងៃផុតកំណត់នៃរយៈពេលសម្បទាន ព្រមទាំងបញ្ជាក់អំពីសិទ្ធិ និងកាតព្វកិច្ចនៃភាគីជាប់កិច្ចសន្យា ប្រសិនបើមានការបញ្ចប់កិច្ចសន្យាមុនពេលកំណត់។ ប្រសិនបើមានបញ្ជាក់ក្នុងកិច្ចសន្យាសម្បទាន ករណីប្រធានសក្តិ អាចនាំឱ្យភាគីមួយមានសិទ្ធិបញ្ចប់កិច្ចសន្យាសម្បទានបាន។

ក្នុងករណីដែលការបញ្ចប់កិច្ចសន្យាបណ្តាលមកពីការរំលោភធ្ងន់ធ្ងរ ដោយស្ថាប័នជាប់កិច្ចសន្យា ឬដោយស្ថាប័នមានសមត្ថកិច្ចដទៃទៀតលើកាតព្វកិច្ចទាក់ទងទៅនឹងគម្រោងសម្បទាន សម្បទានិកមានសិទ្ធិទទួលបាននូវការប៉ះប៉ូវសំណង ដោយអនុលោមទៅតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាសម្បទាន រួមបញ្ចូលទាំងតម្លៃត្រឹមត្រូវនៃការងារដែលបានធ្វើការចំណាយដែលមានឬការខាតបង់ដែលទទួលរងដោយសម្បទានិក រួមទាំងការខាតបង់ប្រាក់ចំណេញដែលមានភាពសមស្រប។

**មាត្រា ៣៩.-**

វិវាទរវាងស្ថាប័នជាប់កិច្ចសន្យានិងសម្បទានិក ត្រូវដោះស្រាយដោយអនុលោមទៅតាមយន្តការដោះស្រាយវិវាទដែលបានកំណត់នៅក្នុងកិច្ចសន្យាសម្បទាន ដោយរាប់បញ្ចូលទាំងការដោះស្រាយតាមរយៈមជ្ឈត្តករអន្តរជាតិ ប្រសិនបើមានការព្រមព្រៀងរបស់គូភាគី។

សេចក្តីសម្រេចដែលចេញដោយតុលាការមានសមត្ថកិច្ច ឬដោយមជ្ឈត្តករ ស្របទៅតាមមាត្រានេះ ត្រូវមានសុពលភាព និងត្រូវអនុវត្តដោយស្ថាប័នជាប់កិច្ចសន្យា និងសម្បទានិក អនុលោមទៅតាមខ្លឹមសារនៃសេចក្តីសម្រេចនោះ។

**មាត្រា ៤០.-**

ស្ថាប័នជាប់កិច្ចសន្យា ជាអ្នកទទួលខុសត្រូវដើម្បីធានាថា កិច្ចសន្យាសម្បទាន ត្រូវអនុវត្តដោយត្រឹមត្រូវ និងត្រូវបង្កើតនូវយន្តការព្រមទាំងនីតិវិធីសម្រាប់ត្រួតពិនិត្យ សម្របសម្រួលការអនុវត្ត និងដំណើរការនៃកិច្ចសន្យាសម្បទាន ហើយរាយការណ៍ស្តីពីការគ្រប់គ្រងកិច្ចសន្យាសម្បទាន ក្នុងរបាយការណ៍ថវិកាប្រចាំឆ្នាំនៃស្ថាប័នជាប់កិច្ចសន្យា ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង /ឬក្រសួងពាក់ព័ន្ធដែលទទួលខុសត្រូវ។

**មាត្រា ៤១.-**

មុននឹងឈានដល់ការព្រមព្រៀងធ្វើការកែសម្រួលកិច្ចសន្យាសម្បទាន ស្ថាប័នជាប់កិច្ចសន្យាត្រូវតែទទួលបាននូវការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នមានសមត្ថកិច្ចដែលបានចូលរួមអនុម័តកិច្ចសន្យាសម្បទានដំបូង។

នីតិវិធីនៃការកែសម្រួលនេះនឹងមានចែងនៅក្នុងអនុក្រឹត្យ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ៤២.-**

រូបវន្តបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលរងទណ្ឌកម្មតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។

អ្នកសមគំនិតត្រូវទទួលទោសដូចចារីដែរ។

នីតិបុគ្គលត្រូវទទួលខុសត្រូវ ឬទទួលទណ្ឌកម្មពិន័យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ជាធរមាន ប្រសិនបើនិយោជិតភ្នាក់ងារ ឬបុគ្គលិករបស់ខ្លួន ដែលធ្វើសកម្មភាពក្នុងក្របខ័ណ្ឌនៃការងារ ឬដោយមានការអនុញ្ញាតពីខ្លួន ត្រូវទទួលទណ្ឌកម្មតាមបទប្បញ្ញត្តិនៃកថាខ័ណ្ឌទី ១ ខាងលើ។

មន្ត្រីរាជការដែលប្រព្រឹត្តល្មើស ឬធ្វេសប្រហែសដោយចេតនា ក្នុងការបំពេញតួនាទីរបស់ខ្លួនពាក់ព័ន្ធការងារសម្បទាន ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាលថែមទៀតស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ៤៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

# សន្ទានុក្រម

## LEXICON

**-សាងសង់ អាជីវកម្ម និង ផ្ទេរ ហៅកាត់ "ស.អ.ផ "**(Build Operate and Transfer(BOT)៖ស្ថាប័នមានសមត្ថកិច្ច ផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់សិទ្ធិឱ្យឯកជនធ្វើអាជីវកម្មយកកម្រៃក្នុងរយៈមួយដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន។ ផុតរយៈពេលនោះ ឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានលក្ខណៈល្អតាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យស្ថាប័នមានសមត្ថកិច្ចវិញ។

**-សាងសង់ ជួល និង ផ្ទេរ ហៅកាត់ "ស.ជ.ផ "** (Build Lease and Transfer(BLT)) ៖ ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់សិទ្ធិឱ្យឯកជនជួលសំណង់នោះពីស្ថាប័នមានសមត្ថកិច្ចក្នុងរយៈពេលមួយដែលបានកំណត់ក្នុងកិច្ចសន្យាជួល តាមតំលៃឯកភាពគ្នាដើម្បីធ្វើអាជីវកម្ម។

ផុតរយៈពេលនោះឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានលក្ខណៈល្អ តាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យស្ថាប័នមានសមត្ថកិច្ចវិញ។

**-សាងសង់ ផ្ទេរ និង អាជីវកម្ម ហៅកាត់ "ស.ផ.អ "** (Build Transfer and Operate(BOT)) ៖ ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយត្រូវផ្ទេរសំណង់នោះមកឱ្យស្ថាប័នមានសមត្ថកិច្ចកាន់កាប់វិញ ក្រោយពេលសាងសង់រួច។ ស្ថាប័នមានសមត្ថកិច្ចប្រគល់សិទ្ធិឱ្យឯកជនធ្វើអាជីវកម្មលើសំណង់នោះ ក្នុងរយៈពេលមួយដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន។

**-សាងសង់ ធ្វើម្ចាស់ និង អាជីវកម្ម ហៅកាត់ "ស.ម.អ "**(Build Own and Operate(BOO)) ៖ ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់ផ្តាច់ឱ្យឯកជនធ្វើជាកម្មសិទ្ធិករលើសំណង់នោះហើយ ឯកជនធ្វើអាជីវកម្មយកកម្រៃលើសំណង់នោះ សម្រាប់បម្រើឱ្យផលប្រយោជន៍សាធារណៈក្រោមលក្ខខណ្ឌដែលមានការឯកភាពគ្នារវាងភាគីទាំងពីរ និងដែលមានចែងក្នុងកិច្ចសន្យាសម្បទាន។

**-សាងសង់ ធ្វើម្ចាស់ អាជីវកម្ម និង ផ្ទេរ ហៅកាត់ "ស.ម.អ.ផ "** (Build Own Operate and Transfer(BOOT)) : ស្ថាប័នមានសមត្ថកិច្ច ផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់ផ្តាច់ឱ្យឯកជនធ្វើជាកម្មសិទ្ធិករ លើសំណង់នោះហើយឯកជនជាអ្នកធ្វើអាជីវកម្មយកកម្រៃក្នុងរយៈពេលមួយជាកំណត់។ ផុតរយៈពេលកំណត់ឯកជនត្រូវផ្ទេរនូវសិទ្ធិសិទ្ធិកាន់កាប់និងផលប្រយោជន៍ ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈល្អ តាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យស្ថាប័នមានសមត្ថកិច្ចវិញ។

**-សាងសង់ សហការ និង ផ្ទេរ ហៅកាត់ "ស.ស.ផ "**(Build Corporate and Transfer(BCT)) : ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយស្ថាប័នមានសមត្ថកិច្ចនោះ និង ឯកជនសហការគ្នាក្នុងការធ្វើអាជីវកម្ម គ្រប់គ្រង កាន់កាប់ទទួលចំណេញ-ខាត និងរងនូវហានិភ័យនានា ដែលទាក់ទងនឹងអាជីវកម្មរួមគ្នា ក្នុងរយៈពេលដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន។ ផុតរយៈពេលកំណត់ឯកជនត្រូវផ្ទេរ នូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈល្អតាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យស្ថាប័នមានសមត្ថកិច្ចវិញ។

**-ពង្រីក អាជីវកម្ម និង ផ្ទេរ ហៅកាត់ "ព.អ.ផ "**(Expand Operate and Transfer(EOT)) : ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើការពង្រីកនូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់សិទ្ធិឱ្យឯកជនធ្វើអាជីវកម្មយកកំរៃលើទីតាំងពង្រីកនោះ ក្នុងរយៈពេលមួយដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន។ ផុតរយៈពេលនោះ ឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់និងផលប្រយោជន៍ទាំងអស់នៃទីតាំងពង្រីកដែលមានលក្ខណៈល្អ តាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យស្ថាប័នមានសមត្ថកិច្ចវិញ។

- **ទំនើបភាវូបនីយកម្ម អាជីវកម្ម និង ផ្ទេរ ហៅកាត់ "ទ.អ.ផ "**(Modernize Operate and Transfer(MOT)): ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជន ធ្វើឱ្យមានភាពទំនើបនូវសំណង់ហេដ្ឋារចនាសម្ព័ន្ធរួចប្រគល់សិទ្ធិឱ្យឯកជនធ្វើអាជីវកម្មយកកម្រៃលើសំណង់ដែលបានធ្វើឱ្យមានភាពទំនើបនោះក្នុងរយៈមួយដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន ។ ផុតរយៈពេលនោះ ឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់នៃសំណង់ដែលបានធ្វើឱ្យមានភាពទំនើប និងមានលក្ខណៈល្អតាមលក្ខខណ្ឌនៃកិច្ចសន្យា មកឱ្យស្ថាប័នមានសមត្ថកិច្ចវិញ។

**-ទំនើបភាវូបនីយកម្ម ធ្វើម្ចាស់ និងអាជីវកម្ម ហៅកាត់ "ទ.ម.អ "**Modernize Own and Operate (MOO)): ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើឱ្យមានភាពទំនើបនូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់សិទ្ធិឱ្យឯកជនធ្វើជាកម្មសិទ្ធិករលើសំណង់នោះ និងធ្វើអាជីវកម្មយកកម្រៃលើសំណង់សម្រាប់បំរើផលប្រយោជន៍សាធារណៈ ក្រោមលក្ខខណ្ឌដែលមានការឯកភាពគ្នារវាងភាគីទាំងពីរ និង ដែលមានកំណត់ក្នុងកិច្ចសន្យាសម្បទាន។

**-ជួល និង អាជីវកម្មគ្រប់គ្រង ឬ កិច្ចព្រមព្រៀងគ្រប់គ្រង:** ជាកិច្ចសន្យាដែលស្ថាប័នមានសមត្ថកិច្ចយល់ព្រមជួលឱ្យឯកជនធ្វើអាជីវកម្ម នៅលើសំណង់ហេដ្ឋារចនាសម្ព័ន្ធក្នុងរយៈពេលមួយជាកំណត់ ឬ ស្ថាប័ននោះធ្វើអាជីវកម្មខ្លួនឯង ដោយ ជួលឯកជនមកគ្រប់គ្រង ឬស្ថាប័នមិន ធ្វើអាជីវកម្មលើសំណង់នោះទេ តែបានជួលឯកជនមកធ្វើអាជីវកម្មក្រោមការគ្រប់គ្រងរបស់ស្ថាប័នមានសមត្ថកិច្ច ដោយផ្តល់ថ្លៃឈ្នួលតាមការព្រមព្រៀងឯកភាព ដើម្បីបំរើផលប្រយោជន៍ សាធារណៈ។

ការជួលខាងលើនេះ អនុវត្តសម្រាប់តែ ប្រភេទគម្រោងសម្បទាន ដែលមានចែងនៅក្នុងអនុក្រឹត្យប៉ុណ្ណោះ។

# ច្បាប់

## ស្ដីពី

## ការគ្រប់គ្រងរដ្ឋបាល
## ឃុំ សង្កាត់

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសជាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភះ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :៕.

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសំរេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវ៚.

សំរេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។



Ba 1

មាត្រា ១១.-

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

មាត្រា ១២.-

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជាសាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមាជិកដទៃទៀតដែរ ។

មាត្រា ១៣.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

**មាត្រា ១៤.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញល័ក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម:

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

**មាត្រា ១៦.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ ៕

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវចាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះមានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ ពុំបណ្តាលឱ្យផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។/.

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្តាលឱ្យមានផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្តាលឱ្យមានការផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិបន្ទាប់ ។

**មាត្រា ១៩.-**

ក្នុងអំឡុងពេល ១៤ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

**មាត្រា ២០.-**

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីគោលការណ៍នានាសំរាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ល។

មាត្រា ២២.-

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការបាន លុះត្រាតែមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិងកំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។

មាត្រា ២៣.-

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីរបៀបរបបប្រជុំខាងលើនេះ ។

មាត្រា ២៤.-

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ ។ល។

# ជំពូកទី ៣
# រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម :

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប :

-ជំទប់ទី ១ មួយរូប

-ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប :

-ចៅសង្កាត់រងទី ១ មួយរូប

-ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។ល។

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់ អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច :

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិ ឱ្យបានសមស្រប ។៚

មាត្រា ៣២.-

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខ-ជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ៣៣.-

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

មាត្រា ៣៤.-

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

មាត្រា ៣៥.-

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។ល។

**មាត្រា ៣៦.-**

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

**មាត្រា ៣៧.-**

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្សេងៗតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងបាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៨.-**

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សា ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។ល។

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ នឹងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.-**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្ដីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្ដល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម

ប្រឹ.

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

**មាត្រា ៤០.-**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤
## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៤១.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចិរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។

- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ល។

មាត្រា ៤៣.-

ក្នុងតួនាទីបំពេញកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ

- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ

- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ

- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក

- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជា-ពលរដ្ឋ ។

**មាត្រា ៤៤.-**

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសម្ព័ហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

**មាត្រា ៤៥.-**

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ

- ប្រៃសណីយ៍និងទូរគមនាគមន៍

- ការពារប្រទេស ល.។.

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសំរុះសំរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។៚.

មាត្រា ៤៩.-

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំ សង្កាត់សាមីនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ៥០.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទំរង់និងបែបបទ ដើម្បីឱ្យឃុំ សង្កាត់រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៥១.-

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ សង្កាត់
- ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ
- ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឱ្យពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។ ៚

មាត្រា ៥២.-

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះទេ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

មាត្រា ៥៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- ប៉ាន់ប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចបំរែកអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

មាត្រា ៥៤.-

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។៚

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនិងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតំរូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

មាត្រា ៥៨.-

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ៥៩.-

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

មាត្រា ៦០.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៦១.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

មាត្រា ៦២.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ស.ក.

**មាត្រា ៦៣.-**

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦៤.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ៚

## មាត្រា ៦៥.-

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កែតំរូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសំរួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## មាត្រា ៦៦.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតំលៃរាល់ការអនុវត្តផែនការ កម្មវិធី គំរោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាពនិងមានការទទួលខុសត្រូវខ្ពស់ ។

## មាត្រា ៦៧.-

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យនិងការវាយតំលៃចំពោះផែនការ កម្មវិធីនិងគំរោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។

## មាត្រា ៦៨.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីផ្សេងៗក្នុងការអនុវត្តផែនការនិងក្នុងការត្រួតពិនិត្យ វាយតំលៃចំពោះការប្រើប្រាស់មូលនិធិសំរាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

## មាត្រា ៦៩.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី :

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់នាឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់ ។ល។

- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្លៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧
## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។ ៚

**មាត្រា ៧៤.-**

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ។

ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិងពន្ធនៃការជួល ។

ក្នុងករណីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់ ។

ប្រភេទ កំរិតនិងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។

**មាត្រា ៧៥.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន ។

ធនធានវិភាជន៍នេះរួមមានៈ

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាននិងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ ។

ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង ។

ការរៀបចំនិងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៦.-**

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត ។

ប្រាក់កំរៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ ។ល។

រាជរដ្ឋាភិបាលឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលត្រូវផ្តល់កំរៃសមស្របដល់ឃុំ សង្កាត់ ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ ។

ក្នុងករណីដែលការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសំរាប់ផ្តល់ឱ្យឃុំ សង្កាត់ ។

ការរៀបចំប្រាក់កំរៃខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៧.-**

រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ។

មូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់ ។

ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្តឬតាមអត្រាជាក់លាក់មួយសំរាប់ថេរៈវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីអនុវត្តជាក់ស្តែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.-**

មូលនិធិឃុំ សង្កាត់បានមកពី :

- ការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋ ពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ
- អនុប្បទាននិងការខ្ចីពីប្រភពក្នុងប្រទេសនិងក្រៅប្រទេស ។

ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ ។

របៀបរបបចាត់ចែង វិធាននៃការប្រើប្រាស់និងនីតិវិធីនៃការបើកប្រាក់ចំណាយពីមូលនិធិឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៩.-**

ឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ។ល។



Bn hw

ថវិកាឃុំ សង្កាត់ត្រូវរៀបចំទៅតាមទំរង់មួយនិងអនុម័តនៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រពន្ធ័ថវិកាជាតិ ។

ថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូលសរុបនិងចំណាយសរុប ។

ឃុំ សង្កាត់អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពនិងសេចក្ដីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ។

នីតិវិធីនៃការរៀបចំនិងការអនុម័តថវិកាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨០.-**

ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។

ឃុំ សង្កាត់មិនអាចធានារ៉ាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ ។

**មាត្រា ៨១.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯងនិងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ ។

ឃុំ សង្កាត់អាចប្រើប្រាស់និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង ។

ឃុំ សង្កាត់ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យៗបានគង់វង្ស ហើយទ្រព្យសម្បត្តិទាំងនោះ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

នីតិវិធីចាត់ចែងនិងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ឃុំ សង្កាត់ត្រូ[illegible]ឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួនដែលរួមមាន ៖ ៨.ក.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ
- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ
- តំរូវការផ្សេងៗ ក្នុងការជ្រើសរើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

វិន័យរួមមាន :

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើ អាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។ល។

ក្នុងករណីបានអនុវត្តបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តបភាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩

## អន្តរប្បញ្ញត្តិ

### មាត្រា ៨៥.-

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

### មាត្រា ៨៦.-

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនានាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

### មាត្រា ៨៧.-

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។ ..

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្ដីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា

- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសំរបសំរួលរវាងឃុំ សង្កាត់ ពីរឬច្រើន ។

- បណ្ដុះបណ្ដាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់

- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់

- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់

- វិះរកមធ្យោបាយសំរាប់ផ្ដល់ព័ត៌មាននិងគំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ

- ផ្ដល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្ដល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ

- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ

- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ។ល។

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្តីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្តូរឈ្មោះឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៨នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។៚

រាជធានីភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

ស ខេង     យូ ហុកគ្រី

លេខ : ៧០ ច.ល

[illegible]

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែ ៧ ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] តាន់

មាត្រា ៥ .- ឯកឧត្តមរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

***

**អនុក្រឹត្យលេខ ១០៣ អនក្រ.បក**

**ស្តីពីអត្រានុកូលដ្ឋាន**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៦ ក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងយុត្តិធម៌
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

## សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់បែបបទ និង នីតិវិធី នៃការងារអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ .-**

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និង ស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ និង ដែលបង្កើតអោយជននោះមានសិទ្ធិ និង ករណីយកិច្ច ។

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និង ជនបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែលសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

សំបុត្រអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍និងសំបុត្រមរណភាព។

**មាត្រា ៣ .-**

ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអត្រានុកូលដ្ឋានជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ គ្រប់រូប ។

**មាត្រា ៤ .-**

រាល់ការសុំចុះសៀវភៅអត្រានុកូលដ្ឋាន កំណើត និង មរណភាព អ្នករាយការណ៍ និង ឬ សាក្សី និង ឬ សាមីខ្លួនត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះការសុំចុះសៀវភៅអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ សាមីខ្លួន និង សាក្សី ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៥ .-**

ទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយឯកភាពគ្នាទូទាំងប្រទេស ។ គំរូសំបុត្រអត្រានុកូលដ្ឋាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ៦ ._

ការចុះសៀវភៅអត្រានុកូលដ្ឋាន សម្រាប់ព្រះរាជវង្សានុវង្ស ត្រូវអនុវត្តដោយឡែក ដោយប្រគល់ភារកិច្ចនេះជូនរដ្ឋមន្ត្រីព្រះបរមរាជវាំង ។

មាត្រា ៧ ._

រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ ។

មន្ត្រីអត្រានុកូលដ្ឋាន មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងទេ ។

រាល់ការចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋាន មានចែងក្នុងជំពូកទី ១០ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## អំពីមន្ត្រីអត្រានុកូលដ្ឋាន

មាត្រា ៨ ._

មេឃុំ ឬ ចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនដីឃុំ ឬ សង្កាត់ ដែលខ្លួនគ្រប់គ្រង ។

នៅពេលដែលមេឃុំ ឬ ចៅសង្កាត់អវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរអោយជំទប់ ឬ ចៅសង្កាត់រង តាមឋានានុក្រម និង រាយការណ៍ជូនអភិបាលស្រុក ឬ ខណ្ឌតាមផ្លូវការ ។

ក្នុងករណីមេឃុំ ឬ ចៅសង្កាត់អវត្តមានដោយស្លាប់ ឬ ដោយបញ្ឈប់ពីមុខតំណែង ក្នុងចន្លោះពេលដែលមិនទាន់មានការរៀបចំមេឃុំ ឬ ចៅសង្កាត់ថ្មី សិទ្ធិជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់ជូនទៅ ជំទប់ ឬ ចៅសង្កាត់រង តាមឋានានុក្រម ។

មាត្រា ៩ ._

មន្ត្រីអត្រានុកូលដ្ឋានមានភារកិច្ច ៖

-ទទួលពិនិត្យ កត់ត្រា រឿងហេតុសំខាន់ៗទាក់ទងនឹង កំណើត អាពាហ៍ពិពាហ៍ មរណភាពនៃជនទាំងឡាយចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន

-ចេញសេចក្តីចម្លង ឬ សម្រង់ នៃអត្រានុកូលដ្ឋាន ដែលមានក្នុងឆ្នាំមិនទាន់ដាច់

-កែតម្រូវអក្ខរាវិរុទ្ធ លើអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ តាមលក្ខខណ្ឌមាត្រា ១៣ នៃអនុក្រឹត្យនេះ

-អនុញ្ញាតអោយរៀបអាពាហ៍ពិពាហ៍ និង ធ្វើបុណ្យបូជា ឬ បញ្ចុះសព

-ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋាន ដែលខ្លួនបានអនុវត្ត

-ចុះហត្ថលេខា និង បោះត្រា លើសំបុត្រអត្រានុកូលដ្ឋាន

-កែតម្រូវ ឬ បដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬ តាមបទប្បញ្ញត្តិ នៃច្បាប់

-ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទអោយបានគង់វង្សល្អ ងាយស្រួលក្នុងការតាមដាន និងការគ្រប់គ្រង

-បញ្ជូនសៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលផុតទៅ យកទៅតម្កល់ទុកនៅសាលាស្រុក ឬ ខណ្ឌ ផ្ទាល់ ០១ ច្បាប់ និងនៅតុលាការខេត្ត ឬ ក្រុងសាមី ០១ ច្បាប់

-ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ ឬ សង្កាត់ អោយបានយល់ដឹងអំពីភារកិច្ចរបស់ខ្លួន ចំពោះអត្រានុកូលដ្ឋាន និង បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ដែលមកទំនាក់ទំនងអំពីអត្រានុកូលដ្ឋាន

-ធ្វើរបាយការណ៍អំពី កំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ ឬ សង្កាត់ជារៀងរាល់ខែ និង រាល់ដំណាច់ឆ្នាំនីមួយៗ ផ្ញើទៅសាលាស្រុក ឬ សាលាខណ្ឌ សាមី

-សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន អំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់ ។

មាត្រា ១០ ._

រាល់ការអនុវត្តន៍ការងារអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន ដូចការងារ អត្រានុកូលដ្ឋាន ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ដោយប្រកាសរួម ។

មាត្រា ១១ ._

ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានមន្ត្រី ០១ រូប នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល អោយទទួលមុខងារជាមន្ត្រីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដោយជូនពត៌មានទៅ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

បែបបទនៃការបំពេញមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននេះ ត្រូវពិគ្រោះរវាងក្រសួងមហាផ្ទៃ និង ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

## ជំពូកទី ៣

## អំពីសៀវភៅអត្រានុកូលដ្ឋាន

មាត្រា ១២ ._

ក្នុងឃុំ ឬ សង្កាត់នីមួយៗ ត្រូវមានសៀវភៅអត្រានុកូលដ្ឋាន សម្រាប់កត់ត្រាអំពីកំណើតអាពាហ៍ពិពាហ៍មរណភាព បញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និង បញ្ជាក់មរណភាព ។

សៀវភៅនេះត្រូវធ្វើជា ០២ ច្បាប់ដូចគ្នា តាមប្រភេទនីមួយៗ តាមគំរូដែលកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សៀវភៅនេះត្រូវចុះចំនួនសន្លឹក និង ចុះលេខរៀងសន្លឹក ពីសន្លឹកទី១ ដល់សន្លឹកចុងក្រោយ ។ សន្លឹកទី១ និងសន្លឹកចុងក្រោយត្រូវសរសេរជាអក្សរ និង ត្រូវចុះហត្ថលេខាពេញដោយអភិបាលស្រុក ឬ អភិបាលខណ្ឌ ។ សន្លឹកទី២ និង សន្លឹកដទៃទៀតអាចចុះហត្ថលេខាសង្ខេប និងបោះត្រារបស់អភិបាល ស្រុក ឬ អភិបាលខណ្ឌគ្រប់សន្លឹក ។

**មាត្រា ១៣ .-**

សៀវភៅអត្រានុកូលដ្ឋានទាំងអស់ មិនត្រូវអោយមាន កោស ឆូត លុប សរសេរជ្រៀតថែមឡើយ ។ បើមានកោស ឆូត លុប ត្រូវទុកពាក្យអោយទាំងនោះនៅមើលបាន ហើយសរសេរទឹកខ្មៅពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងថា យល់ព្រមលុបប៉ុន្មានពាក្យ និង យល់ព្រមថែមប៉ុន្មានពាក្យ ទើបមន្ត្រីអត្រានុកូលដ្ឋាន អ្នករាយការណ៍ និង ឬសាក្សី និង ឬ សាមីខ្លួនចុះហត្ថលេខា ឬ ផ្តិតមេដៃស្តាំទាំងអស់ គ្នា ។

ចំពោះសន្លឹកណា ដែលសរសេរខុស ត្រូវរក្សាទុកជាឯកសារមិនអោយហែកចោលឡើយ ។

**មាត្រា ១៤ .-**

សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗ ត្រូវបើកអោយប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ មករា ហើយត្រូវបញ្ឈប់នៅថ្ងៃទី ៣១ ខែ ធ្នូ រៀងរាល់ឆ្នាំ ។

នៅខែមករាឆ្នាំបន្ទាប់ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបញ្ជូនសៀវភៅតាមប្រភេទនីមួយៗ ០១ ច្បាប់ ទៅសាលាស្រុក ឬ ខណ្ឌសាមី ដើម្បីត្រួតពិនិត្យ និង តម្កល់ទុកនៅទីនោះ និង បញ្ជូន ០១ ច្បាប់ទៀត ដែលដូចគ្នាទៅតម្កល់ទុកនៅតុលាការខេត្ត ឬ ក្រុងសាមី ដើម្បីមុខការតាមផ្លូវ ច្បាប់ ។

សៀវភៅអត្រានុកូលដ្ឋាន ដែលបានប្រើប្រាស់នៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវបញ្ជូនតាមរយៈក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នៅខែ មករា ឆ្នាំ បន្ទាប់ មកតម្កល់ទុក ០១ ច្បាប់ នៅក្រសួងមហាផ្ទៃ និង ០១ ច្បាប់ទៀតតម្កល់ទុកនៅក្រសួងយុត្តិធម៌ ។

**មាត្រា ១៥ .-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរៀបចំទុកដាក់ ថែរក្សាសៀវភៅអត្រានុកូលដ្ឋាន និង សំណុំឯកសារដែលពាក់ព័ន្ធការងារអត្រានុកូលដ្ឋានអោយបានល្អ និង រក្សាការសម្ងាត់របស់បុគ្គលម្នាក់ៗ ។

ចំពោះសាលាឃុំ ឬ សង្កាត់ណា ដែលមិនធានាសុវត្ថិភាព មន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ ឬ សង្កាត់នោះ ត្រូវផ្ញើសៀវភៅអត្រានុកូលដ្ឋានទៅរក្សាទុកនៅសាលាស្រុក ឬ ខណ្ឌសាមី ។ ពេលធ្វើអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាននោះត្រូវទៅធ្វើនៅសាលាស្រុក ឬ ខណ្ឌ ទៅតាមបែបបទដូចបានអនុវត្ត នៅសាលាឃុំ ឬ សង្កាត់ ។

មាត្រា ១៦ ._

ក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំសៀវភៅអត្រានុកូលដ្ឋានអោយបានឯកភាពទូទាំងប្រទេស និង បណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន អំពីរបៀបកត់ត្រាចូលក្នុងសៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ និង ធានាផ្គត់ផ្គង់សៀវភៅ និង សំបុត្រអត្រានុកូលដ្ឋានអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់មន្ត្រីអត្រានុកូលដ្ឋាន ។

## ជំពូកទី ៤
## អំពីសំបុត្រកំណើត

មាត្រា ១៧ ._

បើមានទារកកើត ឪពុក ឬ ម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយទារកនោះ មិនអោយហួស៣០ថ្ងៃ ដោយបញ្ជាក់អោយបានច្បាស់ថា ឪពុកនិងម្តាយនៃទារកនោះមានខាន់ស្លា ឬ គ្មានខាន់ស្លា ។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុក និង ម្តាយទារកនោះ ។

បើឪពុក ម្តាយមានធុរៈទៅមិនបាន ត្រូវតែងតាំងអ្នកជាសាច់ញាតិសន្តាន ឬ អ្នកនៅជិតខាងដែលបានឃើញ និងដឹងច្បាស់ពីទារកនោះកើតអោយទៅចុះសៀវភៅកំណើតអោយបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និងម្តាយទារកនោះជាប់ទៅជាមួយផង ។

មាត្រា ១៨ ._

នាមត្រកូលរបស់ទារក អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬ អាចយកឈ្មោះជីតាខាងឪពុក ឬ អាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន ។

ឪពុក ម្តាយ ឬ អាណាព្យាបាល ជាអ្នកដាក់នាមខ្លួនអោយទារក ។

មាត្រា ១៩ ._

បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់អោយមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬ សង្កាត់នៃទីកន្លែងដែលរើសទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុ និង ចុះក្នុងសៀវភៅកំណើត ដោយរកឈ្មោះដាក់អោយ ហើយបើក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំ កំណើតទារកដែលរើសបាននោះ ដោយស្មាន និង ឈ្មោះឪពុកម្តាយដាក់ថាមិនស្គាល់ ។

បើមានជនណា សុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ។

ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើសបាននោះ ទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ទារកនោះ និង កំណត់ហេតុស្តីអំពីការប្រគល់ទារកនោះ ជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ។

មាត្រា ២០ .-

ចំពោះទារក ឬ កុមារ ដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា ក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ហើយដែលពុំទាន់មានសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតអ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះត្រូវធ្វើសេចក្តីរាយការណ៍ និង នាំទារក ឬ កុមារនោះទៅជូនមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមជ្ឈមណ្ឌលនោះតាំងនៅ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានផ្តល់សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតអោយ ។

មាត្រា ២១ .-

ការសុំទារក ឬ កុមារ ពីមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និងការសុំទារក ឬ កូនពីឪពុក ម្តាយធ្វើជាកូនចិញ្ចឹម ត្រូវអនុវត្តទៅតាមនីតិវិធី ដូចមានចែងក្នុងច្បាប់ និង លិខិតបទដ្ឋានជាធរមាន ។

កិច្ចសន្យាសុំកូនខាងលើនេះ ត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន ។

មាត្រា ២២ .-

បើមានទណ្ឌិតណាម្នាក់សម្រាលកូន ទីកន្លែងកំណើតនៃទារកនោះ ត្រូវយកតាមលំនៅដ្ឋានរបស់ម្តាយ ឬ ឪពុក ។

មាត្រា ២៣ .-

ទារកកើត ឪពុកម្តាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅកំណើតដែរ ។ នៅពេលធ្វើសំបុត្រកំណើត បើឪពុកម្តាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះបានឆ្លើយទទួលស្គាល់ដោយជាក់លាក់ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក ម្តាយនោះថាជាឪពុក ម្តាយរបស់កូននោះ ។

ករណីមានតែឪពុក ឬ មានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ ។

ក្រោយពេលឪពុក ឬ ម្តាយបានប្តឹងចុះក្នុងសៀវភៅកំណើត ឪពុកឬ ម្តាយណា ដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុក ឬ ម្តាយនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

កូនឥតខាន់ស្លាដែលឪពុក ម្តាយបានទទួលស្គាល់ នឹង ទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឪពុក ម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នា នឹង ពេលចុះអាពាហ៍ពិពាហ៍ ឬ ក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

មាត្រា ២៤ ._

ក្រោយពេលចុះសៀវភៅកំណើតរួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់អោយអ្នករាយការណ៍នូវសំបុត្រកំណើតច្បាប់ដើម ០១ សន្លឹកទុកជាសម្គាល់ និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

មាត្រា ២៥ ._

បើមានទារកកើតហើយ ទុកអោយហួសរយៈពេល ៣០ ថ្ងៃ ពុំបានទៅរាយការណ៍ ចុះសៀវភៅកំណើត ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី ។

ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលទារកនោះ ត្រូវយកសាលក្រមតុលាការនោះមកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅ ដើម្បីចុះសៀវភៅកំណើត ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ។

មាត្រា ២៦ ._

ទារកកើតពីម្តាយ ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្របច្បាប់ឯបរទេស ឬ ពីឪពុកជាពលរដ្ឋខ្មែរ ម្តាយជាជនបរទេស ពីឪពុកជាជនបរទេស ម្តាយជាពលរដ្ឋខ្មែរ ឪពុក ម្តាយ នៃទារកនោះ អាចសុំចុះ សៀវភៅកំណើតនៅឯប្រទេសនោះ តាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ ។ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវទៅចុះសៀវភៅកំណើតនៅឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅតាមសំបុត្រកំណើតដែលប្រទេសនោះចេញអោយ ដោយយកសញ្ជាតិតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅ នូវសំបុត្រកំណើតថ្មីអោយយកទៅប្រើប្រាស់ ។

បើឪពុក ម្តាយនៃទារកនោះ បានទៅរាយការណ៍ចុះសៀវភៅកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ អាចយកសំបុត្រកំណើតដែលប្រគល់អោយនោះមកពីប្រើប្រាស់ជាផ្លូវការបាន ។

មាត្រា ២៧ ._

ជនអន្តោប្រវេសន៍ និង ជនបរទេស ដែលបានរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បានកើតទារកនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ឪពុក ម្តាយទារកនោះ អាចទៅចុះ

សៀវភៅកំណើតនៅសាលាឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់ ឬ អាចចុះសៀវភៅកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។ បើចុះសៀវភៅកំណើតនៅសាលាឃុំ សាលាសង្កាត់ នាមត្រកូល និង នាមផ្ទាល់ខ្លួន និងនាមនៃឪពុក ម្តាយរបស់ទារកនោះ ត្រូវសរសេរជាអក្សរឡាតាំងរួមជាមួយអក្សរខ្មែរផង ។

ចំពោះសញ្ជាតិនៃកូននោះ ត្រូវអនុវត្តតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៥

## អំពីសំបុត្រអាពាហ៍ពិពាហ៍

**មាត្រា ២៨ .-**

បុរស នារី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យអោយបានហ្មត់ចត់នូវពាក្យសុំនោះ ដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ ស្តីពីការអាពាហ៍ពិពាហ៍ និង គ្រួសារ ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៩ .-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងធ្វើនោះ ផ្សាយជាសាធារណៈ នៅលំនៅដ្ឋាន និង នៅសាលាឃុំ ឬ សាលាសង្កាត់ នៃសាមីខ្លួននារី ០១ ច្បាប់ ។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និង បិទនៅសាលាឃុំ ឬ សង្កាត់នៃសាមីខ្លួនបុរស ០១ ច្បាប់ ។

ប័ណ្ណប្រកាសត្រូវចុះ ៖

១-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅនៃអនាគត ប្តី ប្រពន្ធ ។

២-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅរបស់ ឪពុក ម្តាយ នៃអនាគត ប្តី ប្រពន្ធ បើឪពុក ឬ ម្តាយស្លាប់ ត្រូវដាក់ថាស្លាប់ ។

៣-រយៈពេលប្តឹងជំទាស់

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីជនដែលមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ ។ ផុតរយៈពេល១០ថ្ងៃ អាពាហ៍

[illegible] អាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្តឹងជំទាស់ត្រូវបានសម្រេចដោះស្រាយចប់ ។

មាត្រា ៣០ ._

អាពាហ៍ពិពាហ៍ នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តទទួលធ្វើជា ប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី ។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និង សាក្សីគ្រប់អាយុការចំនួន ០២នាក់ផង ។

មាត្រា ៣១ ._

ពេលសាមីខ្លួនជាអនាគត ប្តី និង ប្រពន្ធ មករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់អោយសាមីខ្លួន ប្តីប្រពន្ធ នូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

មាត្រា ៣២ ._

ការសុំរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ និង ជនបរទេស ដែលរស់នៅស្រប ច្បាប់ឯបរទេស ត្រូវប្រព្រឹត្តិទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេស ដែលគូរភាគីមានទីលំនៅ ។

ក្នុងករណីពេលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ និង អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានប្រព្រឹត្តិទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយនឹងបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេស នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ឬ បើប្តី ប្រពន្ធមកតាំងលំនៅនៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកចុះ សៀវភៅអាពាហ៍ពិពាហ៍ នៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនបានរស់នៅ ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល ឬ មន្ត្រីអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ថតចម្លងផ្លូវការនោះទុកហើយចម្លងចេញពីសៀវភៅនូវសំបុត្រអាពាហ៍ពិពាហ៍ថ្មី អោយទៅជននោះយកទៅប្រើប្រាស់ ។

មាត្រា ៣៣ ._

អាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និង ជនបរទេស ឬ ជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣៤ ._

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬ ជនអន្តោប្រវេសន៍នោះបាន ដោយអនុវត្តតាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ ដែលមានចែងនៅក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋាន ដោយប្រាប់ពីទីកន្លែង និងពេលវេលាដែលខ្លួនរៀបអាពាហ៍ពិពាហ៍នេះអោយបានច្បាស់ ។

ពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ឬសុំចុះសៀវភៅអាពាហ៍ពិពាហ៍ នៅមន្ត្រីអត្រានុកូលដ្ឋានតាមច្បាប់ព្រះរាជាណាចក្រកម្ពុជាក៏បាន ។

ការចុះឈ្មោះនៃជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

## ជំពូកទី៦

## អំពីសំបុត្រមរណភាព

មាត្រា ៣៥ ._

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកមានភារកិច្ចនៅក្រសួងស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬ សង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់ ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតអោយធ្វើបុណ្យបូជា ឬ បញ្ចុះសព បើស្លាប់ដោយជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬ ដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទង ដល់អំពើឃាតកម្ម នៃបទល្មើសឧក្រិដ្ឋណាមួយ ។

ការចុះសៀវភៅមរណភាព និង ចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព ។

បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាត អាចបណ្តាលអោយគ្រោះថ្នាក់ដល់សង្គម ត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬ ផ្នែកអនាម័យភ្លាម ។ បើពេទ្យ ឬ ផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតឯនុញ្ញាអោយធ្វើបុណ្យបូជា ឬ បញ្ចុះសពតាមការសម្រេចនោះ ។

មាត្រា ៣៦ ._

បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យដល់អំពើឃាតកម្ម នៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬ ជនទាំងឡាយណា ដែលមានការពាក់ព័ន្ធត្រូវរាយការណ៍ភ្លាម ដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ ដើម្បីអោយសមត្ថកិច្ចជំនាញនានាពិនិត្យស្រាវជ្រាវ និងដោះស្រាយរួសរាន់ ។ ក្រោយពីមានការសម្រេចយ៉ាងណាពីភ្នាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតអោយធ្វើបុណ្យបូជា ឬ បញ្ចុះសពបាន ។

មាត្រា ៣៧ ._

បើមានពលរដ្ឋខ្មែររស់នៅក្នុងឃុំ ឬ សង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬ សង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់ ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់របស់អ្នកស្លាប់រស់នៅ ដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់អោយទៅយកសពធ្វើបុណ្យ និង ចុះសៀវភៅមរណភាពនៅឃុំ ឬ សង្កាត់នៃអ្នកស្លាប់នោះស្នាក់នៅជាប់លាប់ ។

បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬ គ្មានអ្នកសារប់ស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់ដែលមានអ្នកស្លាប់ត្រូវចាត់ចែងបូជា ឬ បញ្ចុះសពនោះ និង ចុះសៀវភៅមរណភាពក្នុងឃុំ ឬ សង្កាត់នោះ ។

មាត្រា ៣៨ ._

បើមានអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ អ្នកទទួលខុសត្រូវនៃពន្ធនាគារនោះ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងទៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅអចិន្ត្រៃយ៍របស់អ្នកទោសនោះ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានចុះក្នុងសៀវភៅមរណភាព ។

មាត្រា ៣៩ ._

ពេលមានអ្នករាយការណ៍អំពីមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅមរណភាពរួចប្រគល់អោយអ្នកសុំនូវសំបុត្រមរណភាពច្បាប់ដើម ០១ សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

មាត្រា ៤០ ._

បើមានអ្នកស្លាប់ទុកអោយហួសរយៈពេល ១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត-ក្រុងសាមី រួចយកសាលក្រម

តុលាការនោះមកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅមរណភាព ។

មាត្រា ៤១ ._

បើមានពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេសបានស្លាប់ ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកដែលបានឃើញអ្នកស្លាប់នោះផ្ទាល់ អាចទៅចុះសៀវភៅមរណភាពនៅប្រទេសនោះ តាមច្បាប់របស់ប្រទេសនោះ ។ ពេលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាព ដែលធ្វើនៅបរទេសនោះទៅចុះសៀវភៅនៅ ឃុំ ឬ សង្កាត់ ដែលសាមីខ្លួនអ្នកស្លាប់ ធ្លាប់ស្នាក់នៅជាប់ លាប់មុនចេញទៅបរទេស ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវដកយកសំបុត្រមរណភាពថតចម្លងជាផ្លូវការទុកជាឯកសារ ហើយចម្លងចេញពីសៀវភៅមរណភាពនូវសំបុត្រមរណភាពថ្មី ប្រគល់អោយសាមីខ្លួនអ្នកសុំយកទៅប្រើប្រាស់ ។

បើបានទៅរាយការណ៍ចុះសៀវភៅមរណភាពនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ រួចហើយពេលត្រឡប់មកប្រទេសកម្ពុជាវិញ អាចយកសំបុត្រមរណភាពនោះមកប្រើប្រាស់ជាផ្លូវការបាន ។

មាត្រា ៤២ ._

ជនអន្តោប្រវេសន៍ និង ជនបរទេសរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានស្លាប់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬ អ្នកទទួលខុសត្រូវ អាចទៅចុះសៀវភៅមរណភាពនៅសាលាឃុំ ឬ សង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់មុនពេលខ្លួនស្លាប់ ឬ អាចទៅចុះសៀវភៅមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ។

បើចុះសៀវភៅមរណភាពនៅឃុំ ឬ សង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង ។

## ជំពូកទី៧
## អំពីសំបុត្របញ្ជាក់កំណើត

មាត្រា ៤៣ ._

ពលរដ្ឋខ្មែរដែលបានកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះសៀវភៅបញ្ជាក់កំណើតបាន តាមគំរូណែនាំថ្មី

នៅសាលាឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២ រូប ជានីតិជននិងជាមនុស្សគួរអោយជឿទុកចិត្តបាន ដែលបានស្គាល់ច្បាស់ពីប្រវត្តិអ្នកត្រូវសុំធ្វើសំបុត្របញ្ជាក់កំណើត និង ធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយ ពីពេលដែលសាមីខ្លួនកើត នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬ ទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬ សោធននិវត្តន៍ ឬ សេចក្តីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះនៅក្នុងសៀវភៅបញ្ជាក់កំណើតមិនត្រូវអោយខុសពីថ្ងៃខែកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬ សោធននិវត្តន៍ជាផ្លូវការឡើយ ។

មាត្រា ៥៤ ._

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់កំណើត មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់កំណើត រួចត្រូវប្រគល់អោយសាមីខ្លួន ឬ ក្រុមគ្រួសារនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើម ០១ សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ។

## ជំពូកទី៨
## អំពីសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

មាត្រា ៥៥ ._

ពលរដ្ឋខ្មែរដែលបានធ្លាប់ជាប្តី ឬ ប្រពន្ធពិតប្រាកដ នៅមុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយគ្មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនប្តី ប្រពន្ធអាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់ បច្ចុប្បន្នដោយមានសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរអោយជឿទុកចិត្តបាន ដែលបានដឹងច្បាស់ពីសាមីខ្លួនប្តី ប្រពន្ធនោះនិងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយគ្នា នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

មាត្រា ៥៦ ._

ពេលមានសាមីខ្លួនប្តី និង ប្រពន្ធមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់អោយសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្របញ្ជាក់ អាពាហ៍ពិពាហ៍ច្បាប់ដើម ០១ សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ។

## ជំពូកទី៩
## អំពីសំបុត្របញ្ជាក់មរណភាព

**មាត្រា ៤៧ ._**

ពលរដ្ឋខ្មែរ ដែលស្លាប់មុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមានហើយ គ្មានសំបុត្រមរណភាព សាច់ញាតិសន្តានដែលនៅរស់ អាចមកសុំចុះសៀវភៅបញ្ជាក់មរណភាព គំរូណែនាំថ្មីនៅសាលាឃុំ ឬ សង្កាត់ ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្នបាន ដោយនាំសាក្សីចំនួន ០២ រូប ជានីតិជន និង ជាមនុស្សគួរអោយជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់អំពីការស្លាប់ និង ធ្លាប់ រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយអ្នកស្លាប់មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៤៨ ._**

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់មរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់មរណភាព រួចត្រូវប្រគល់អោយអ្នកមកសុំនូវសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ០១សន្លឹក និង ចេញ សេចក្តីចម្លងតាមការស្នើសុំ ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ។

## ជំពូកទី១០
## អំពីសេចក្តីចម្លង ឬ សម្រង់អត្រានុកូលដ្ឋាន

**មាត្រា ៤៩ ._**

សេចក្តីចម្លង ឬ សម្រង់អត្រានុកូលដ្ឋានមាន សេចក្តីចម្លង ឬ សម្រង់សំបុត្រកំណើត សេចក្តីចម្លង ឬ សម្រង់សំបុត្រអាពាហ៍ពិពាហ៍ សេចក្តីចម្លង ឬ សម្រង់សំបុត្រមរណភាព សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់កំណើត សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ និង សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់មរណភាព ។

រាល់ខ្លឹមសារនៃសេចក្តីចម្លង ត្រូវអនុវត្តដូចគ្នានឹងខ្លឹមសារក្នុងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ។

សម្រង់អត្រានុកូលដ្ឋាន ត្រូវធ្វើតាមសំណើរបស់អ្នកសុំដោយដកស្រង់នូវខ្លឹមសារសំខាន់ៗ ចេញពីសៀវភៅអត្រានុកូលដ្ឋាន ។

**មាត្រា ៥០ ._**

បើមានអ្នកមកសុំចម្លង ឬ សុំស្រង់សំបុត្រអត្រានុកូលដ្ឋានពីមន្ត្រីអត្រានុកូលដ្ឋាន អ្នកសុំត្រូវមានសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមយកមកជាមួយ តែការចម្លង ឬ សម្រង់ត្រូវស្រង់ចេញពីសៀវភៅដែលតម្កល់ទុក ។ ក្នុងករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មន្ត្រីអត្រា

នុកូលដ្ឋានត្រូវចម្លងតាមសៀវភៅអត្រានុកូលដ្ឋាន ដែលបានចុះពីមុនមក និង កំពុងថែរក្សាក្នុងឆ្នាំដែលមិនទាន់ដាច់ នៅសាលាឃុំ ឬ សាលាសង្កាត់ ។ ក្នុងករណីសៀវភៅអត្រានុកូលដ្ឋានបានវិនាសដោយមានកំណត់ហេតុត្រឹមត្រូវ ហើយមានសេចក្តីណែនាំពីអន្តរក្រសួង ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ទើបធ្វើការចម្លង ឬ សម្រង់ចេញពីសន្លឹកអត្រានុកូលដ្ឋាន ដែលសាមីខ្លួនម្នាក់សុំមាន ហើយយកទៅប្រើការបាន ។

មាត្រា ៥១._

ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬ សុំស្រង់ នៅសាលាឃុំ ឬ សាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាល ស្រុក ឬ ខណ្ឌ និង បោះត្រាផង ។

មាត្រា ៥២ ._

ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬ សុំស្រង់ នៅសាលាស្រុក ឬ ខណ្ឌ ឬ នៅតុលាការខេត្ត ក្រុងសាមី ។

ការសុំចម្លង ឬ សម្រង់នៅសាលាស្រុក ឬ សាលាខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និង ត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬ ខណ្ឌ និង បោះត្រាផង ។

ការសុំចម្លង ឬ សម្រង់នៅតុលាការខេត្ត ក្រុងត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និង ត្រូវបញ្ជាក់ហត្ថលេខានោះដោយប្រធានតុលាការ ឬ ចៅក្រមជំនួស និង បោះត្រាផង ។

មាត្រា ៥៣ ._

ពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ការសុំចម្លង ឬ សម្រង់អត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬ សុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬ កុងស៊ុល និង បោះត្រាផង ។

ការសុំចម្លង ឬ សម្រង់អត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវសុំចម្លង ឬ សុំស្រង់នៅក្រសួងមហាផ្ទៃ ឬនៅក្រសួងយុត្តិធម៌ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់ទុកនៅទីនោះ ។

## ជំពូកទី១១
## អំពីការទទួលខុសត្រូវចំពោះមុខច្បាប់
## ស្ដីពីការងារអត្រានុកូលដ្ឋាន

**មាត្រា ៥៤ .-**

សាមីខ្លួន និង ឬអ្នករាយការណ៍ និង ឬ សាក្សី ត្រូវសំដែងនូវការស្មោះត្រង់ ចំពោះការបញ្ជាក់អះអាងរបស់ខ្លួនអំពីហេតុការណ៍ដែលកើតមានឡើង ហើយដែលខ្លួនបានដឹងឮ ឬ ឃើញផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្ដីពីអត្រានុកូលដ្ឋានតាមប្រភេទ ។

**មាត្រា ៥៥ .-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ។ បើមានមន្ត្រីអត្រានុកូលដ្ឋានណាម្នាក់ការឃុបឃិត ឬ ក្លែងបន្លំដោយចេតនា ក្នុងការធ្វើសំបុត្រអត្រានុកូលដ្ឋាន ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

សំបុត្រអត្រានុកូលដ្ឋានក្លែងបន្លំដែលបានចេញរួចហើយ ត្រូវប្រមូលយកទៅវិញ នឹងប្ដឹងទៅតុលាការដើម្បីបដិសេធ និង សុំផ្ដន្ទាទោសតាមច្បាប់ ។

## ជំពូកទី១២
## អំពីថវិកា អត្រានុកូលដ្ឋាន

**មាត្រា ៥៦ .-**

ការបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និង ការបណ្ដុះបណ្ដាល អំពីការងារអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេសត្រូវស្ថិតក្នុងបន្ទុកថវិការដ្ឋ ។

**មាត្រា ៥៧ .-**

ក្រសួងមហាផ្ទៃត្រូវលើកគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ការសុំបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្ដុះបណ្ដាលការងារអត្រានុកូលដ្ឋាន ។

**មាត្រា ៥៨ .-**

ការសុំចុះសំបុត្រអត្រានុកូលដ្ឋាន កំណើត និង មរណភាព អ្នកមកសុំមិនតម្រូវអោយបង់ថ្លៃអ្វីឡើយ ។

ការសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និង ការចុះសំបុត្រអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ ការសុំបញ្ជាក់កំណើតបញ្ជាក់អាពាហ៍ពិពាហ៍ និង បញ្ជាក់មរណភាព អ្នកសុំត្រូវបង់ថ្លៃក្រដាសតាមការកំណត់ ។

រាល់ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋានអ្នកមកសុំត្រូវបង់ថ្លៃក្រដាស និងថ្លៃបិទតែមប្រិ៍ ដើម្បីជាប្រយោជន៍សម្រាប់ ឃុំ ឬ សង្កាត់ និង ចំណូលថវិការដ្ឋ ។

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និង ថ្លៃតែមប្រិត្រូវកំណត់ដោយអនុក្រឹត្យ តាមសេចក្ដីស្នើសុំរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី១៣

## អន្តរប្បញ្ញត្តិ

**មាត្រា ៥៩ ._**

ការសុំបញ្ជាក់អត្រានុកូលដ្ឋានមានចុះ សៀវភៅបញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល៣ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។ ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋាន កំណើត និង មរណភាព ត្រូវទៅសុំសាលក្រមពីតុលាការខេត្តក្រុមសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន ។ ឯការបញ្ជាក់ អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍អនុញ្ញាតអោយប្ដឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

**មាត្រា ៦០ ._**

ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនរបស់ជនណាម្នាក់ផ្សេងទៀត ។

**មាត្រា ៦១ ._**

រាល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ចាស់ ដែលមានស្រាប់ពីសង្គមមុនៗ និង អត្រានុកូលដ្ឋានក្រោយឆ្នាំ ១៩៧៩ ហើយរក្សាទុករហូតដល់បច្ចុប្បន្ន សាមីខ្លួនត្រូវយកមកបង្ហាញមន្ត្រីអត្រានុកូលដ្ឋានបច្ចុប្បន្ន ដើម្បីចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន តាមគំរូថ្មី សម្រាប់ប្រើប្រាស់ទៅថ្ងៃក្រោយ ។

**មាត្រា ៦២ ._**

ក្នុងករណីដែលពិនិត្យសំបុត្រអត្រានុកូលដ្ឋានចាស់ពី មុនណាមួយដែលមានលក្ខណៈពុំត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រមូលសំបុត្រអត្រានុកូលដ្ឋានមកវិញ រួចណែនាំអោយសាមីជនបំពេញបែបបទនោះមកវិញ រួចណែនាំអោយសាមីជនបំពេញបែបបទសុំអត្រានុកូលដ្ឋានថ្មី ។

**មាត្រា ៦៣ ._**

ហាមមនុស្សម្នាក់ចុះសៀវភៅអត្រានុកូលដ្ឋានក្នុងប្រភេទនីមួយៗ លើសពី ០១ដង និង នៅច្រើនកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី១៤

## អំពីទោសប្បញ្ញត្តិ

**មាត្រា ៦៤ ._**

ជនណារាយការណ៍មិនពិត អំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬ យកអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬ រាយការណ៍សុំចុះអត្រានុកូលដ្ឋាន លើស

ពី០១ផង នៅទីកន្លែងដដែល ឬ ទីកន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ប្រើប្រាស់អត្រានុកូលដ្ឋានក្លែង ត្រូវពិន័យ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

មាត្រា ៦៥ .-

មន្ត្រីអត្រានុកូលដ្ឋានណា សមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានអោយប្រជាពលរដ្ឋដែលមកសុំ ឬ បានទារប្រាក់លើសច្បាប់កំណត់ពីប្រជាពលរដ្ឋសម្រាប់ការងារអត្រានុកូលដ្ឋាន ត្រូវពិន័យជាប្រាក់ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

## ជំពូកទី១៥

## អវសានប្បញ្ញត្តិ

មាត្រា ៦៦ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦៧ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា ហត្ថលេខា

ស ខេង យូ ហុកគ្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

អ៊ុក វិធុន

***

## អនុក្រឹត្យលេខ ៤២១ អនក្រ.តត

## ស្តីពីការជូនមេដាយ សហមេត្រី

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ។
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសំរួលមាត្រា ៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ។
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សំរេច

**មាត្រាតែមួយ .-**

កែសំរួលមាត្រា ២៥ មាត្រា ៤០ មាត្រា ៤៣ មាត្រា ៤៥ មាត្រា ៤៧ មាត្រា ៥១ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន

និងមាត្រា ៥៩ ថ្មី នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី ការកែសំរួលមាត្រា៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ដូចខាងក្រោម ៖

**មាត្រា២៥ថ្មី ៖**

បើមានទារកកើតហើយ ទុកអោយហួសរយៈពេល ៣០ ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ត្រូវប្តឹងសុំសំបុត្រកំណើតនេះពី មេឃុំ ចៅសង្កាត់ សាមី ដោយបង់ប្រាក់ថ្លៃសំបុត្រកំណើតដល់អាជ្ញាធរ ឃុំ សង្កាត់សាមី ចំនួន ១.០០០ (មួយពាន់) រៀលសំរាប់ប្រជាពលរដ្ឋមានទីលំនៅនៅក្នុងខេត្ត រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំបន្ថែមអំពីបែបបទ និង នីតិវិធីនៃការសុំ និង ការចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ក្នុងករណីខាងលើនេះ ។

**មាត្រា៤០ថ្មី ៖**

បើមានអ្នកស្លាប់ទុកអោយហួសរយៈពេល ១៥ ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពី មេឃុំ ចៅសង្កាត់សាមី ដោយបង់ថ្លៃសំបុត្រមរណភាពនេះដល់អាជ្ញាធរឃុំ សង្កាត់សាមីចំនួន១.០០០ (មួយពាន់) រៀល សំរាប់ប្រជាពលរដ្ឋមានទីលំនៅ នៅក្នុងខេត្ត រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំបន្ថែម អំពីបែបបទ នីតិវិធី នៃការសុំ និង ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្នុងករណីខាងលើនេះ ។

**មាត្រា៤៣ថ្មី ៖**

ពលរដ្ឋខ្មែរដែលកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតបានតាមគំរូណែនាំថ្មី នៅ សាលាឃុំ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សី ចំនួន ០២ រូប ជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដ នាំមកបញ្ជាក់នៅចំពោះមុខ មន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬ ទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬ សោធននិវត្តន៍ ឬ សេចក្តីបញ្ជាក់ពីក្រសួងស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត មិនត្រូវអោយខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬ សោធននិវត្តន៍ជាផ្លូវការឡើយ ។

**មាត្រា៤៥ថ្មី ..**

ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ នៅមុនពេលដែលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយមិនទាន់បានចុះសៀវភៅអាពាហ៍-ពិពាហ៍ សាមីខ្លួនទាំងពីររូបអាចសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មី នៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២ រូប ជានីតិជន និងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

**មាត្រា៤៧ថ្មី ..**

ពលរដ្ឋខ្មែរដែលស្លាប់មុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តាន ដែលនៅរស់អាចមកសុំចុះ សៀវភៅបញ្ជាក់មរណភាពបានតាមគំរូណែនាំថ្មី នៅសាលា ឃុំ ឬ សង្កាត់ ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្ន ដោយនាំសាក្សី ចំនួន ០២ រូប ជានីតិជន ហើយមានទីលំនៅពិតប្រាកដ មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា៥១ថ្មី ..**

ការសុំចម្លង ឬ សំរង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ ឬ សាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំឬសង្កាត់ ហើយត្រូវបោះត្រាផង ។

**មាត្រា៥៩ថ្មីស្ទួន ..**

**ក.** ការសុំបញ្ជាក់អត្រានុកូលដ្ឋានមាន ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ។

ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និង មរណភាព ត្រូវទៅសុំសំបុត្រអត្រានុកូលដ្ឋាន តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា២៥ថ្មី និង មាត្រា៤០ថ្មី នៃអនុក្រឹត្យនេះ ។ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អនុញ្ញាតអោយប្តឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

សំរាប់ឆ្នាំ ២០០២ សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវបានអនុញ្ញាតអោយបើកប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ សីហា ហើយត្រូវបញ្ឈប់បញ្ជីត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ។

ចាប់ពីឆ្នាំ ២០០៣ តទៅ ត្រូវអនុវត្តបទបញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ១៤ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ។

**ខ.**ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ ប្រជាពលរដ្ឋ ដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋានរួមមាន បញ្ជាក់កំណើត និង បញ្ជាក់មរណភាព នឹងត្រូវបានផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានខាងលើនេះនូវច្បាប់ដើម ០១សន្លឹកដោយឥតគិតថ្លៃ។

ចំពោះទារកដែលបានកើតក្នុងចន្លោះពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០៥ ហើយដែលមិនទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅពេលដែលឪពុកឬម្តាយ ឬ អាណាព្យាបាល មកសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត អោយទាន់ពេលក្នុងថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ នោះនឹងត្រូវបាន ផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើម ០១ សន្លឹកដោយឥតគិតថ្លៃ ។

**គ.**ដើម្បីបង្កលក្ខណៈសម្បត្តិងាយស្រួល ជូនប្រជាពលរដ្ឋ ក្នុងការចុះសៀវភៅអត្រានុកូលដ្ឋាន ឃុំ សង្កាត់ អាចចាត់អោយមានការចុះសៀវភៅអត្រានុកូលដ្ឋានចល័តក្នុងឃុំ សង្កាត់របស់ខ្លួនតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី**

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង** **យូ ហុកគ្រី**

**ចម្លងជូន :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ ។

# ច្បាប់

# ស្តីពី

# លក្ខន្តិកៈទូទៅនៃសហ

# គ្រាសសាធារណៈ

នស/រកម/០៦៩៦/០៣

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការតែង ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២២ ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៦នីតិកាលទី១ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅគ្រប់គ្រងផ្នែកសហគ្រាសសាធារណៈ និង កំណត់ល័ក្ខខ័ណ្ឌដែលត្រូវអនុវត្តចំពោះលក្ខន្តិកៈ គតិយុត្តការប្រព្រឹត្តទៅ និងការត្រួតពិនិត្យ ។

**មាត្រា ២.-**

សហគ្រាសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ ។ សហគ្រាសសាធារណៈ មានបេសកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព ។

**មាត្រា ៣.-**

សហគ្រាសសាធារណៈមានទម្រង់ជា :

- គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច
- ក្រុមហ៊ុនរដ្ឋ
- ក្រុមហ៊ុនចំរុះដែលក្នុងនោះរដ្ឋកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលលើសពី ៥១ភាគរយនៃដើមទុនក្រុមហ៊ុន ឬសិទ្ធិបោះឆ្នោត ។

**មាត្រា ៤.-**

សហគ្រាសសាធារណៈ គឺជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលសហគ្រាសសាធារណៈដែលតទៅនេះហៅកាត់ថា ក្រុមប្រឹក្សាភិបាល ជាអង្គការដឹកនាំខ្ពស់បំផុតនៅក្នុងសហគ្រាសសាធារណៈ ហើយបំពេញមុខងារប្រកបដោយស្វ័យភាពបរិបូណ៌ ចំនួនសមាជិកនៃក្រុមប្រឹក្សាភិបាលមិនត្រូវលើសពីប្រាំពីររូបឡើយ ។

វៀរលែងតែមានចែងក្នុងបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ ការគ្រប់គ្រងលើគ្រប់ផ្នែករបស់សហគ្រាសសាធារណៈត្រូវអនុលោមតាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ។

**មាត្រា ៥.-**

លើកលែងតែមានបដិបញ្ញត្តិដែលចែងដោយច្បាប់ សហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោមរបបនីតិរួមចំពោះពន្ធ និងអាករ ។

**មាត្រា ៦.-**

សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួង ឬអាជ្ញាធរសាធារណៈណាមួយ អាស្រ័យលើប្រភេទនៃសកម្មភាពរបស់សហគ្រាសនោះ ។

**មាត្រា ៧.–**

សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោម :

- ការត្រួតពិនិត្យរបស់រដ្ឋដូចមានចែងនៅក្នុងផ្នែកទី៣ ជំពូកទី២ នៃច្បាប់នេះ
- ការត្រួតពិនិត្យហិរញ្ញវត្ថុ និងអធិការកិច្ចរបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៨.–**

បុគ្គលិកដែលធ្វើការក្នុងសហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី ២

## បទប្បញ្ញត្តិរួមសម្រាប់សហគ្រាសសាធារណៈ

### ផ្នែកទី១

### ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាល

**មាត្រា ៩.–**

ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលត្រូវមានអាសនៈមួយកន្លែងសម្រាប់តំណាងនិយោជិតនៃសហគ្រាសសាធារណៈដែលត្រូវបានបោះឆ្នោតជ្រើសតាំងចេញពីនិយោជិត និងដោយនិយោជិតរបស់សហគ្រាស ។

**មាត្រា ១០.–**

ក្រុមប្រឹក្សាភិបាលផ្ទេរឱ្យប្រធានអគ្គនាយក ឬអគ្គនាយកនូវអំណាចចាំបាច់សម្រាប់ដំណើរការសហគ្រាសប្រចាំថ្ងៃ តែការផ្ទេរអំណាចនេះមិនមែនជាការផ្ទេរ ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលឡើយ ។

មុខងារនៃប្រធានអគ្គនាយក អគ្គនាយក ឬសមាជិកក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ មានវិសមិតភាពជាមួយមុខងារនៃសមាជិករដ្ឋសភា ឬសមាជិករាជរដ្ឋាភិបាល ។

**មាត្រា ១១.–**

ក្រុមប្រឹក្សាភិបាលកំនត់ទិសដៅ និងត្រួតពិនិត្យការគ្រប់គ្រងសហគ្រាសព្រមទាំងធានាសនិទានភាព និងប្រសិទ្ធភាពនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគ្រាស ។

ដើម្បីបំពេញមុខងានេះក្រុមប្រឹក្សាភិបាលមានភារកិច្ចជាអាទិ៍ដូចតទៅ :

- សម្រេចគម្រោងអភិវឌ្ឍន៍សហគ្រាស
- វាយតម្លៃក្នុងចន្លោះពេលមួយទៀងទាត់នូវលទ្ធផលសម្រេចបាន និង លើកវិធានការកែតម្រូវសម្រាប់អនុវត្ត
- សម្រេចគម្រោងថវិកាសម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគព្រមទាំងសេមាហិរញ្ញប្បទាន
- អនុម័តតុល្យការ និងគណនីគ្រប់គ្រង

- កំណត់រចនាសម្ព័ន្ធរបស់សហគ្រាស លក្ខន្តិកៈបុគ្គលិក និងរបបបៀវត្ស

- អនុម័តការដេញថ្លៃសាធារណៈ ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាភិបាល ត្រូវប្រជុំយ៉ាងតិចមួយដងក្នុងរៀងរាល់ ៣ខែ ដើម្បីពិភាក្សា និងសម្រេចនូវបញ្ហាដែលមានចុះក្នុងរបៀបវារៈ ។ របៀបវារៈនេះនឹងត្រូវបានជូនដំណឹងជាមុនយ៉ាងតិច ១០ថ្ងៃ ដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល។

ក្រុមប្រឹក្សាភិបាល ត្រូវចាត់ចែងធ្វើកំណត់ហេតុនានាឱ្យហើយក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីការប្រជុំ ។

**មាត្រា ១៣.-**

វៀរលែងតែមានចែងក្នុងបទប្បញ្ញត្តិនៃលក្ខន្តិកៈ ឬបទបញ្ជាដែលទាក់ទងទៅ និងការរៀបចំ និងការប្រព្រឹត្តទៅរបស់ សហគ្រាសសាធារណៈណាមួយ ក្រុមប្រឹក្សាភិបាលអាចប្រជុំដោយចាត់ទុកជាបានការ លុះត្រាតែមានសមាជិកភាគច្រើនចូលរួម ។ ក្រុមប្រឹក្សាភិបាលត្រូវសម្រេចតាមសម្លេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីដែលមានសម្លេងស្មើគ្នានោះ សម្លេងរបស់ប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព ។

**មាត្រា ១៤.-**

ក្រុមប្រឹក្សាភិបាលត្រូវសម្រេចយ៉ាងយូរបំផុតនៅថ្ងៃទី ៣០ ខែ កញ្ញា រៀងរាល់ឆ្នាំនូវគម្រោងថវិកាសម្រាប់ប្រព្រឹត្តទៅ និងការវិនិយោគ ព្រមទាំងសេមាហិរញ្ញប្បទាន ។

ឯកសារទាំងនេះ ត្រូវបានទទួលការយល់ព្រមពីក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល បន្ទាប់ពីការផ្តល់យោបល់ឯកភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលអតិបរមា ២ខែ គិតចាប់ពីថ្ងៃដែលឯកសារមកដល់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាភិបាល ត្រូវសម្រេចលើរបាយការណ៍ស្តីពីសកម្មភាពប្រចាំឆ្នាំ តុល្យការ និងគណនីគ្រប់គ្រងព្រមទាំងឯកសារឧបសម្ព័ន្ធនានាយ៉ាងយូរបំផុត ៣ខែ ក្រោយពេលបិទបញ្ជី ។

## ផ្នែកទី ២

## ភារកិច្ចរបស់សហគ្រាសសាធារណៈ

**មាត្រា ១៦.-**

សហគ្រាសសាធារណៈត្រូវផ្តល់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលនូវឯកសារដូចតទៅដែលពាក់ព័ន្ធទៅ និង :

- កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល

- ថវិកា សម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគ

- របាយការណ៍ស្ដីពីសកម្មភាព តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងឯកសារឧបសម្ព័ន្ធ

- របាយការណ៍ស្ដីពីការត្រួតពិនិត្យគណនីនានា ។

ឯកសារនីមួយៗ ដែលធ្វើហើយស្រេចតាមកាលកំណត់ ត្រូវបានបញ្ជូនទៅឱ្យកន្លែងទទួលក្នុងរយៈពេលមិនលើសពី ១៥ថ្ងៃ ។

ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលមានរយៈពេល ១ខែ សម្រាប់ជំទាស់ក្នុងករណីចាំបាច់ ។ ក្រុមប្រឹក្សាភិបាលត្រូវបានផ្ដល់ពត៌មានអំពីខ្លឹមសារនៃការជំទាស់ នៅពេលប្រជុំបន្ទាប់ដើម្បីចាត់វិធានការ ។

ក្នុងករណីដែលក្រុមប្រឹក្សាភិបាលមិនទទួលការជំទាស់របស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលនោះ ក្រុមប្រឹក្សាភិបាលត្រូវបង្ហាញហេតុផល ហើយត្រូវជូនដំណឹងទៅក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលវិញជាបន្ទាន់ ។

**មាត្រា ១៧.-**

គណនីទាំងឡាយរបស់សហគ្រាសសាធារណៈ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីអ្នកជំនាញគណនេយ្យ តាមលក្ខខណ្ឌ និងបែបបទដែលកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៨.-**

លទ្ធកម្មដោយសហគ្រាសសាធារណៈ ដាច់ខាតត្រូវធ្វើឡើងដោយអនុលោមតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៩.-**

វិធាននៃការដេញថ្លៃ ការអនុវត្ត និងការត្រួតពិនិត្យការដេញថ្លៃត្រូវបានកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣

## ការត្រួតពិនិត្យសហគ្រាសសាធារណៈ

**មាត្រា ២០.-**

ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ត្រូវធ្វើការត្រួតពិនិត្យសេដ្ឋកិច្ចដល់សហគ្រាសតាមរយៈតំណាងរបស់ខ្លួនដែលនៅក្នុងក្រុមប្រឹក្សាភិបាល ។ ការត្រួតពិនិត្យសេដ្ឋកិច្ចត្រូវបានធ្វើឡើងដើម្បីធានាឱ្យសេចក្ដីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលមានលក្ខណៈអនុលោមតាមទិសដៅរបស់រាជរដ្ឋាភិបាល ឬតាមការណែនាំរបស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ។

**មាត្រា ២១.-**

ត្រូវបានដាក់អោយនៅអមសហគ្រាសសាធារណៈនីមួយៗនូវមន្ត្រីត្រួតពិនិត្យរដ្ឋដែលទទួលបន្ទុកខាងការងារត្រួតពិនិត្យ ជាអាទិ៍លើ :

- ការបំពេញកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ដែលមានចែងក្នុងច្បាប់ និងបទបញ្ញាទាំងឡាយជាធរមាន
- ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ការតាមដានការប្រព្រឹត្តទៅ និងការវិវឌ្ឍន៍របស់សហគ្រាស
- ប្រក្រតីភាពនៃសកម្មភាពទាំងឡាយ ដែលអាចជះឥទ្ធិពលដល់ស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាស ។

**មាត្រា ២២.-**

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានតែងតាំង និងបញ្ឈប់ពីតំណែងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យ រដ្ឋត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីជាន់ខ្ពស់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបាន និងកំពុងបំពេញការងារសាធារណៈយ៉ាងតិច ៥ឆ្នាំ ។

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញភារកិច្ចតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុហើយត្រូវរាយការណ៍ជូនក្រសួងឱ្យបានទៀងទាត់អំពីការបំពេញភារកិច្ចរបស់ខ្លួន ។

**មាត្រា ២៣.-**

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល មានសិទ្ធិផ្តល់យោបល់ពិគ្រោះ និងត្រូវបានអញ្ជើញឱ្យចូលរួមក្នុងមហាសន្និបាតជាទៀងទាត់ ។

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវផ្តល់យោបល់លើបញ្ហាដែលមានចុះក្នុងរបៀបវារៈនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលក្នុងការអនុវត្តភារកិច្ចនេះ មន្ត្រីត្រួតពិនិត្យរដ្ឋអាចស្នើសុំពត៌មាន ឬស្វែងយល់នៅនឹងកន្លែងអំពីឯកសារ ឬបញ្ជីទាំងអស់ ដែលមាននៅក្នុងសហគ្រាស ។

**មាត្រា ២៤.-**

មន្ត្រីត្រួតពិនិត្យរដ្ឋអាចជំទាស់ និងការចាត់វិធានការទាំងឡាយដែលខ្លួនយល់ឃើញថា ផ្ទុយ និងច្បាប់ និងការប្រតិបត្តិដែលប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់សហគ្រាស ឬរបស់រដ្ឋ ឬពុំសមស្រប និងគោលដៅរបស់សហគ្រាស ។

**មាត្រា ២៥.-**

ការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាលនៅពេលប្រជុំ ឬយ៉ាងយូរបំផុតក្នុងរយៈពេល ៣ថ្ងៃ"គិតតែថ្ងៃធ្វើការ" ក្រោយពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវរាយការណ៍ជាបន្ទាន់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេសនៃសហគ្រាស អំពីការជំទាស់របស់ខ្លួនលើការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។ ៤ថ្ងៃធ្វើការ ក្រោយការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋ បើសិនជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលមិនបានបញ្ជាក់អំពីការជំទាស់នេះ ដោយចេញបញ្ជាឱ្យលុបចោល ឬកែប្រែសេចក្តីសម្រេចទេនោះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវចាត់ទុកជាបានការ ។

## ជំពូកទី ៣
## បទបញ្ញត្តិដោយឡែក សម្រាប់ប្រភេទផ្សេងៗនៃសហគ្រាសសាធារណៈ
## ផ្នែកទី ១
## គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច

**មាត្រា ២៦.-**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចគឺជានីតិបុគ្គលនៃនីតិសាធារណៈដែលមានស្វ័យភាពហិរញ្ញវត្ថុ ។ គ្រឹះស្ថាននេះផលិតផលិតផល ឬធ្វើសេវាសម្រាប់ទីផ្សារ ។

**មាត្រា ២៧.-**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចត្រូវបានបង្កើតឡើងដោយអនុក្រឹត្យតាមការស្នើរួមគ្នារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ។ អនុក្រឹត្យនេះកំណត់ជាអាទិ៍អំពី ភារកិច្ច ដើមទុន ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល សមាសភាពក្រុមប្រឹក្សាភិបាល ការរៀបចំរដ្ឋបាល និងហិរញ្ញវត្ថុ វិធាននៃការប្រព្រឹត្តទៅរបស់គ្រឹះស្ថាន ។

**មាត្រា ២៨.-**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ត្រូវបានដឹកនាំដោយប្រធានអគ្គនាយកមួយរូប ជាប្រធានក្រុមប្រឹក្សាភិបាលផង និងជាអគ្គនាយកផង ដែលបំពេញមុខងារក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល ។

តួនាទីរបស់ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកអាចញែកចេញដាច់ពីគ្នា ។ ក្នុងករណីនេះទីចាត់ការប្រតិបត្តិនៃគ្រឹះស្ថានត្រូវបានដឹកនាំដោយអគ្គនាយក ។

**មាត្រា ២៩.-**

ប្រធានអគ្គនាយក ឬអគ្គនាយកត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលនៃគ្រឹះស្ថានសាធារណៈនោះ ។ សមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលជាសមាជិកអាចជាតំណាង និងត្រូវបានជ្រើសរើសតាមលក្ខខណ្ឌដែលបានកំណត់ក្នុង មាត្រា ៤៣ នៃច្បាប់នេះ ។

## ផ្នែកទី ២
## ក្រុមហ៊ុនរដ្ឋ

**មាត្រា ៣០.-**

ក្រុមហ៊ុនរដ្ឋ គឺជាក្រុមហ៊ុនដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ ។

**មាត្រា ៣១.-**

ក្រុមហ៊ុនរដ្ឋ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមការស្នើរួមគ្នារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ។ អនុក្រឹត្យនេះកំណត់ជាអាទិ៍អំពីកម្មវត្ថុរបស់ក្រុមហ៊ុន ទម្រង់គតិយុត្តិ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែលត្រូវអនុវត្ត សមាសភាពរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ៣២.-**

ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេសទទួលខុសត្រូវបំពេញទម្រង់បែបបទនៃការបង្កើតក្រុមហ៊ុនដោយ :

- រៀបចំលក្ខន្តិកៈរបស់ក្រុមហ៊ុនដោយមានការព្រមព្រៀងជាមួយ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចាត់ចែងចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- បំពេញទម្រង់បែបបទទាំងអស់តាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ។

**មាត្រា ៣៣.-**

វៀរលែងតែមានចែងក្នុងបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ លក្ខន្តិកៈរបស់ក្រុមហ៊ុនរដ្ឋកំណត់ជាអាទិ៍អំពីចំនួនទឹកប្រាក់ និងប្រភេទនៃភាគទុន ការរៀបចំរដ្ឋបាល និងហិរញ្ញវត្ថុ វិធាននៃការប្រព្រឹត្តទៅរបស់ក្រុមហ៊ុន ។

**មាត្រា ៣៤.-**

តាមបដិបញ្ញត្តិលើគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម អំណាចនៃមហាសន្និបាតរបស់ក្រុមហ៊ុនរដ្ឋ ត្រូវបានប្រគល់ឱ្យក្រុមប្រឹក្សាភិបាល ។

**មាត្រា ៣៥.-**

ភាគទុនដំបូងព្រមទាំងការកែប្រែជាក្រោយនៃដើមទុនរបស់ក្រុមហ៊ុនរដ្ឋ ត្រូវបានធ្វើឱ្យសំរេចដោយអនុលោមតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ហិរញ្ញវត្ថុជាធរមាន ។

**មាត្រា ៣៦.-**

ប្រធានអគ្គនាយក ឬអគ្គនាយកក្រុមហ៊ុនរដ្ឋ ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងអាណាព្យាបាន ឬអាជ្ញាធរអាណាព្យាបាល ។ សមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលសមាជិកនោះជាតំណាង និងត្រូវបានជ្រើសរើសក្នុងលក្ខខណ្ឌដែលបានកំនត់ក្នុងមាត្រា ៤៣ នៃច្បាប់នេះ ។

## ផ្នែកទី ៣

## ក្រុមហ៊ុនចំរុះ

**មាត្រា ៣៧.-**

ភាគកម្មសាធារណៈ គឺជាចំណែកនៃដើមទុនរបស់ក្រុមហ៊ុនចំរុះ ដែលកាន់កាប់ដោយរដ្ឋ ដោយគ្រឹះស្ថានសាធារណៈ ឬដោយក្រុមហ៊ុនរដ្ឋ។

**មាត្រា ៣៨.-**

ក្រុមហ៊ុនចំរុះ គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមគោលការណ៍ និងតាមបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្មហើយដែលដើមទុនត្រូវបានកាន់កាប់រួមគ្នាដោយនីតិបុគ្គល ឬរូបវន្តបុគ្គល បុគ្គលឯកជន និងនីតិបុគ្គលរដ្ឋ ។

កាលណាភាគកម្មសាធារណៈលើសពី ៥១ភាគរយនៃដើមទុន ឬសិទ្ធិបោះឆ្នោតក្រុមហ៊ុនចំរុះត្រូវបានចាត់ទុកជាសហគ្រាសសាធារណៈ ។

**មាត្រា ៣៩.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរ៉ាប់រងខាងផ្នែករដ្ឋបាលលើភាគកម្មសាធារណៈ ។

**មាត្រា ៤០.-**

ប្រតិបត្តិការហិរញ្ញវត្ថុអំពីភាគកម្មសាធារណៈ ត្រូវបានធ្វើឱ្យសម្រេចដោយអនុលោមតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ហិរញ្ញវត្ថុជាធរមាន ។

**មាត្រា ៤១.-**

តាមបដិបញ្ញត្តិលើគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម រដ្ឋគ្រឹះស្ថានសាធារណៈ និងក្រុមហ៊ុនរដ្ឋ ត្រូវបានលើកលែងការតម្កល់ភាគហ៊ុនធានាសម្រាប់តំណាងនៅក្នុងក្រុមប្រឹក្សាភិបាលសហគ្រាសដែលខ្លួនបាន ចូលរួម ។

**មាត្រា ៤២.-**

តំណាងរបស់រដ្ឋ ឬតំណាងរបស់គ្រឹះស្ថានសាធារណៈ នៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចំរុះ ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

តំណាងរបស់ក្រុមហ៊ុនរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចំរុះ ត្រូវបានតែងតាំងដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុននោះ ក្រោយពីមានយោបល់ឯកភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៣.-**

តំណាងរបស់រដ្ឋ របស់គ្រឹះស្ថានសាធារណៈ ឬរបស់ក្រុមហ៊ុមរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចំរុះត្រូវបានជ្រើសរើសដោយផ្អែកលើគុណសម្បត្តិ និងបទពិសោធន៍របស់ខ្លួន ឬមួយពីក្នុងចំណោមមន្ត្រីរាជការបំរើការងារយ៉ាងតិច ៥ឆ្នាំ ឬចូលនិវត្តន៍តែមានអាយុមិនលើសពី ៦៥ឆ្នាំ ឬមួយពីក្នុងចំណោមឥស្សរជនខ្មែរដែលមានសមត្ថភាពខាងសេដ្ឋកិច្ច ខាងនីតិសាស្ត្រ ឬខាងវិទ្យាសាស្ត្រ ។

តំណាងទាំងនោះ អាចឱ្យរួចផុតពីការបង់ប្រាក់ធានាសម្រាប់មុខតំណែងនៅក្នុងក្រុមប្រឹក្សាភិបាលតែមិនត្រូវមានភាគហ៊ុនក្នុងសហគ្រាសឡើយ ។

**មាត្រា ៤៤.-**

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី របស់តំណាងទាំងនោះក្នុងការបំពេញភារកិច្ចរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចំរុះត្រូវធ្លាក់លើរដ្ឋ លើគ្រឹះស្ថានសាធារណៈ ឬលើក្រុមហ៊ុនរដ្ឋ តែតំណាងត្រូវទទួលខុសត្រូវដោយខ្លួនឯងខាងផ្នែកព្រហ្មទណ្ឌ ។

**មាត្រា ៤៥.-**

ហាមដាច់ខាតមិនឱ្យមន្ត្រីសាធារណៈដែលធ្លាប់ធ្វើជាតំណាងរបស់រដ្ឋ របស់គ្រឹះស្ថានសាធារណៈ ឬរបស់ក្រុមហ៊ុនរដ្ឋចូលធ្វើការនៅក្នុងមុខតំណែងណាមួយ ក្នុងសហគ្រាសដែលខ្លួនធ្លាប់ពាក់ព័ន្ធនៅមុនការផុតរយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃឈប់ធ្វើការរបស់តំណាងនោះ លើកលែងតែមានការអនុញ្ញាតពិសេសពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៦.-**

ត្រូវមានអាណត្តិគាហកៈពិសេសមួយរូប តំណាងរដ្ឋនៅក្នុងមហាសន្និបាតក្រុមហ៊ុនចំរុះ ។ អាណត្តិគាហកៈពិសេសមានវិសមិតភាពជាមួយតំណែងជាអគ្គនាយកនៃសហគ្រានោះ ។

**មាត្រា ៤៧.-**

អាណត្តិគាហកៈពិសេស មានភារកិច្ចការពារផលប្រយោជន៍រដ្ឋនៅក្នុងមហាសន្និបាតសាមញ្ញ និងវិសាមញ្ញ ហើយមានសិទ្ធិបោះឆ្នោតក្នុងនាមភាគីរដ្ឋ ។

**មាត្រា ៤៨.-**

អាណត្តិគាហកៈពិសេស ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការដែលបាន និងកំពុងបំរើការងារយ៉ាងតិច ៥ឆ្នាំ ។ អាណត្តិគាហកៈពិសេសត្រូវបានតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អាណត្តិគាហកៈពិសេសត្រូវសុំមតិណែនាំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមុនពេលចូលរួមមហាសន្និបាតក្រុមហ៊ុនចំរុះ ។

# ជំពូកទី ៤

# អវសានប្បញ្ញត្តិ

**មាត្រា ៤៩.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦ នាសម័យប្រជុំ
រដ្ឋសភាលើកទី ៦ នីតិកាលទី ១ ។

ភ្នំពេញ.ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៦
ប្រធានរដ្ឋសភាស្តីទី
ហត្ថលេខានិងត្រា
សឺន ស៊ូប៊ែរ្តិ៍